ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៤៨០ អយក.៣៦

ថ្ងៃ ពុធ ២ កើត ខែ ចេត្រ ឆ្នាំ ថោះ បញ្ចស័ក ពស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៤

## ជម្រាបជូន

- **ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ និងនាយកវិទ្យាស្ថាន**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាពចំណុះទីស្តីការក្រសួង**
- **លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការរៀបចំនិងអនុវត្តវិធានការគន្លឹះ ឆ្លើយតបទៅនឹងអនុសាសន៍របស់ ប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួង និងវេទិកាពិភាក្សាក្នុងសន្និបាតអប់រំឆ្នាំ២០២៤។

**យោង ៖** ស្មារតីនៃសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២២-២០២៣ និងទិសដៅការងារឆ្នាំសិក្សា ២០២៣-២០២៤។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២២-២០២៣ និងទិសដៅការងារឆ្នាំសិក្សា២០២៣-២០២៤ កាលពីថ្ងៃទី៣១ ខែមីនា ដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤ កន្លងមក បានដាក់ចេញនូវវិធានការគន្លឹះសំខាន់ៗមួយចំនួន ឆ្លើយតបទៅនឹងអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួង និងវេទិកាពិភាក្សា ក្នុងសន្និបាតអប់រំបន្ថែមលើទិសដៅដែលបានកំណត់ក្នុងរបាយការណ៍សន្និបាតអប់រំសម្រាប់អនុវត្តនៅឆ្នាំ២០២៤ និងឆ្នាំបន្តបន្ទាប់ (ឧបសម្ព័ន្ធទី១)។ ដើម្បីឱ្យក្រសួងអាចឆ្លុះបញ្ចាំងបានពីសមិទ្ធកម្មនៅឆ្នាំ២០២៤ និងឆ្នាំបន្តបន្ទាប់ ខ្ញុំសូមស្នើឯកឧត្តម លោកជំទាវ លោក លោកស្រី ដាក់បញ្ចូលវិធានការគន្លឹះទាំងនេះទៅក្នុងផែនការសកម្មភាពរបស់អង្គភាពសម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាព។ នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ នាយកដ្ឋានផែនការ នៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ មានភារកិច្ចសម្របសម្រួលនិងតាមដានការអនុវត្តសកម្មភាពដែលបានកំណត់ ព្រមទាំងសហការជាមួយនឹងអង្គភាពពាក់ព័ន្ធ និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបនិងចាត់ចែងអនុវត្តការងារនេះប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធ
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍

# ស្តីពី

# លទ្ធផលសន្និបាតអប់រំ យុវជន និងកីឡា
# និងវិធានការគន្លឹះឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា
# បន្ថែមលើទិសដៅដែលបានកំណត់ក្នុងរបាយការណ៍សន្និបាត
# សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤

ខែមេសា ឆ្នាំ ២០២៤

## ១. សេចក្តីផ្តើម

សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២២-២០២៣ និងលើកទិសដៅការងារឆ្នាំសិក្សា ២០២៣-២០២៤ បានប្រារព្ធធ្វើឡើងចាប់ពីថ្ងៃទី៣១ ខែមីនា ដល់ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ពិធីបើកសន្និបាតប្រព្រឹត្តទៅក្រោមអធិបតីភាព**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងពិធីបិទសន្និបាតប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

### ១.១ សមាសសភាពអញ្ជើញចូលរួមសន្និបាត

អង្គសន្និបាតមានអ្នកចូលរួមដោយផ្ទាល់ប្រមាណ ២ ០០០នាក់ និងតាមរយៈប្រព័ន្ធអនឡាញ មកពីក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្ត ឃុំ សង្កាត់ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀន (នាយកល្អ សាលារៀនស្អាត សាលារៀនគំរូ គ្រូបង្រៀនល្អភាសាខ្មែរនិងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ និងសាលារៀនទទួលបានលទ្ធផលល្អតេស្តវាយតម្លៃ PISA-2022 និង SEA-PLM-2019) វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។

### ១.២ គោលបំណងសន្និបាតអប់រំ

- ជាវេទិកាពិគ្រោះយោបល់លើការរៀបចំ និងអនុវត្តគោលនយោបាយជាមួយថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ
- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តបរិវត្តកម្មអប់រំ និងស្តង់ដាសាលារៀនគំរូ
- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣
- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តសូចនាករនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តទិសដៅដែលបានដាក់ចេញក្នុងសន្និបាតឆ្នាំកន្លងមក
- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣
- កំណត់បញ្ហាប្រឈមនានាដែលជាឧបសគ្គ
- ផ្តល់អនុសាសន៍ និងវិធានការសំខាន់ៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ និងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥។

## ២. វឌ្ឍនភាពក្នុងឆ្នាំសិក្សា ២០២២-២០២៣ និងក្នុងរយៈពេល ៦ខែ ដើមអាណត្តិទី៧

### ផ្នែកបរិមាណវិស័យ

ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ សាលារៀនចំណេះទូទៅ និងមត្តេយ្យសិក្សាមានចំនួន ១៩,៣៤១កន្លែង ក្នុងនោះ សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៨,៨៩១កន្លែង សាលាបឋមសិក្សា ៨,២៥២ (ឯកជន ៨៥៤) អនុវិទ្យាល័យ ១,៣៤១ (ឯកជន ៩៩) និងវិទ្យាល័យ ៨៩៧ (ឯកជន ៣១៦)។ គ្រឹះស្ថានឧត្តមសិក្សាមាន ១៦៩កន្លែង (ឯកជន ៩១)។ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** មាន ៤ ៥៤៥ ខ្នង ស្មើ ២៩ ៧០៥ បន្ទប់។

សិស្ស និងនិស្សិតសរុប ៤,០៩៦,៧៥៨នាក់ (កុមារមត្តេយ្យសិក្សា ៤០០,៩៥៩នាក់ ស្រី ៥០.២%, សិស្សបឋមសិក្សា ២,២៦៥,៧៨៣នាក់ ស្រី ៤៧.៩%, សិស្សមធ្យមសិក្សាបឋមភូមិ ៧១១,១១៣នាក់ ស្រី ៥៣.៣%, សិស្សមធ្យមសិក្សាទុតិយភូមិ ៤៣០,៧៩២នាក់ ស្រី ៥៥%, សិស្សមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស ៣,៥១២នាក់ ស្រី ៣៥.៤% និងនិស្សិតឧត្តមសិក្សា ២៨៤,៥៩៩នាក់ ស្រី ៥២.៣%)។

ក្រុមប្រឹក្សាកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សា ៨ ៩៨០ មានសមាជិក ១ ៥៦៣ ២៩៤នាក់ ស្រី ៧៨៦ ៩៨៣នាក់ និងក្រុមប្រឹក្សាយុវជនកម្ពុជានៅតាមគ្រឹះស្ថានសិក្សា ៦០៦ មានសមាជិក ៣៧៤ ៦៨៤នាក់ ស្រី ២០៤ ៥៩៤នាក់ ។

ក្រសួងបានប្រមូលផ្តុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ ១ ៣៨៤នាក់ កើន ៣៣,៦ភាគរយ មកធ្វើការហាត់ហ្វឹកហ្វឺន បង្កើនសមត្ថភាពបច្ចេកទេសលើ ៤៣ប្រភេទកីឡា និង ១៣ប្រភេទកីឡាជនមាន ពិការភាព

បុគ្គលិកអប់រំមាន ១២៤ ៥១៧នាក់ ស្រី ៥៩ ១៦៥នាក់ ក្នុងនោះថ្នាក់ជាតិ ៤ ៩៧៨នាក់ ស្រី ១ ៦៥៨នាក់ និង ថ្នាក់ក្រោមជាតិ ១១៩ ៥៣៩នាក់ ស្រី ៥៧ ៥០៧នាក់។ បុគ្គលិកមិនបង្រៀន ៣៣ ៣៥៥នាក់ ស្រី ១០ ៦៥៣នាក់ និង បុគ្គលិកបង្រៀន ៨៦ ១៨៤នាក់ ស្រី ៤៦ ៨៥៤នាក់។

## ផ្នែកគុណវិស័យ

កុមារអាយុ ៦ឆ្នាំ បានចូលរៀនថ្នាក់ទី១ មាន ៧៧,៨១ភាគរយ ស្រី ៧៧,៩២ភាគរយ។ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ៨៩,២ភាគរយ ស្រី ៩២,៣ភាគរយ និងមធ្យមសិក្សាបឋមភូមិ ៦០,៩៧ភាគរយ ស្រី ៦៦,៣៧ ភាគរយ។ អត្រាឆ្លងភូមិសិក្សានៅបឋមសិក្សា ៨៦,៦ភាគរយ ស្រី ៨៩,០ភាគរយ និងមធ្យមសិក្សាបឋមភូមិ ៨៦,៦ភាគរយ ស្រី ៨៩,០ភាគរយ។

បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៧២,៨៩ភាគរយ ស្រី ៧៨,០៩ភាគរយ។ សិស្សផ្នែកអប់រំបច្ចេកទេសប្រឡងបញ្ចប់ឆ្នាំទី១ ឆ្នាំទី២ និងប្រឡងជាប់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ចំនួន ៩៧២១ភាគរយ, ស្រី ៩៩០៤ភាគរយ,។

និស្សិតបញ្ចប់ការសិក្សា ៥៩ ៦៨៥នាក់ ស្រី ២៨ ៥១៨នាក់ ក្នុងនោះថ្នាក់បរិញ្ញាបត្ររង ៧ ៧៧៥នាក់ ស្រី ៤ ២០១នាក់ ថ្នាក់បរិញ្ញាបត្រ ៣៨ ៥៩៤នាក់ ស្រី ២៣ ២០៦នាក់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៣ ២០២នាក់ ស្រី ១ ០៩៦នាក់ និងថ្នាក់បណ្ឌិត ១១៤នាក់ ស្រី ១៥នាក់។ និស្សិតអាហារូបករណ៍កម្ពុជាបានបញ្ចប់ការសិក្សាពីបរទេស ៦៣០នាក់ ស្រី ១១៣នាក់ ស្មើ ២០,៥៧ភាគរយ។

ក្រសួងបានរៀបចំចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" ទទួលបានពានរង្វាន់ឆ្នើមប្រចាំឆ្នាំ២០២៣ ចំនួន ២៩០នាក់ ស្រី ៥២ភាគរយ។

ការប្រកួតកីឡាលក្ខណៈអន្តរជាតិក្នុងប្រទេសទទួលបានមេដាយ ៤៧៣គ្រឿង (មេដាយមាស ១២០គ្រឿង ប្រាក់ ១៣៨គ្រឿង និងសំរឹទ្ធ ២១៤គ្រឿង) និងការប្រកួតកីឡាជាលក្ខណៈអន្តរជាតិក្រៅប្រទេសទទួលបានមេដាយ ១២២គ្រឿង (មេដាយមាស ៣៥គ្រឿង ប្រាក់ ៣៦គ្រឿង និងសំរឹទ្ធ ៥១គ្រឿង)។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកំណែទម្រង់វិស័យអប់រំ ៩ចំណុចឆ្លើយតបទៅនឹងបរិវត្តកម្មអប់រំ ដែលមានវឌ្ឍនភាពដូចខាងក្រោម៖

### ១) ការបើកសាលារៀនឡើងវិញប្រកបដោយសុវត្ថិភាព ការស្តារឡើងវិញនូវការរៀនសូត្រ និងការបន្តការសិក្សារបស់សិស្ស

- ការបង្កើតគណៈកម្មការសុខភាពសិក្សានៅតាមសាលារៀន ៩ ៤៦៧សាលា
- ការផ្សព្វផ្សាយគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពី ការលើកកម្ពស់សុខភាពសិក្សានៅគ្រឹះស្ថានសិក្សា
- ការផ្សព្វផ្សាយគោលការណ៍បរិស្ថានសាលារៀនបៃតង សាលារៀនស្អាតគ្មានសំរាមនៅគ្រឹះស្ថានសិក្សា។

### ២) កំណែទម្រង់សាលារៀន

- ការដាក់ឱ្យអនុវត្តស្តង់ដាសាលាគំរូ គ្រប់ភូមិសិក្សា
- ការពង្រឹងការគ្រប់គ្រងតាមសាលារៀនឆ្ពោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងផ្លាស់ប្តូរវប្បធម៌សាលារៀន
- ការបំប៉នសមត្ថភាពស្តីពីការគ្រប់គ្រងតាមសាលារៀន SBM ដល់នាយកសាលា និងគ្រូបង្រៀន ២ ០០០នាក់។

### ៣) ការអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពខ្ពស់ តាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- ការអនុម័តក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀន តាមប្រព័ន្ធក្រេឌីត ដោយផ្អែកលើក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនថ្នាក់តំបន់ និងសកល ព្រមទាំងឧត្តមានុវត្តន៍នានា
- ការអនុម័តក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធអនុវត្តក្រេឌីតបរិញ្ញាបត្រ+១

- ការអនុម័តផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៣-២០៣០
- គ្រូបង្រៀននិងនាយកសាលា ៦ ៦៥៩នាក់ ទទួលបានក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងត្រៀមវាយតម្លៃចូលគន្លងអាជីពគ្រូបង្រៀន។

### ៤) ការអប់រំឌីជីថល

- ការរៀបចំយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន
- ការអភិវឌ្ឍសៀវភៅសិក្សាគោលមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) សម្រាប់មធ្យមសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី១២
- ការអភិវឌ្ឍថ្នាលអប់រំឌីជីថល (e-learning) និងធនធានសិក្សាកម្ពុជា (OER) សម្រាប់ជំនួយគ្រូក្នុងការបង្រៀនតាមអេឡិចត្រូនិកនៅតាមសាលារៀន
- ការបង្កើតក្លឹបសិក្សាសរសេរកូដ សម្រាប់សិស្សានុសិស្សសិក្សានៅតាមសាលារៀន។

### ៥) ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

ក្រសួងបាននិងកំពុងផ្តោតលើការអប់រំស្ទែម តាមរយៈបង្កើនម៉ោងបង្រៀន និងការបង្រៀនផ្តោតលើមុខវិជ្ជាស្ទែម ការវិនិយោគលើការបំពាក់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រតាមមុខវិជ្ជា បន្ទប់កុំព្យូទ័រ បណ្ណាល័យសតវត្សរ៍ទី២១ និងបំពាក់សម្ភារឧបទេស សម្ភារពិសោធន៍នៅតាមវិទ្យាល័យធនធាន និងសាលារៀនជំនាន់ថ្មី ការបង្កើនគុណភាពនៃការបណ្តុះបណ្តាលគ្រូមុខវិជ្ជាស្ទែមឱ្យដល់កម្រិតស្តង់ដារវិជ្ជាជីវៈ ការកែលម្អវិធីសាស្ត្របង្រៀនតាមមុខវិជ្ជាស្ទែម តាមបែបគម្រោង វិធីរិះរក និងវិធីផ្សេងទៀត ការបង្កើតក្លឹបសិក្សាក្រោយម៉ោងសិក្សា និងពង្រឹងក្រុមប្រឹក្សាយុវជន ការបង្កើតប្រព័ន្ធអេកូឡូស៊ីដូចជា ពិព័រណ៍វិទ្យាសាស្ត្រ ការប្រកួតប្រជែងស្នាដៃ និងការបង្កើតភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សា និងក្រុមហ៊ុនឯកជន និងការអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ជាមួយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ៦ ដើម្បីគាំទ្រការរៀន និងបង្រៀនតាមបែបឌីជីថល។

### ៦) ការអភិវឌ្ឍជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន

- ការអនុវត្តកម្មវិធីយុវជន២១ ក្រោមប្រធានបទ សហគ្រិនឌីជីថល នវានុវត្តន៍អាជីវកម្ម និងកម្មវិធីអប់រំសហគ្រិនភាព
- ការអប់រំស្តីពីសហគ្រិនភាពឌីជីថលក្នុងកម្មវិធីយុវជន២១ ក្រោមប្រធានបទ «នវានុវត្តន៍អាជីវកម្ម» ដល់យុវជន ៦៥៩ នាក់ ស្រី ២៧៤នាក់
- កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ និងជំនាញនិយាយសាធារណៈ យុវជនចូលរួម ៣៩៦នាក់ ស្រី ២២៧នាក់ និងការប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១ (គម្រោងSTEM) យុវជនចូលរួម ៥៧០នាក់ ស្រី ២៨០ នាក់

### ៧) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅកម្រិតឧត្តមសិក្សា

- ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា ៤
- ការអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ដោយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៦ ដើម្បីគាំទ្រការរៀន និងបង្រៀនតាមបែបឌីជីថល
- ការរៀបចំ និងកែលម្អកម្មវិធីសិក្សា ៧៩ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ១១
- ការអនុវត្តគម្រោងស្រាវជ្រាវ ១៩០ (ក្រោមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ១៣ និងគ្រឹះស្ថានឯកជន៥០)។

### ៨) ការពង្រឹងសមត្ថភាពស្ថាប័ន និងការកសាងប្រព័ន្ធអប់រំ

- ការសម្រួចសកម្មភាពអាទិភាពដោយបន្សុីជាមួយនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងអាទិភាពកំណែទម្រង់
- ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកាឆ្នាំ២០២៤ ដោយផ្សារភ្ជាប់ជាមួយនឹងផែនការសមិទ្ធកម្ម
- ការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៣ និង ២០២៤ រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨
- ការពិនិត្យឡើងវិញមុខងារ រចនាសម្ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៩) ការអភិវឌ្ឍការអប់រំកាយ និងកីឡា

- ការប្រមូលផ្តុំត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេម និងត្រៀមលក្ខណៈការប្រកួតកីឡាអន្តរជាតិនានា
- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា
- ការបើកផ្តល់សម្ភារៈកីឡាជូនកីឡាករ កីឡាការិនីសម្រាប់ហាត់ហ្វឹកហ្វឺនគ្រប់គ្រាន់
- ការបណ្តុះបណ្តាលគ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម និងមន្ត្រីរៀបចំការប្រកួតកើនពី ១ ០៣៦នាក់ ស្រី ២៨៣នាក់ នៅឆ្នាំ២០២២ ដល់ ១ ៤៣៨នាក់ នៅឆ្នាំ២០២៣
- ការប្រមូលផ្តុំក្រុមកីឡាជម្រើសជាតិ និងក្រុមកីឡាជនមានពិការភាពនៅក្នុងប្រទេស និងក្រៅប្រទេស ១ ៣៨៤នាក់ ស្រី ៤៥៥នាក់។

ក្រសួងបាន និងកំពុងអនុវត្តយ៉ាងសកម្មនូវវិធានការគន្លឹះ ៤ ចំណុចរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ដែលបានដាក់ចេញអនុសាសន៍ដ៏ខ្ពង់ខ្ពស់ នាសម័យប្រជុំដំបូងគណៈរដ្ឋមន្ត្រី សម្រាប់នីតិកាលទី៧ សំដៅលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតសំខាន់លើការពង្រឹង គុណភាពសាលារៀនរដ្ឋ ចាប់ពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សា៖ ទី១) ការពង្រឹងអភិបាលកិច្ចសាលារៀន, ទី២) ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាព ក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និង ឥរិយាបថរបស់សិស្ស, ទី៣) ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យ គុណភាពចំណីអាហារនៅតាមសាលា, ទី៤) ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីការអប់រំ។ បន្ថែមពីលើនេះ ក្រសួង បានកំណត់អាទិភាពចំនួន៤បន្ថែមទៀតគឺ ទី៥).ការអប់រំឌីជីថល, ទី៦).ការបង្កើតមជ្ឈមណ្ឌល ឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា, ទី៧).ការកសាងប្រព័ន្ធនិងការអភិវឌ្ឍសមត្ថភាព, និងទី៨) ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

## ២.១ ការអនុវត្តសាលារៀនគំរូ

ក្រសួងបានចេញប្រកាសដាក់ឱ្យអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ សាលាបឋមសិក្សាគំរូ និងសាលាមធ្យមសិក្សាគំរូ ជាមួយនឹងយន្តការគាំទ្រ និងអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីធានាបានការអនុវត្តមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។ ក្នុងឆ្នាំ២០២៤ សាលារៀនចំនួន ៧៩៣ ត្រូវបានជ្រើសរើសជាសាលារៀនគោលដៅអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីធ្វើអធិការកិច្ច ផ្តល់ការគាំទ្រ និងជំរុញការអនុវត្ត ក្នុងនោះសាលាមត្តេយ្យសិក្សា ៩៦ សាលាបឋមសិក្សា ៣៤៨ និងសាលាមធ្យមសិក្សា ៣៤៩។ ក្រសួងបាននិងកំពុងជំរុញការអនុវត្តសាលារៀនគំរូតាមគ្រប់រូបភាពដោយប្រើប្រាស់យន្តការ និងធនធានសរុប ទាំងថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍ ក្នុងនោះក្រសួងបានកៀរគរឥណទានថវិកាពីសកម្មភាពផ្សេងៗដើម្បីអនុវត្តសាលារៀនគំរូ បានថវិកាសរុប ១៥ ៥៤៣ ២០០ ០០០ រៀល ឬស្មើនឹង ៣.៨លានដុល្លារ។ ជាមួយនេះ ក្រសួងបានធ្វើការវាយតម្លៃ និងទទួលស្គាល់ជ័យលាភីសាលារៀនគំរូចំនួន ១២០ ដោយផ្អែកលើគោលការណ៍៖

- សាលារៀនធ្លាប់ទទួលបានជ័យលាភីជានាយកល្អ និងសាលារៀនស្អាត
- សាលារៀនដែលទទួលជ័យលាភីជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ
- សាលារៀនដែលមានសិស្សនិទ្ទេស A, និទ្ទេស ABC, និងភាគរយប្រឡងជាប់ច្រើន ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- សាលារៀនដែលបានចូលរួមវង្វាយតម្លៃការសិក្សាកម្រិតតំបន់ SEA-PLM និងកម្រិត អន្តរជាតិ PISA និងមានសិស្សទទួលបានពិន្ទុខ្ពស់

– សាលារៀនជំនាន់ថ្មី វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងសាលារៀនទទួល បានពិន្ទុខ្ពស់ក្នុងការវាយតម្លៃស្តង់ដាសាលារៀនគំរូ។

នៅក្នុងការអនុវត្តសាលារៀនគំរូឆ្នាំទី១ ក្រសួងបានចេញប្រកាសទទួលស្គាល់សាលារៀនទាំង ១២០ នៅក្នុងឱកាសសន្និបាតអប់រំ និងបានលើកចិត្តឱ្យសាលារៀនទាំង ១២០ និងសាលារៀនដទៃទៀតបន្តធ្វើការកែលម្អ និងអនុវត្តឱ្យបានពេញលេញនូវស្តង់ដាសាលារៀនគំរូ នៅឆ្នាំបន្តបន្ទាប់ទៀត។ ជាមួយគ្នានេះ ក្រសួងបានទទួលស្គាល់ **មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតស្រែក្នុង** ស្ថិតក្នុងស្រុកជុំគីរី ខេត្តកំពត ជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតគំរូ ដោយមើលឃើញអំពីលទ្ធផលនៃការបំពេញការងារល្អ និងភាពជាអ្នកដឹកនាំល្អរបស់លោកនាយក។

ដើម្បីគាំទ្រដល់កំណែទម្រង់សាលារៀន ក្រសួងបានកែលម្អការងារអធិការកិច្ច ដែលជា កិច្ចការដ៏សំខាន់មួយក្នុងការគាំទ្រសាលារៀនគំរូ ដោយក្រសួងបានបន្សុីឧបករណ៍អធិការកិច្ច ជាមួយស្តង់ដាសាលារៀនគំរូ ដើម្បីក្តាប់បានស្ថានភាពរបស់សាលារៀននីមួយៗ និងឈានទៅរៀបចំសកម្មភាពជាក់លាក់សម្រាប់ចុះជួយគាំទ្រ។

**ការរៀបចំតេស្តស្តង់ដា៖** ដើម្បីពង្រឹងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅកម្រិត សាលារៀន និងជាមូលដ្ឋានសម្រាប់រៀបចំផែនការកែលម្អសាលារៀន។ ក្រសួងបាន និងកំពុង រៀបចំសេចក្តីណែនាំ ដើម្បីជំរុញឱ្យសាលាបឋមសិក្សា និងសាលាមធ្យមសិក្សាអនុវត្តតេស្តស្តង់ដាឱ្យបានច្បាស់លាស់។ ការធ្វើតេស្តស្តង់ដា ប្រចាំខែ ត្រីមាស និងឆមាស លទ្ធផលនឹងត្រូវយកមក កែលម្អការបង្រៀននិងរៀន។ ម៉្យាងវិញទៀត ក្រសួងចាប់ផ្តើមយកសំណួរតេស្តកម្រិតតំបន់ និងកម្រិតអន្តរជាតិមកអនុវត្តតាមសាលារៀន ដើម្បីជានាសង្គតិភាពរវាងការរៀន និងការ បង្រៀន និងការធ្វើតេស្ត។

**ការអនុវត្តវិធីសាស្ត្របង្រៀន ដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មី៖** ដោយក្រសួងបាន និងកំពុងជំរុញឱ្យសាលារៀនគំរូអនុវត្ត "វិធីសាស្ត្របង្រៀនថ្មី" ដូចជាការបង្រៀនតាមបែបគម្រោង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន ជាដើម ដើម្បីពង្រឹងគុណភាពអប់រំ និងលើកកម្ពស់ បំណិនសតវត្សទី២១ និងឆ្លើយតបនឹងតេស្ត PISA។

**យុទ្ធសាស្ត្រការបង្រៀននិងរៀនពេញមួយថ្ងៃ៖** ក្រសួងបានដាក់ឱ្យអនុវត្តការរៀន និង បង្រៀនពេញមួយថ្ងៃ ដោយប្រើមូលនិធិសមធម៌នៅតាមសាលាបឋមសិក្សាចំនួន ២០កន្លែង។ ជាមួយនេះ ក្រសួងបាននិងកំពុងរៀបចំយុទ្ធសាស្ត្របង្រៀនពេញមួយថ្ងៃ តាមរយៈការលើកកម្ពស់អំណានបន្ថែម និងការធ្វើស្វ័យសិក្សា ដោយប្រើប្រាស់សន្លឹកកិច្ចការ កម្មវិធីកីឡា ការងារសង្គម ការបង្រៀនសិល្បៈ និងវប្បធម៌ខ្មែរ ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី**។

**ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា៖** ក្រសួងបានជំរុញឱ្យសាលារៀនដែលមានសក្តានុពល ដើម្បីបង្កើនម៉ោងសិក្សាពី ៤ ម៉ោងក្នុង ១ថ្ងៃ នាពេលបច្ចុប្បន្នទៅ ៦ម៉ោងក្នុង១ថ្ងៃ ឬ ៤០ម៉ោង ក្នុង១សប្តាហ៍ ដោយគិតគូរអំពីលទ្ធភាពនៃបន្ទប់រៀន និងចំនួនគ្រូបង្រៀន។ ក្រសួងបានចេញសេចក្តីណែនាំ ដើម្បីដោះស្រាយបញ្ហាវត្តមានរបស់គ្រូបង្រៀន និងវត្តមានរបស់សិស្ស ព្រមទាំងការពង្រឹងវិន័យនៅក្នុងនិងក្រៅសាលារៀន។ ក្រសួងបានជំរុញឱ្យសាលារៀនរៀបចំយន្តការ និងបង្កើតក្លឹបសិក្សា ដើម្បីធ្វើស្វ័យសិក្សា និងការជួយសិស្សរៀនយឺត។ ក្រសួងបានចេញសេចក្តីណែនាំស្តីពី ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានសិក្សាមធ្យមសិក្សាសាធារណៈដែលជាផ្នែកមួយជំរុញ «ភាពជាដៃគូសាធារណៈនិងសហគមន៍ក្នុងការអប់រំ» ក្នុងគោលដៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួម ជាពិសេសការបង្កើតទំនាក់ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស។

**ការអនុវត្តអំណាន និងគណិតវិទ្យាថ្នាក់ដំបូង៖** គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់របស់សិស្ស នៅបឋមសិក្សា និងភូមិសិក្សាបន្តបន្ទាប់ទៀត។ ក្រសួងបាននិងកំពុងពង្រឹង គុណភាពនៃការអប់រំកម្រិតបឋមសិក្សាតាមរយៈ៖១)ការលើកកម្ពស់អំណានដំបូង ២)គណិតវិទ្យាថ្នាក់ដំបូង ៣)បង្កើនចំនួនគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣, និង៤)បង្កើត «សាលាគំរូអំណាននិងគណិតថ្នាក់ដំបូង»។ ការលើកកម្ពស់អំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង ជាពិសេសការបណ្តុះបណ្តាលគ្រូ និងការពង្រីកការអនុវត្តនៅទូទាំងប្រទេសមានគោលដៅលើកកម្ពស់គុណភាពអប់រំ តាមរយៈការបង្កើនលទ្ធផលសិក្សា

របស់សិស្សពោលគឺ កុមារកម្ពុជាចេះអាន សរសេរ និងគិតលេខទាំងអស់គ្នា។ ជាលទ្ធផល ក្រសួងបានសហការ ជាមួយដៃគូអភិវឌ្ឍ អនុវត្តកញ្ចប់សម្ភារអំណានថ្នាក់ទី១ បានគ្រប់សាលាបឋមសិក្សាក្នុង ២២ រាជធានី ខេត្ត អំណានថ្នាក់ទី២ បានអនុវត្តក្នុង ១៩ខេត្ត និងអំណានថ្នាក់ទី៣ បានអនុវត្តនៅ ខេត្តកំពង់ឆ្នាំង។ កញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ទី១ បានអនុវត្តនៅ ៨ខេត្ត និងកញ្ចប់សម្ភារ គណិតវិទ្យាថ្នាក់ទី២ បានអនុវត្តនៅ ៦ខេត្ត។ ក្រសួងបានបញ្ចូលកញ្ចប់អំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង ក្នុងការបណ្ដុះបណ្ដាលគ្រូនៅតាមសាលាគរុកោសល្យ។

**សេចក្ដីណែនាំស្ដីពី ការបង្កើតគ្រឹះស្ថានសិក្សា រួមទាំងសាលារៀនឧបសម្ព័ន្ធ៖** ដើម្បីកំណត់ បានទំហំគ្រប់ដណ្ដប់នៃសេវាអប់រំរបស់សាលារៀននីមួយៗបានច្បាស់លាស់ រួមទាំងការបង្កើត សាលាឧបសម្ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងដឹកនាំ និងប្រសិទ្ធភាពការងារនៅ គ្រប់កម្រិត។ សេចក្ដីណែនាំនេះនឹងចេញឱ្យអនុវត្តនាពេលឆាប់ៗនេះ។ បញ្ហាប្រឈមកន្លងមកគឺ ប្រជាពលរដ្ឋបានទៅរស់នៅតំបន់ដីថ្មី និងបានបង្កើតជារោងដោល ដោយគ្មានការទទួលស្គាល់ ពីក្រសួង (ចំនួនជាង ៣០០) ជាហេតុធ្វើឱ្យតម្រូវការក្នុងការសាងសង់អគារថ្មីកើនឡើងខ្លាំង លើសពីលទ្ធភាពជាក់ស្ដែង។

## ២.២ កំណែទម្រង់មុខងារសាធារណៈ

**ការពិនិត្យឡើងវិញមុខងារក្រសួង និងអនុក្រឹត្យថ្មី៖** ក្រសួងបានធ្វើការវិភាគមុខងារបែបស៊ីជម្រៅតាមស្មារតីនៃការធ្វើ វិចារណកម្ម ដោយបានកាត់ចោលមុខងារត្រួតស៊ីគ្នាក្នុងការអនុវត្តភារកិច្ច និងបានកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនឱ្យស្របទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ការកែសម្រួលរចនាសម្ព័ន្ធនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងអនុវត្តកំណែទម្រង់វិស័យអប់រំ ឱ្យកាន់តែមានប្រសិទ្ធភាព និងរៀបចំផែនការអភិវឌ្ឍបណ្ដុះបណ្ដាលធនធានមនុស្ស ដើម្បី ពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពមន្ត្រីរាជការ ក្នុងគោលដៅសម្រេចចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ ខាងមុខ។ ក្រសួងបានពិនិត្យ និងកាត់បន្ថយនាយកដ្ឋានចំនួន៤ និងការិយាល័យចំនួន ៣៤ និងបានប្រែក្លាយអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ទៅជាអគ្គលេខាធិការដ្ឋាន ដើម្បីសម្របសម្រួលការងារ ព្រមទាំងបង្កើតអគ្គនាយកដ្ឋានថ្មីមួយគឺ អគ្គនាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស។

**ការរៀបចំផែនការអភិវឌ្ឍសមត្ថភាព៖** ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស ដោយផ្ដោតលើការបណ្ដុះបណ្ដាលវិជ្ជាជីវៈជាគ្រូបង្រៀន ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង និងអ្នកស្រាវជ្រាវ និងវាយតម្លៃ ព្រមទាំងបង្កើតយន្តការតម្រង់ទិសការងារ ការចុះជួយបង្វឹកការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ជាកិច្ចបន្ទាប់ ក្រសួងនឹងរៀបចំ និងអនុម័តផែនការស្ដីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ២០២៤-២០២៨ ឱ្យបានមុនដំណាច់ឆមាសទី១ ឆ្នាំ២០២៤ និងកំណត់អាទិភាពបណ្ដុះបណ្ដាលអ្នកជំនាញឱ្យបានពី ១០០ ទៅ ២០០នាក់ ក្នុងរយៈពេល ២ឆ្នាំ។

**ការសិក្សាបែងចែកតំបន់ជួបការលំបាក៖** គឺជាកិច្ចការដ៏សំខាន់នៃការគ្រប់គ្រងបុគ្គលិក ជាពិសេសការធ្វើឱ្យប្រសើរឡើងនូវការផ្ដល់ និងរក្សាបុគ្គលិកអប់រំនៅតាមសាលារៀនទូទាំង ប្រទេសសំដៅធានាបានសមធម៌ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព។ ក្រសួងបានពិនិត្យកែសម្រួលការកំណត់លក្ខខណ្ឌស្ដីពីតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកឱ្យទៅជាការកំណត់សាលារៀនជួបការលំបាក ដែលសំដៅដល់សាលារៀនស្ថិតក្នុងភូមិសាស្ត្រងាយរងគ្រោះដោយកត្តាធម្មជាតិស្ថិតនៅតំបន់ដាច់ស្រយាល និងខ្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងសហគមន៍ ស្ថិតក្នុងសហគមន៍ងាយរងគ្រោះដោយកត្តាផ្សេងៗ និងលទ្ធផលសិក្សាទាប។ ក្រសួងនឹងប្រើប្រាស់ថវិកាដែលសន្សំបាន ដើម្បីប្រើប្រាស់សម្រាប់លើកទឹកចិត្តគ្រូឱ្យមានប្រសិទ្ធភាពក្នុងគោលដៅពង្រាយគ្រូឱ្យបានដល់សាលាដែលជួបការលំបាកពិតៗ។

**ការសិក្សាលើដំណោះស្រាយបញ្ហាខ្វះអគារសិក្សា ថ្នាក់រៀន ការខ្វះគ្រូ និងបន្ទប់រៀន ដែលមានសិស្សច្រើនលើសលប់៖** ក្រសួងបានធ្វើការសិក្សាស្ដីពីស្ថានភាពអគារសិក្សា ខ្វះគ្រូបង្រៀន និងបន្ទប់រៀនដែលមានសិស្សច្រើន និងកំពុងពិគ្រោះយោបល់ និងដាក់ចេញវិធានការដោះស្រាយជាក់លាក់ ដើម្បីធានាបានការធ្វើផែនការ និងការប្រើប្រាស់បុគ្គលិកអប់រំនៅកម្រិតសាលារៀន។ វិធានការដោះស្រាយរួមមាន៖ ការធ្វើចំណោលតម្រូវការគ្រូបង្រៀនរយៈពេលវែង ការរៀបចំផែនការដោយ

សហការជាមួយនាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ និងភាគីពាក់ព័ន្ធ ដែលមានលក្ខណៈពីក្រោមឡើងលើ និងពីលើចុះក្រោម ដើម្បីកាត់បន្ថយកត្តាខ្វះខាត ការផ្គត់ផ្គង់គ្រូបង្រៀនដោយថែជន្យ ការរៀបចំគោលការណ៍បែងចែកគ្រូ ដោយវិភាគទៅលើទីតាំងដែលអាចប្រើប្រាស់ ឬដាក់ដំណើរការបង្រៀនបែបប្រព័ន្ធឌីជីថលបាន ការផ្លាស់ប្តូរគ្រូបង្រៀនត្រូវពិនិត្យលក្ខខណ្ឌ និងកែសម្រួលដើម្បីធ្វើបច្ចុប្បន្នកម្ម ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

**ការជំរុញការអនុវត្តគន្លងអាជីព** ដែលក្រសួងបានអនុម័តរួចហើយនូវក្របខណ្ឌគោល នយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំងក្របខណ្ឌនិងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន។ គន្លងអាជីពចែកចេញជា៣ផ្នែកៈ គ្រូបង្រៀន គណៈគ្រប់គ្រង និងអ្នកបច្ចេកទេស និងជា ៣កម្រិតៈ ល្អ ឆ្នើម និងឈានមុខ។ មកទល់ពេលនេះ ក្រសួងបានផ្តល់សិទ្ធិក្នុងការផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់អង្គភាពចំនួន ៤ និងបានបើកវគ្គចំនួន ៣៧ប្រធានបទ រួចហើយ ដើម្បីផ្តល់ឱកាសដល់បុគ្គលិកអប់រំក្នុងការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងវិធីសាស្ត្របង្រៀន។ ក្រសួងក៏បណ្តុះស្មារតីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពេញមួយជីវិតការងារដល់បុគ្គលិកអប់រំដោយផ្តោតលើៈ

- ធានាឱ្យមានក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ
- ធានាថាបុគ្គលិកអប់រំគ្រប់រូបនឹងទទួលបានវគ្គវិក្រឹតការទៀងទាត់
- ធានាការផ្សារភ្ជាប់រវាងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពបុគ្គលិកអប់រំ
- ធានាឱ្យមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការផ្សារភ្ជាប់កំណែទម្រង់គ្រូបង្រៀន និងកំណែទម្រង់សាលារៀន។

**ការលើកកម្ពស់ការប្រឡងប្រណាំងៈ** ក្រសួងបានលើកទឹកចិត្ត និងជំរុញឱ្យមានការប្រឡងប្រណាំងសាលារៀនល្អ គ្រូបង្រៀនល្អ នាយកល្អ សាលារៀនគំរូ និងប្រធានមន្ទីរគំរូឱ្យបានកាន់តែច្រើន តាមរយៈការរៀបចំយន្តការវាយតម្លៃនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងនៅថ្នាក់ជាតិ។ គ្រូបង្រៀនល្អ នាយកល្អ និងអ្នកជំនាញល្អ ត្រូវបានបញ្ចូលទៅក្នុងគន្លងអាជីពដោយស្វ័យប្រវត្តិ។

## ២.៣ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ក្រសួងបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងបានធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធ កម្មវិធី និងអនុកម្មវិធី ក៏ដូចជាការបង្កើនការទទួលខុសត្រូវរបស់អង្គភាពអនុវត្ត ការធ្វើបច្ចុប្បន្នកម្ម ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា និងការពង្រឹងការគ្រប់គ្រងមូលនិធិដំណើរការ សាលារៀន ព្រមទាំងការរៀបចំរបាយការណ៍សមិទ្ធកម្ម ផងដែរ។

## ២.៤ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

ក្រសួងក៏បានពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅក្នុងវិស័យអប់រំ ទាំងប្រព័ន្ធគ្រប់គ្រង ព័ត៌មាននៅថ្នាក់ជាតិ និងនៅតាមសាលារៀន ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការរៀបចំ ផែនការ ការពិនិត្យតាមដាន ការវាយតម្លៃ និងរបាយការណ៍។ មកទល់ពេលនេះ ក្រសួងមានប្រព័ន្ធព័ត៌មានច្រើនដូចជា EMIS, FMIS, HRMIS, SIS, Sala Digital ។ល។ ដែលក្រសួងមានទិសដៅរៀបចំកែលម្អប្រព័ន្ធព័ត៌មានទាំងនេះឱ្យបានល្អ និងធ្វើសុខដុមនីយកម្មជាមួយគ្នាទាំងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការងារគ្រប់គ្រងសាលារៀនជាទូទៅ ដើម្បីធានាសុក្រឹតភាពទិន្នន័យ ការវិភាគទិន្នន័យ និងការប្រើប្រាស់ទិន្នន័យសម្រាប់ការសម្រេចចិត្តផ្នែក គោលនយោបាយ ដើម្បីងាយស្រួលក្នុងការកំណត់សាលារៀនអាទិភាព ដែលត្រូវផ្តល់ការគាំទ្រពីក្រសួង ឬពីគម្រោងនានា និងដើម្បីដោះស្រាយបញ្ហាប្រឈមរបស់សាលារៀន។

## ២.៥ កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

ក្រសួងបានធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដែលផ្តោតលើៈ ១).ការកែលម្អកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូ ២.)ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេសខាងផ្នែកខ្លឹមសារមេរៀន គរុកោសល្យ និងវិធីសាស្ត្របង្រៀនសម្បូរបែប និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន ៣).ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ និងសម្ភារឧបទេស

ទំនើបសម្បូរបែប ៤).ការអភិវឌ្ឍភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ៥).ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ និង ៦).ការធានាគុណភាពនៃការបណ្តុះបណ្តាល។ ក្នុងពេលខាងមុខ ក្រសួងនឹង៖

១. បន្តអនុវត្តកំណែទម្រង់សាលាគរុកោសល្យ តាមរយៈ (i) បង្កើនគុណវុឌ្ឍិ ១២+៤ ឬ បរិញ្ញាបត្រ+១សម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ និងបរិញ្ញា+២ សម្រាប់ គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ (ii) កែលម្អការបណ្តុះបណ្តាលគ្រូ ដើម្បីបំពេញតាម «ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន» និង (iii) ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
២. ឈានឆ្ពោះទៅអនុវត្តអាជ្ញាប័ណ្ណគ្រូបង្រៀន(គ្រូបង្រៀនកិច្ចសន្យាពិសេស) សម្រាប់សាលារៀននៅជនបទ និងជួបការលំបាក ដោយប្រើប្រាស់គុណវុឌ្ឍិដូចគ្នា
៣. អនុវត្តវិធីសាស្ត្របង្រៀនថ្មីសម្រាប់មធ្យមសិក្សាស្របទៅនឹងកម្មវិធីវាយតម្លៃ PISA ជាពិសេសផ្តោតលើចំណេះដឹង និងបំណិនសតវត្សរ៍ទី២១ ដូចដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មី និងអនុវត្តអំណានដំបូង និងគណិតវិទ្យាដំបូង នៅកម្រិតបឋមសិក្សា
៤. ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្របង្រៀន វិធីសាស្ត្ររៀន និងវិធីសាស្ត្រវាយតម្លៃថ្មី ដែល អាចអនុញ្ញាតឱ្យសិស្សអភិវឌ្ឍបំណិននៃការគិតប្រកបដោយការត្រិះរិះពិចារណា និងដោះស្រាយបញ្ហាដែលទាក់ទងនឹងជីវិតប្រចាំថ្ងៃ
៥. លើកកម្ពស់ការអប់រំឌីជីថល និងវេទិកាសិក្សាអេឡិចត្រូនិក ដើម្បីចែករំលែកឧត្តមានុវត្តន៍ដល់គ្រូបង្រៀន
៦. ការផ្តល់ឋានៈដល់គ្រូឧទ្ទេស។

## ២.៦ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្រសួងបាន ១).លើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំរបស់ក្រុមការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង ២).ត្រួតពិនិត្យ និងគាំទ្រដល់ការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ៣).កែសម្រួលរចនាសម្ព័ន្ធតួនាទីមុខងាររបស់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ៤).ផ្សព្វផ្សាយអនុក្រឹត្យលេខ ២១៣ ដល់ថ្នាក់ដឹកនាំបច្ចេកទេស ៥).បើកវគ្គបណ្តុះបណ្តាលស្តីពី គោលការណ៍ បែបបទ និងនីតិវិធីអនុវត្តមុខងារអប់រំ យុវជន និងកីឡា ជូនដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ៦).ពង្រឹងនីតិវិធីក្នុងការតែងតាំងនាយក នាយករងសាលារៀនដោយថ្នាក់ក្រោមជាតិនិង៧)ពង្រឹងការត្រួតពិនិត្យដើម្បីធានាថាថ្នាក់ក្រោមជាតិអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួង។

# ៣. ទស្សនវិស័យសម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤

អនុសាសន៍សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១០ចំណុច សំខាន់ៗក្នុងពិធីបិទសន្និបាតអប់រំរួមមាន៖

១. បន្តពង្រឹងអភិបាលកិច្ចសាលារៀន និងអភិវឌ្ឍប្រព័ន្ធអប់រំឱ្យកាន់តែរឹងមាំ, មានភាពបុរេសកម្ម, ទំនើបកម្ម និងឆ្លើយតបទៅនឹងបរិការណ៍ជាតិ និងអន្តរជាតិ ដែលបាននិងកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័ស តាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូ និងការធានាបាននូវសេវាអប់រំ ដែលមានប្រសិទ្ធភាព និងគុណភាពប្រកបដោយសមធម៌ បរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
២. បន្តពិនិត្យកែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់អ្នកសិក្សា ដូចជាចាប់ផ្តើមអនុវត្តការសិក្សាពេញមួយថ្ងៃ, និងកែលម្អសៀវភៅសិក្សាគោល ដើម្បីឱ្យស្របគ្នាជាមួយបណ្តាប្រទេសជឿនលឿន
៣. ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្របង្រៀន វិធីសាស្ត្ររៀន និងវិធីសាស្ត្រវាយតម្លៃថ្មី ដែលអាចអនុញ្ញាតឱ្យសិស្សអភិវឌ្ឍបំណិននៃការគិតប្រកបដោយការត្រិះរិះពិចារណា ដោះស្រាយបញ្ហាដែលទាក់ទងនឹងជីវិតប្រចាំថ្ងៃ និងអនុវត្តចំណេះដឹងវិទ្យាសាស្ត្រក្នុងជីវិតប្រចាំថ្ងៃ
៤. បន្តកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយត្រូវពង្រឹងគុណវុឌ្ឍិគ្រូបង្រៀនចេញថ្មី និងធ្វើវិក្រឹតការគ្រូបង្រៀន កែលម្អការបណ្តុះបណ្តាលគ្រូ ដើម្បីបំពេញតាម «ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន» និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

៥. បន្តអភិវឌ្ឍការអប់រំឌីជីថល ដោយត្រូវបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត បំពាក់បន្ទប់ពិសោធន៍ឌីជីថល ភ្ជាប់បណ្តាញអគ្គិសនី និងអ៊ីនធើណិតនៅតាមគ្រឹះស្ថានសិក្សា លើកកម្ពស់គុណវុឌ្ឍិ និងសមត្ថភាពឌីជីថលដល់គ្រូបង្រៀន បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងការបង្រៀននិងរៀន កែលម្អមាតិកាឌីជីថល និងបង្កើតមជ្ឈមណ្ឌលអប់រំឌីជីថល និងផ្សព្វផ្សាយវេទិកាឌីជីថលឱ្យកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ

៦. បន្តលើកកម្ពស់សុខភាពអនាម័យនៅតាមគ្រឹះស្ថានសិក្សា ត្រៀមវិធានការឆ្លើយតបនិងចូលរួមទប់ស្កាត់ភ្លាមៗ និងបង្កើនការអប់រំអំពីសុវត្ថិភាពសុខភាពសិក្សា សុវត្ថិភាពចំណីអាហារ កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព ដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា បរិស្ថានសាលារៀនបៃតង សាលារៀនស្អាតគ្មានសំរាម និងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ

៧. ជំរុញភាពជាដៃគូសាធារណៈនិងសហគមន៍ក្នុងការអប់រំ ដោយចាប់ផ្តើមអនុវត្តនៅតាមសាលារៀនគំរូ និងរៀបចំសេចក្តីណែនាំអនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សា ក្នុងគោលដៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួម ដូចជាការបង្កើតមូលនិធិសមធម៌ ដើម្បីប្រើប្រាស់ថវិកាបដិភាគដោយស្ម័គ្រចិត្តពីមាតាបិតាសិស្ស សម្រាប់គាំទ្រដល់ការបន្ថែមមុខវិជ្ជាថ្មីៗ ការបង្កើតទំនាក់ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស និងការអប់រំមាតាបិតាឱ្យផ្តល់តម្លៃបន្ថែមទៀតដល់ការអប់រំ និងលើកទឹកចិត្តពួកគាត់ឱ្យចូលរួមជាមួយការសិក្សារបស់កូនកាន់តែច្រើន

៨. បន្តអភិវឌ្ឍកុមារ និងយុវជន ឱ្យមានស្មារតីទទួលខុសត្រូវ មានជំនឿលើសមត្ថភាពរបស់ខ្លួន និងប្រកាន់ខ្ជាប់នូវទង្វើវិជ្ជមានក្នុងសង្គម មានសីលធម៌ និងការរស់នៅក្នុងភាពជាពលរដ្ឋល្អ តាមរយៈការបំផុសចលនា «កូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ» កម្មវិធីយុវជនស្ម័គ្រចិត្ត និងការលើកទឹកចិត្តឱ្យយុវជនចុះជួយដល់មូលដ្ឋាននៅតាមសហគមន៍ ព្រមទាំងបន្តបណ្តុះបណ្តាលជំនាញបច្ចេកទេស និងជំនាញទន់ដល់យុវជន សំដៅឆ្លើយតបបានទៅនឹងឱកាសការងារ និងភាពរឹងមាំនៃកោសិកាសង្គម

៩. បន្តលើកកម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និងសុខុមាលភាពល្អ កាយសម្បទាមាំមួន ធន្ទះមោះមុត អំណត់ព្យាយាម មានវិន័យ មានស្មារតីក្រុម គំនិតច្នៃប្រឌិត និងមានការតស៊ូស្វិតស្វាញ។ ជាមួយនេះ ពង្រឹងការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា ពង្រឹងយន្តការដែលមានស្រាប់រួមទាំងសហព័ន្ធកីឡា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា ការបណ្តុះបណ្តាលធនធានមនុស្ស និងការលើកទឹកចិត្ត ដែលជាកត្តាចម្បងក្នុងការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការត្រៀមខ្លួនរបស់អត្តពលិក, និងការពង្រឹងគុណភាពនៃការប្រកួតគ្រប់កម្រិត

១០. បន្តការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ, ការកសាងគោលនយោបាយ និងផែនការអប់រំ, និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ និងគ្រូបង្រៀនឱ្យបានពេញលេញ និងមានភាពរស់រវើកនិងប្រទាក់ក្រឡាគ្នាដើម្បី ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ទន្ទឹមនឹងនោះ ក្រសួងអប់រំ យុវជន និងកីឡាក៏បានដាក់ចេញនូវអាទិភាពចំនួន ១៥ ដើម្បីឆ្លើយតបទៅនឹងវិធានការគន្លឹះទាំង ៤ របស់**សម្តេចធិបតី**, ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៣-២០២៨, បរិវត្តកម្មឌីជីថលនៃវិស័យអប់រំ និងការអនុវត្តស្តង់ដាសាលារៀនគំរូ សម្រាប់អនុវត្តនៅក្នុងឆ្នាំសិក្សា២០២៣-២០២៤ និងឆ្នាំសិក្សាបន្តបន្ទាប់ មានដូចខាងក្រោម៖

**១. ការពង្រឹងអភិបាលកិច្ច និងកំណែទម្រង់សាលារៀន៖** អភិបាលកិច្ចសាលារៀនត្រូវបានពង្រឹង ដោយឈរលើកត្តាគន្លឹះចំនួន៣ គឺ៖ លទ្ធផលសិក្សារបស់សិស្ស ការដឹកនាំនិងគ្រប់គ្រង និងការចូលរួមរបស់មាតាបិតា និងសហគមន៍។ ដើម្បីធ្វើកំណែទម្រង់សាលារៀន អ្នកដឹកនាំ និងគ្រប់គ្រងត្រូវ៖

### ១. ការពង្រឹងវិន័យ និងអប់រំសិស្សឱ្យស្រឡាញ់សាលារៀន៖

- **កម្រិតបឋមសិក្សា៖** ត្រូវរៀបចំឯកសណ្ឋាន និងសម្លៀកបំពាក់ស្អាត ការអប់រំណែនាំសិស្សនៅពេលគោរពទង់ជាតិ ដោយបង្ហាត់អំពីការតម្រង់ជួរ របៀបរបប ការហាត់កីឡា ការយកចិត្តទុកដាក់អំពីសុខភាពនិងសុខមាលភាពរបស់

សិស្ស ការបណ្ដុះមនសិការស្នេហាជាតិ ការធ្វើសមាធិ ការលេងភ្លេង ការបង្កើតក្រុមប្រឹក្សាកុមារ និងយុវជន ការផ្ដល់រង្វាន់ និងការអនុវត្តទណ្ឌកម្មតាមបែបវិជ្ជមាន

- **កម្រិតមធ្យមសិក្សា៖** ត្រូវរៀបចំបរិស្ថានសិក្សាដែលគាំទ្រដល់ការសិក្សា ការផ្ដល់ប្រឹក្សាអាជីព ការជួយដោះស្រាយបញ្ហាសិស្ស កម្មវិធីមិត្តអប់រំមិត្ត ការរៀបចំពិព័រណ៍ស្នាដៃសិស្ស ដើម្បីលើកទឹកចិត្តដល់ការសិក្សា និងស្វ័យសិក្សា ការបណ្ដុះបំណិនសតវត្សរ៍ទី២១ និងការផ្ដល់ឱកាសដល់សិស្សក្នុងការប្រកួតប្រជែងដើម្បីបញ្ចេញស្នាដៃ។

**២. ការងារជាមួយមាតាបិតា៖** នាយកសាលាត្រូវធ្វើការងារជាមួយមាតាបិតា ដើម្បីផ្ដល់ការគាំទ្របន្ថែមដល់សិស្សដូចជា ការរៀបចំកម្មវិធីបំប៉ន ទស្សនកិច្ចសិក្សា ការប្រជុំជាប្រចាំ ការបង្កើតប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតា ជាពិសេសនៅពេលសិស្សអវត្តមាន និងការផ្សព្វផ្សាយលទ្ធផលសិក្សា។

**៣. ការងារជាមួយគ្រូបង្រៀន៖** សាលារៀនត្រូវការពារផលប្រយោជន៍របស់គ្រូ យកចិត្តទុកដាក់ដល់សុខទុក្ខរបស់បុគ្គលិក ការរៀបចំយន្តការស្វ័យគ្រប់គ្រង ការផ្ដល់ការគាំទ្រដល់គ្រូបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យា បន្ទប់ពិសោធន៍ ការផ្ដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការបង្កើនគុណវុឌ្ឍិ ការស្រាវជ្រាវប្រតិបត្តិដើម្បីកែលម្អវិធីសាស្ត្របង្រៀន និងការលើកទឹកចិត្តតាមគ្រប់រូបភាព។

**៤. ការពង្រឹងការដឹកនាំ និងគ្រប់គ្រង៖** សាលារៀនត្រូវបង្កើត៖

- គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រប់គ្រងថ្នាក់រៀន ការរៀបចំផែនការកែលម្អសាលារៀន ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ
- ការបែងចែកតួនាទី ភារកិច្ចដល់គណៈគ្រប់គ្រងតាមគោលការណ៍ស្វ័យភាព និងការចុះកិច្ចសន្យាការងាររវាងគណៈគ្រប់គ្រងសាលារៀនជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន
- ការបង្កើនភាពជាម្ចាស់ និងគណនេយ្យភាព
- ការបណ្ដុះស្មារតី ពង្រឹងសមត្ថភាពខ្លួនឯងជាប្រចាំ
- ការគ្រប់គ្រងប្រកបដោយតម្លាភាព
- ការរៀបចំបរិស្ថានសាលារៀនស្អាត
- ការបង្កើតបណ្ណាល័យស្តង់ដា និងមានផាសុខភាពសម្រាប់ការអាន។

**២. ការពង្រឹងវិន័យ សីលធម៌ និងឥរិយាបថសិស្ស៖** ការលើកកម្ពស់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់សិស្ស ជាពិសេសការអភិវឌ្ឍផ្នែកស្មារតី រាងកាយ សុខភាព វិន័យ សីលធម៌ ចំណេះដឹង បំណិន និងឥរិយាបថល្អ។ សាលារៀនត្រូវ៖

- **ការអប់រំសិស្ស៖** បណ្ដុះស្មារតីសិស្សឱ្យមករៀនទាន់ពេលវេលា
  - ការបណ្ដុះទម្លាប់ល្អដល់កុមារ (ភាពស្អាតនៃរាងកាយ ការស្លៀកពាក់ របៀបហូបអាហារ ការប្រើប្រាស់សម្ភារៈសិក្សា ការចូលបន្ទប់ទឹក ការលាងសម្អាតដៃ របៀបសំពះ សុភាពរាបសារ សេចក្ដីក្លាហានក្នុងការនិយាយ និងទំនាក់ទំនង ជាដើម)
  - ការយល់ដឹងពីសិល្បៈ តន្ត្រី វប្បធម៌ និងបរិស្ថានជុំវិញ រួមទាំងការធ្វើសមាធិដើម្បីយល់ហេតុផល ការអប់រំតាមបែបវិជ្ជមាន ការលើកទឹកចិត្តចំពោះឥរិយាបថល្អ និងមានសេចក្ដីក្លាហានក្នុងការទាក់ទងរវាងកុមារនិងកុមារ រវាងកុមារនិងរៀមច្បង ឬចាស់ព្រឹទ្ធាចារ្យ មាតាបិតា លោកគ្រូ អ្នកគ្រូ
  - ការបង្កើតកម្មវិធីក្រៅម៉ោងសិក្សា ដើម្បីលើកកម្ពស់ការចូលរួមរបស់ព្រះសង្ឃក្នុងការលើកកម្ពស់សីលធម៌ និងចរិយាធម៌របស់សិស្ស។
- **ការងារជាមួយគ្រូបង្រៀន៖**
  - ពង្រឹងសីលធម៌ និងឥរិយាបថរបស់គ្រូឱ្យទៅជាគំរូដល់សិស្ស
  - ការអភិវឌ្ឍវិធីសាស្ត្របង្រៀន របៀបនៃការសិក្សារៀនសូត្ររបស់សិស្ស
  - ការយល់ដឹងអំពីភាសាទំនាក់ទំនង បរិស្ថានសិក្សាទាំងក្នុងបរិវេណ និងបរិស្ថានជុំវិញសាលារៀន។

- **បរិស្ថានសិក្សា៖**
  - បង្កើតបរិស្ថានសាលារៀនស្អាត
  - ការលើកកម្ពស់អនាម័យ និងបរិស្ថានបៃតង
  - ការអនុវត្តសកម្មភាពបន្ថែមទាំងក្នុងថ្នាក់ និងក្រៅថ្នាក់
  - ការអប់រំសុខភាពសិក្សាដើម្បីបណ្តុះទម្លាប់ល្អ វិន័យ សីលធម៌ និងឥរិយាបថ។

៣. **ការលើកកម្ពស់អាហារូបត្ថម្ភតាមសាលារៀន៖** កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានដោះស្រាយបញ្ហាអសន្តិសុខស្បៀងក្នុងចំណោមសិស្សដោយធានាថាសិស្សអាចទទួលបានអាហារមួយពេលទៀងទាត់ និងមានជីវជាតិ។ ឧត្តមានុវត្តន៍នៃកម្មវិធីនេះគឺ៖

- **ការអប់រំប្រកបដោយសមធម៌៖**
  - ការលើកកម្ពស់សុវត្ថិភាពស្បៀង អាហារូបត្ថម្ភ និងអនាម័យ ទឹកស្អាត
  - ការលូតលាស់ខួរក្បាល និងរាងកាយ
  - ការផ្លាស់ប្តូរទម្លាប់របស់សិស្សឱ្យបរិភោគអាហារមានតុល្យភាពសុខភាព និងសុខមាលភាពរបស់សិស្ស ភាពឆ្លាតវៃ វិន័យ សាមគ្គីភាព ភាពក្លាហាន និងសីលធម៌
  - ការបណ្តុះទម្លាប់ល្អ ការមករៀនទាន់ពេល ការធ្វើការជាក្រុម
- **ការផ្តល់សន្តិសុខសង្គម៖** កាត់បន្ថយចំណាយរបស់មាតាបិតាលើការបរិភោគអាហារបានមួយពេល និងជួយបង្កើនជីវភាពគ្រួសារ
- **ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន៖** យុទ្ធនាការទិញស្បៀងតាមសហគមន៍បានជំរុញឱ្យកសិករតាមសហគមន៍ខិតខំដាំដំណាំតាមតម្រូវការក្នុងកម្រិតខ្នាតតូច និងបានបង្កើតទីផ្សារសម្រាប់កសិករក្នុងសហគមន៍ ការលើកកម្ពស់ការដាំដុះបន្លែ ការចិញ្ចឹមសត្វ និងការបង្កើតប្រភពចំណូលដល់កសិករ ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការគាំទ្រដល់វិស័យកសិកម្មក្នុងស្រុក និងពង្រឹងខ្សែសង្វាក់ផ្គត់ផ្គង់តាមមូលដ្ឋាន។ សាលារៀនមួយចំនួនបានជំរុញឱ្យមានការដាំដំណាំក្នុងសាលារៀន ដើម្បីអាចរកប្រាក់ចំណូលពីកម្មវិធីនេះផងដែរ។ កត្តាជានាដោគជ័យដល់ការអនុវត្តកម្មវិធីអាហារូបត្ថម្ភតាមសាលារៀន រួមមាន៖
- **ការផ្លាស់ប្តូរពីកម្មវិធីអាហារពេលព្រឹកបែបបុរាណ ទៅជាកម្មវិធីអាហារពេលព្រឹកដោយប្រើប្រាស់កសិផលក្នុង សហគមន៍តាមរយៈ ៖**
  - ផ្សព្វផ្សាយ និងកៀរគរសហគមន៍ឱ្យចូលរួមវិភាគទានបន្ថែមដល់ចុងភៅ និងទិញសម្ភារផ្ទះបាយ
  - សាលារៀនត្រូវរៀបចំទីតាំងឱ្យបានល្អ
  - សហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីផ្សព្វផ្សាយ និងហាមឃាត់ការលក់អាហារគ្មានសុវត្ថិភាពនៅក្បែរបរិវេណសាលារៀន
  - សហការជាមួយអាជ្ញាធរ ដៃគូអភិវឌ្ឍ និងសហគមន៍ ឱ្យជួយផ្តល់គ្រាប់ពូជដំណាំ និងបច្ចេកទេស ឬរបៀបនៃការដាំដុះដំណាំ
- ការយកចិត្តទុកដាក់ក្នុងការអនុវត្តកម្មវិធីអាហារតាមសាលារៀន ពីគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូដោយមានយន្តការអនុវត្តច្បាស់លាស់ និងអ្នកពាក់ព័ន្ធបានបំពេញតួនាទី និងភារកិច្ចប្រកបដោយការទទួលខុសត្រូវ
- សហគមន៍ចូលរួម និងគាំទ្រទាំងពេលវេលា សម្ភារៈ និងថវិកា តាមរយៈការផ្គត់ផ្គង់បន្លែ ត្រី សាច់ និងគ្រឿងទេស។

៤. **ការជំរុញការចូលរួមរបស់សហគមន៍តាមរយៈមូលនិធិសមធម៌៖** ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់គុណភាពអប់រំមានច្រើនរូបភាព។ ដើម្បីធានាបានភាពជោគជ័យ សាលារៀនត្រូវអនុវត្តដូចខាងក្រោម៖

- បង្កឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធសហការគ្នា ក្នុងការជួយសិស្សឱ្យចេះរៀន និងជួយកែលម្អបរិស្ថានថ្នាក់រៀន និងសាលារៀន
- លើកទឹកចិត្តឱ្យសិស្ស គ្រូបង្រៀន និងមាតាបិតាឱ្យរួមគ្នាកំណត់កិច្ចការត្រូវធ្វើ ក្នុងការជួយសិស្ស និងសាលារៀន
- លើកទឹកចិត្តគ្រប់ភាគីពាក់ព័ន្ធក្នុងការជួយគ្រូបង្រៀនឱ្យមានទឹកចិត្តបង្រៀន និងគ្រប់គ្រងសិស្សឱ្យអាចរៀនបានកាន់តែប្រសើរ ឆ្លើយតបនឹងតម្រូវការរបស់សហគមន៍
- ប្រជុំផ្សព្វផ្សាយ និងកៀរគរធនធានតាមសហគមន៍
- បង្កើតគណៈកម្មការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ។

**៥. ការបង្រៀននិងរៀនពេញមួយថ្ងៃ៖** គោលការណ៍ណែនាំស្ដីពី ការរៀនពេញមួយថ្ងៃនឹងត្រូវដាក់ចេញឱ្យអនុវត្តនៅតាមសាលារៀនដែលមានសក្ដានុពលទាំងលទ្ធភាព អគារសិក្សា បន្ទប់រៀន និងគ្រូបង្រៀន ក្នុងគោលបំណង៖

- សិស្សមានទំនុកចិត្តចំពោះសាលារៀនដែលមានសក្ដានុពល ក្នុងការទទួលបាន ការអប់រំប្រកបដោយគុណភាព
- ការលើកកម្ពស់គុណភាពអប់រំ និងការបង្កើតឱកាសសិក្សាវែងឆ្ងាយ ព្រមទាំងការបង្ការមិនឱ្យសិស្សយកពេលទៅប្រព្រឹត្តអំពើអបាយមុខផ្សេងៗ
- សាលារៀនមានការរីកចម្រើនខាងផ្នែកកែលម្អបរិស្ថាន ការអនុវត្តកម្មវិធីសិក្សាបានគ្រប់ជ្រុងជ្រោយ ការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ ជាពិសេស ការលើកកម្ពស់អំណាន និងការរៀបចំសកម្មភាពក្រៅម៉ោងសិក្សា ដូចជាសិល្បៈ តន្ត្រី វប្បធម៌ គេហវិជ្ជា បណ្ណាល័យ ការអប់រំសីលធម៌ វិន័យ និងសម្មាធិ
- ការប្រើប្រាស់ធនធានសម្ភារៈរបស់សាលារៀន និងម៉ោងសិក្សាឱ្យអស់លទ្ធភាព
- ការកៀរគរសហគមន៍ឱ្យចូលរួមគាំទ្រ និងវិនិយោគលើវិស័យអប់រំចាប់ពីកម្រិតបឋមសិក្សា
- មាតាបិតាមានឱកាសពេញលេញក្នុងការប្រកបរបរចិញ្ចឹមជីវិត។

ដើម្បីពង្រឹងគុណភាពនៅកម្រិតបឋមសិក្សា ក្រសួងនឹងរៀបចំកែទម្រង់កម្មវិធីសិក្សាពីការរៀនមួយពេលទៅការរៀននិងបង្រៀនពេញមួយថ្ងៃ រៀបចំក្រុមធានាគុណភាពផ្ទៃក្នុង រៀបចំបុគ្គលិកសិក្សាឱ្យសមស្របតាមសមត្ថភាពជំនាញ រៀបចំកម្មវិធីសិក្សាផ្ដោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ចាត់ចែងនិងគ្រប់គ្រងសៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ រៀបចំបន្ទប់រៀននិងថ្នាក់រៀនជាបណ្ដើរៗឱ្យមានបច្ចេកវិទ្យា បង្កើនការបង្រៀនភាសាបរទេស និងរៀបចំបរិស្ថានសាលារៀនទាំងមូលឱ្យក្លាយជាទីមេត្រី។ ឧត្តមានុវត្តន៍នៃការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ មានដូចជា៖

- ការបង្រៀននិងរៀនពេញមួយថ្ងៃតាមកម្មវិធីសិក្សាទំនើប ដោយបង្កើនម៉ោងសិក្សា ពង្រីកការអនុវត្តកម្មវិធីសិក្សានិងមុខវិជ្ជាសិក្សា លើកកម្ពស់ការអប់រំឌីជីថល ការបង្រៀនភាសាបរទេស និងការអប់រំស្នែម ភាសាជាតិ ភាសាបរទេស កុំព្យូទ័រ រ៉ូបូទិក ។ល។
- មុនពេលចាប់ផ្ដើមដំណើរការរៀនពេញមួយថ្ងៃ សាលារៀនត្រូវសិក្សាពីការចំណាយរបស់សិស្ស អគារសិក្សា ទីតាំងភូមិសាស្ត្រ ជំនួបជាមួយគ្រូ និងជំនួបជាមួយមាតាបិតា
- ការកំណត់មុខសញ្ញាចំណាយដូចជា បុគ្គលិក រដ្ឋបាលសាលារៀន ការអភិវឌ្ឍសាលារៀន និងសន្សំទុក
- ការប្រជុំពិភាក្សារវាងគណៈកម្មការគ្រប់គ្រងសាលារៀនជាមួយគ្រូបង្រៀន ជាមួយមាតាបិតា និងអ្នកពាក់ព័ន្ធ ដើម្បីពន្យល់អំពីដំណើរការ និងលទ្ធផលរំពឹងទុក និងមានការឯកភាពគ្នា។

**៦. ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ៖** ក្រសួងបាននិងកំពុងបន្តអភិវឌ្ឍ និងជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ទែមនៃការអប់រំ ដើម្បីកសាងមូលធនមនុស្សសម្រាប់សេដ្ឋកិច្ចឌីជីថល តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំនៅសាលារៀនជំនាន់ថ្មី។ ដើម្បីជំរុញការប្រើប្រាស់ឌីជីថល ក្រសួងនឹងបន្ត៖
- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាប្រចាំលើវិធីសាស្ត្របង្រៀន និងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការបង្រៀន
- បំពាក់សម្ភារបរិក្ខារបម្រើឱ្យការអប់រំឌីជីថលនៅទីចាត់ការ បន្ទប់រៀន បណ្ណាល័យ និងបន្ទប់កុំព្យូទ័រ

- លើកទឹកចិត្តសិស្ស និងគ្រូបង្រៀន ឱ្យចូលរួមដោយមិនគិតពីកត្តាបរាជ័យ
- សហការជាមួយក្រសួង និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធើណិត ដើម្បីភ្ជាប់សេវាដល់សាលារៀន
- សហការជាមួយក្រសួងមានសមត្ថកិច្ចក្នុងការបិទការផ្សព្វផ្សាយកម្មវិធីផ្សេងៗ ដែលរំខានសិស្សនៅលើឧបករណ៍ឌីជីថលរបស់ពួកគេ។

**៧. ការអនុវត្តកម្មវិធីសិក្សាបន្ថែមក្រៅម៉ោងសិក្សា៖** បណ្តុះនូវបំណិនសម្បទាបន្ថែមដល់សិស្សមានដូចជាការបណ្តុះជំនាញបន្ថែម ភាពច្នៃប្រឌិត ការធ្វើការជាក្រុម ទំនាក់ទំនង មានចរិយាធម៌ ការទទួលស្គាល់ស្នាដៃ ស្មារតីលះបង់ភាពជាគំរូរបស់យុវជន ភាពជាអ្នកដឹកនាំ ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីព ការផ្តល់ប្រឹក្សាកម្មវិធីជំនាញស្វែម អំណានក្នុងបណ្ណាល័យ សិល្បៈ កសិកម្ម អប់រំកាយកីឡា និងវប្បធម៌។ ដើម្បីអនុវត្តកម្មវិធីក្រៅម៉ោងសិក្សាសាលារៀនត្រូវ៖

- បង្កើតគណៈកម្មការគ្រប់គ្រងការអនុវត្តកម្មវិធី
- ជួបជាមួយអ្នកអាណាព្យាបាលសិស្ស
- ស្វែងរក និងទាក់ទងអង្គភាព ឬអង្គការដៃគូ សហគ្រិនភាព ឬ សាលាបច្ចេកទេស ដើម្បីជួយគាំទ្រដល់ការអនុវត្ត
- បង្កើតរចនាសម្ព័ន្ធគ្រូប្រឹក្សាអាជីព និងជ្រើសរើសគ្រូអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា
- ផ្សព្វផ្សាយព័ត៌មានដល់សិស្ស និងអ្នកអាណាព្យាបាលនៅកម្មវិធីក្រៅម៉ោងសិក្សា
- ជ្រើសរើសសិស្សតាមកម្មវិធីដែលពួកគេពេញចិត្ត។

**៨. សាលារៀនស្អាតក្នុងក្របខណ្ឌយុទ្ធនាការសាលារៀនគ្មានសំរាម៖** គឺជាការលើកកម្ពស់សុខភាពអនាម័យរបស់អ្នកអប់រំនិងអ្នកសិក្សា ការចូលរួមថែរក្សាបរិស្ថានសាលារៀន សហគមន៍ឱ្យមានភាពបៃតង តាមរយៈការអប់រំអំពីការទុកដាក់សំរាម ការញែកសំរាម ការកែច្នៃសំរាមឡើងវិញ ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងការបណ្តុះស្មារតីឱ្យស្រឡាញ់បរិស្ថាន ដើម្បីធានាឱ្យបាននូវសិស្សស្អាត ថ្នាក់រៀនស្អាត គ្រូបង្រៀនស្អាត សាលារៀនស្អាត និងសហគមន៍ស្អាត។ ដើម្បីធ្វើឱ្យសាលារៀនស្អាតគ្មានសំរាម គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកពាក់ព័ន្ធ ត្រូវអនុវត្តវិធានការ ៤គឺ៖

- **ចក្ខុវិស័យ និងការប្តេជ្ញាចិត្ត៖** គណៈគ្រប់គ្រង និងបុគ្គលិកត្រូវមានការប្តេជ្ញាចិត្តខ្ពស់ មានស្មារតីការងារជាក្រុម ភាពជាម្ចាស់ និងចក្ខុវិស័យ ដើម្បីកែលម្អសាលារៀនស្របតាមស្តង់ដាសាលាកុមារមេត្រី សាលាមេត្រីបរិស្ថាន និងសូចនាករស្តង់ដាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ
- **ការចូលរួម៖** ព្រះសង្ឃ គ្រូបង្រៀន សិស្ស មាតាបិតា សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវចូលរួមគាំទ្រគ្រប់រូបភាព
- **ភាពជាអ្នកដឹកនាំ៖** សមត្ថភាពក្នុងការកៀរគរធនធាន ការបង្កើតជំនឿទុកចិត្ត ការគ្រប់គ្រងប្រកបដោយតម្លាភាព
- **ការបង្កើតយន្តការគ្រប់គ្រង៖** ការចូលរួមរបស់ក្រុមប្រឹក្សាកុមារ និងបុគ្គលិក កសាង និងការថែទាំបរិស្ថានសិក្សា។

**៩. មជ្ឈមណ្ឌលឧត្តមភាពនៅឧត្តមសិក្សា៖** ដើម្បីឆ្លើយតបនឹងយុគសម័យថ្មីនៃឧស្សាហកម្ម៤.០ ក្រសួងបានបន្តអនុវត្តកំណែទម្រង់ឧត្តមសិក្សា ស្របតាមយុទ្ធសាស្ត្រ បញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលអាណត្តិទី៧ ជាពិសេសមុំទី១ ការអភិវឌ្ឍមូលធនមនុស្ស និងមុំទី៥ ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល។ កំណែទម្រង់ឧត្តមសិក្សាផ្តោតលើ៖

- **ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព៖** វិនិយោគលើគ្រឹះស្ថានឧត្តមសិក្សាដែលមានសក្តានុពល ដូចជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារសិក្សា អន្តេវាសិកដ្ឋាន មន្ទីរពិសោធន៍ កសិដ្ឋាន មជ្ឈមណ្ឌលឌីជីថល។
- **ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន៖**
    - ជានាស្វ័យភាព គណនេយ្យភាព ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថល ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធអភិបាលកិច្ច និងការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា
    - ការកសាងផែនការយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវ
    - ការបញ្ចូលអ្នកមានសញ្ញាបត្រថ្នាក់បណ្ឌិតក្នុងក្របខណ្ឌមន្ត្រីរាជការ
    - ការបង្កើតកម្មវិធីថ្នាក់ក្រោយបណ្ឌិត ការសិក្សាលើជំនាញពាក់ព័ន្ធនឹងការងារទាំងរយៈពេលខ្លី និងវែង

- ការរៀបចំប្រព័ន្ធវាយតម្លៃការបំពេញការងារផ្អែកលើសមិទ្ធកម្ម។

- **ការធ្វើទំនើបកម្មកម្មវិធីសិក្សា និងការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន៖**
  - ធ្វើទំនើបកម្ម និងការអភិវឌ្ឍកម្មវិធីសិក្សាដោយផ្អែកលើលទ្ធផល (OBE) រួមទាំងការផ្តល់សិទ្ធិដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការកែសម្រួល និងការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការបញ្ចូលមុខវិជ្ជាថ្មីៗ និងការបង្កើតកម្មវិធីសិក្សាជំនាញថ្មី
  - ការបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សា
  - ការវាយតម្លៃទទួលស្គាល់គុណភាពកម្មវិធីសិក្សា និងការរៀននិងបង្រៀន តាមរយៈប្រព័ន្ធឌីជីថល ការបង្កើតប្រព័ន្ធផ្ទេរក្រេឌីតការសិក្សា (Credit Transfer) ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា
  - ការផ្សារភ្ជាប់សាកលវិទ្យាល័យជាមួយកម្មវិធីអគារវៃឆ្លាត និងទីក្រុងវៃឆ្លាត ដោយសហការជាមួយក្រុមហ៊ុនក្នុង និងក្រៅប្រទេស។

- **វិធានការលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន៖**
  - បង្កើនគុណវុឌ្ឍិសាស្ត្រាចារ្យដោយផ្តល់អាហារូបករណ៍ ដើម្បីបង្កើនគុណវុឌ្ឍិគ្រូថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត
  - អនុវត្តវិធីសាស្រ្តបង្រៀនទំនើប ដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១ តាមរយៈការសិក្សាបែបត្រឡប់ ការបង្រៀនតាមបែបសិក្សាគម្រោង (អនុវត្តផ្ទាល់ក្នុងមន្ទីរពិសោធន៍ កសិដ្ឋាន ឬជាក្រុម) ការសិក្សាបែបពិសោធន៍ ការសិក្សាបែបអនុវត្តផ្ទាល់ តាមរយៈម៉ូដែល Fab-lab ការបង្រៀនភាសាបរទេស បំណិនសហគ្រិនភាព បំណិនបច្ចេកវិទ្យា និងបំណិនឌីជីថល
  - ការគាំទ្រដល់និស្សិត ដូចជាការសិក្សាគម្រោង ការស្រាវជ្រាវ ការពិសោធន៍ ការចុះកម្មសិក្សា និងការចល័តនិស្សិតជាមួយសាកលវិទ្យាល័យអន្តរជាតិ ស្ថាប័នដៃគូ សហគ្រាសឯកជន និងឧស្សាហកម្ម និងការបង្កើតក្លឹបសិក្សា ស្វ័យសិក្សា និងការជួយនិស្សិតរៀនយឺត។

- **ការពង្រឹងអន្តរជាតិភាវូបនីយកម្ម៖**
  - បង្កើតកម្មវិធីសិក្សាអន្តរជាតិរួមមាន កម្មវិធីសិក្សាទ្វេ/ភ្លោះ និងកម្មវិធីសិក្សារួមគ្នា ជាពិសេសសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត តាមរយៈការសហការជាមួយសាកលវិទ្យាល័យដៃគូនៅក្នុង និងក្រៅប្រទេស និងក្រុមហ៊ុនឧស្សាហកម្ម
  - ការផ្លាស់ប្តូរគ្រូបង្រៀន អ្នកស្រាវជ្រាវ និងនិស្សិត
  - ការអនុវត្តគម្រោងស្រាវជ្រាវរួមគ្នា ការអញ្ជើញសាស្ត្រាចារ្យ និងអ្នកជំនាញពីបរទេសមកជួយបង្រៀនមុខវិជ្ជាថ្មីៗ។

- **ការពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅឧត្តមសិក្សា៖**
  - ការលើកកម្ពស់ការស្រាវជ្រាវ និងបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវជាតិ និងអន្តរជាតិ
  - ការពង្រឹងសមត្ថភាព គ្រប់គ្រងការស្រាវជ្រាវ
  - ការផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវនិងការបង្កើតប្រាក់ចំណូល
  - ការវាយតម្លៃស្នាដៃស្រាវជ្រាវដើម្បីផ្តល់ឋានៈសាស្ត្រាចារ្យ
  - ការរៀបចំវេទិកាផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ
  - ការបង្កើតមូលនិធិស្រាវជ្រាវជាតិ
  - ការបង្កើតសង្គមវិទ្យាសាស្ត្រ (Professional Scientific Society) ដើម្បីចែករំលែកបទពិសោធ

- ការបង្កើតភាពជាដៃគូរវាងសាកលវិទ្យាល័យ និងសាកលវិទ្យាល័យ (Consortium Universities) សាកលវិទ្យាល័យនិងក្រុមហ៊ុនឧស្សាហកម្មឯកជន (University-Industry Linkage) សាកលវិទ្យាល័យ និងសហគមន៍ (University-Community Partnership)។

– **ការបង្កើនចំនួននិស្សិតចូលរៀន និងបរិយាបន្ន៖**
  - ការអនុវត្តកម្មវិធីភាពជាដៃគូ ការអប់រំស្វែមតាមគំរូភាពជាដៃគូរវាងមធ្យមសិក្សា និងឧត្តមសិក្សា
  - ការផ្តល់អាហារូបករណ៍ដល់និស្សិតក្រីក្រ និងមានពិការភាព
  - ការផ្តល់ថវិកាគាំទ្រនិស្សិតចូលរៀននៅឧត្តមសិក្សា។

**១០.ការអភិវឌ្ឍឧត្តមសិក្សាក្នុងបរិបទបច្ចេកវិទ្យាឌីជីថល៖** ការអប់រំឌីជីថលនៅកម្រិតឧត្តមសិក្សាបានធានា៖ ១). ភាពសម្បូរបែបនៃធនធាន សម្រាប់ការរៀននិងបង្រៀន ២). ភាពងាយស្រួលនៃទំនាក់ទំនង កិច្ចសហការ និងការចូលរួម ៣). ភាពបត់បែននៃកាលវិភាគ និងការរៀនតាមលក្ខណៈបុគ្គល ៤). ការអភិវឌ្ឍការអប់រំឌីជីថល ៥). ការលើកកម្ពស់ជំនាញឌីជីថល ៦). ការបង្កើនការស្រាវជ្រាវ និងការច្នៃប្រឌិត និង ៧). ការគាំទ្រការអប់រំពេញមួយជីវិត។ ដើម្បីគាំទ្រដល់ការអប់រំឌីជីថលនៅកម្រិតឧត្តមសិក្សា ក្រសួងបាននិងកំពុង៖

– អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា
– ការធានាគុណភាព និងស្តង់ដា
– ការបត់បែន ទៅតាមការផ្លាស់ប្តូរបច្ចេកវិទ្យា
– ការធានាសុវត្ថិភាពទិន្នន័យឯកជនភាព
– ការពង្រឹង ភាពជាដៃគូជាមួយក្រុមហ៊ុន
– ការបន្តការអភិវឌ្ឍវិជ្ជាជីវៈ
– ការអភិវឌ្ឍបណ្តាញសាកលវិទ្យាល័យសាយប៊ឺរ (Cyber University Network) ដែលមានគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនសម្រាប់ការអនុវត្តការបង្រៀននិងរៀន តាមអនឡាញ។

**១១. ការអប់រំបរិយាបន្ននៅកម្ពុជា៖** ជាយុទ្ធសាស្ត្រមួយដើម្បីលើកកម្ពស់គុណភាពអប់រំ សំដៅការផ្តល់ឱ្យមនុស្សគ្រប់រូបទទួលបានឱកាសស្មើៗគ្នា ដោយមិនគិតពីភេទ អាយុ ពណ៌សម្បុរ ជាតិសាសន៍ ជនជាតិដើមភាគតិច ភាសា សាសនា និន្នាការនយោបាយ ឬពិការភាព ជាពិសេសជនងាយរងគ្រោះ។ ដើម្បីធានាបាននូវការផ្តល់សេវាអប់រំ ពិសេសប្រកបដោយគុណភាព ក្រសួងបាន៖

– **ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស និងនាយកដ្ឋានអប់រំពិសេស៖** ការរៀបចំគោលនយោបាយស្តីពីការអប់រំកុមារមានពិការភាព គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ឯកសារជំនួយស្មារតីសម្រាប់គ្រូបង្រៀនវិទ្យាល័យអប់រំពិសេស ឯកសារជំនួយសម្រាប់ការកំណត់អត្តសញ្ញាណកុមារមានពិការភាពក្រោមអាយុ ៥ឆ្នាំ និងសម្របសម្រួលកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។
– **ការបន្តវិនិយោគលើវិទ្យាល័យអប់រំពិសេសចំនួន ៦៖** ដើម្បីអនុវត្តកម្មវិធីអប់រំដល់កុមារមានពិការភាពនៅទូទាំងប្រទេស រួមទាំងកុមារខ្សោយសតិបញ្ញានិងអូទីស្សឹម និងការអនុវត្តកម្មវិធីសមាហរណកម្ម ដោយកុមារត្រូវរៀននៅគ្រឹះស្ថានសិក្សារដ្ឋពាក់កណ្តាលថ្ងៃ និងនៅសាលាអប់រំពិសេសពាក់កណ្តាលថ្ងៃទៀត។
– **ការផ្តល់ប្រាក់ឧបត្ថម្ភពិសេស៖** ចំនួន ៨ សែនរៀលលើបៀវត្សគ្រូបង្រៀន ដែលកើនឡើងជាលំដាប់ ដើម្បីថែរក្សាអ្នកឯកទេសខាងផ្នែកអប់រំពិសេស។
– **ការបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** សហការជាមួយអង្គការគ្លេសាប៊្មីក្នុងការធ្វើសវនកម្មគុណភាពប្រចាំឆ្នាំ និងសហការជាមួយដៃគូអន្តរជាតិក្នុងការពិនិត្យត្រចៀក និងការគាំទ្របច្ចេកទេស។

ក្រសួងបានផ្ដល់ការអប់រំពហុភាសានៅកម្រិតមត្តេយ្យសិក្សា និងបីឆ្នាំដំបូងនៃបឋមសិក្សាសម្រាប់កុមារជនជាតិភាគតិច នៅក្នុងខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ ដោយសហការជាមួយអង្គការយូនីសេហ្វ និង CARE៖

- **ការប្រើប្រាស់គំរូស្ពានចម្លង៖** រៀនពីភាសាជនជាតិភាគតិច (ភាសាព្នង កាវ៉ែត គ្រឹង ទំពួន ព្រៅ និងចារ៉ាយ) ដើម្បីឱ្យពួកគេអាចរៀនជាភាសាជាតិទាំងស្រុងនៅថ្នាក់ទី៤
- **ផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា៖** កម្ពុជាជាប្រទេសតែមួយគត់នៅតំបន់អាស៊ីអាគ្នេយ៍ដែលលើកកម្ពស់ការអប់រំពហុភាសា តាមរយៈការកំណត់គោលការណ៍ស្ដីពីការអនុវត្តកម្មវិធីអប់រំពីរភាសា ការរៀបចំឯកសារបណ្ដុះបណ្ដាលគ្រូអប់រំពហុភាសា ឯកសារបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សាអប់រំពហុភាសាជាដើម
- **ការបញ្ចូលសាលាសហគមន៍ចូលជាគ្រឹះស្ថានសិក្សារដ្ឋ៖** ផ្ដល់ថវិកាដំណើរការសាលារៀន និងបញ្ចូលគ្រូជនជាតិដើមភាគតិចចំនួន ៥០នាក់ ចូលក្នុងក្របខណ្ឌរដ្ឋ ដើម្បីធានាថា កុមារជនជាតិដើមភាគតិចទទួលការអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិត ដើម្បីក្លាយជាមូលធនមនុស្ស។

**១២. មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត៖** ជាផ្នែកមួយដ៏សំខាន់សម្រាប់រួមចំណែកអភិវឌ្ឍធនធានមនុស្សនៅក្នុងសហគមន៍ឱ្យមានការរីកចម្រើនទាំងផ្នែកបញ្ញាស្មារតី ចំណេះដឹងថ្មី បំណិនថ្មី រួមទាំងការផ្ដល់ជាគំនិតច្នៃប្រឌិត ការបង្កើតថ្មី ការគិតអ្វីដែលងាយ និងមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ ការកាត់បន្ថយភាពក្រីក្រ ការជួយបង្កើតការងារ ការស្វែងរកការងារជូនអ្នកសិក្សាក្រោយរៀនចប់ជំនាញ។ ដើម្បីជំរុញមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យដំណើរការល្អ និងប្រែក្លាយជាមជ្ឈមណ្ឌលអប់រំពេញមួយជីវិត ទាមទារនូវកត្តាជាច្រើនរួមមាន៖

- **ការបំពេញបន្ថែមលើកម្មវិធីសិក្សាសាលារដ្ឋ៖** ស្របតាមតម្រូវការជាក់ស្ដែងរបស់យុវជន និងសិស្ស ដូចជាកម្មវិធីបណ្ដុះបណ្ដាលភាសាបរទេស បច្ចេកវិទ្យា ព័ត៌មានវិទ្យា ការបណ្ដុះបណ្ដាលជំនាញ និងការបើកវគ្គខ្លីៗសម្រាប់យុវជន និងសិស្សចំណេះទូទៅ ព្រមទាំងមានវិធីសាស្ត្រទាក់ទាញសិស្សឱ្យមករៀន
- **ការផ្សារភ្ជាប់កម្មវិធីបណ្ដុះបណ្ដាលជាមួយតម្រូវការជាក់ស្ដែងក្នុងសហគមន៍៖** ការសិក្សាតម្រូវការទីផ្សារ ការបណ្ដុះបណ្ដាលជំនាញកសិកម្ម និងការរៀបចំកម្មវិធីប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ដូចជាវគ្គខ្លីៗខាងផ្នែកគរុកោសល្យ សិប្បកម្មដែក ការផលិតវីដេអូ ការបណ្ដុះបំណិនរកប្រាក់ចំណូលជាដើម
- **ការចូលរួមនិងការសហការ៖** ការបង្កើតគណៈកម្មការគ្រប់គ្រងដែលសកម្ម និងមានមនសិការខ្ពស់ ដោយមានការចូលរួមពីយុវជនស្ម័គ្រចិត្ត និងការគាំទ្រពីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងអង្គការដៃគូ ដូចជាអង្គការ DVVI ព្រមទាំងធ្វើការអភិវឌ្ឍសមត្ថភាពគណៈកម្មការគ្រប់គ្រងឱ្យមានសមត្ថភាពពេញលេញទាំងជំនាញទន់ និងជំនាញរឹង
- **ការធានានិរន្តរភាព៖** តាមរយៈការផ្ដល់ថវិការដ្ឋ ការបង្កើតសកម្មភាពរកចំណូល ដើម្បីទ្រទ្រង់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ការកៀរគរធនធានពីប្រភពផ្សេងៗ និងការលើកទឹកចិត្តដល់បុគ្គលិក។

**១៣. ក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា និងការផ្លាស់ប្ដូរ ឥរិយាបថជាវិជ្ជមាន៖** គោលបំណងរបស់ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារគឺ ដើម្បីប្រមូលផ្ដុំយុវជន និងកុមារគ្រប់រូបនៅក្នុងសាលារៀន ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ សាសនា ភេទ វណ្ណៈ ពិការភាព ឱ្យក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ មានភាពក្លាហាន មានសាមគ្គីភាព ចេះរស់នៅជាមួយគ្នាប្រកបដោយគុណធម៌ សីលធម៌ សុជីវធម៌ និងមានគំនិត ស្នេហាជាតិមាតុភូមិ។ ដើម្បីធានាបាននូវការគ្រប់គ្រងសាលារៀន និងការរៀននិងការបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារត្រូវចូលរួមលើកកម្ពស់៖

- **ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា៖** ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ កម្មវិធីមិត្តអប់រំមិត្ត យុទ្ធនាការលើកកម្ពស់ការយល់ដឹងពីសុខភាពបន្តពូជ និងការប្រយុទ្ធប្រឆាំងការប្រើប្រាស់សារធាតុញៀន
- **ការងារស្ម័គ្រចិត្ត៖** លើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារសង្គម ហាត់ការ និងការបណ្ដុះបំណិនបច្ចេកទេស
- **ការបង្កើតក្លឹបសិក្សា៖** ការលើកកម្ពស់ស្វ័យសិក្សា និងការសិក្សារៀនសូត្រក្រៅម៉ោងសិក្សា

- **ការបណ្តុះបំណិនសតវត្សទី២១៖** ការចូលរួមក្នុងការប្រឡងប្រណាំង និងកម្មវិធីយុវជន ដើម្បីបង្កើនចំណេះដឹង បំណិនជីវិត បំណិនឌីជីថល បំណិនត្រិះរិះពិចារណា ការធ្វើការជាក្រុម និងបង្កើតទម្លាប់និងឥរិយាបថល្អ ដែលមានភាពចាំបាច់សម្រាប់យុវជននៅក្នុងសង្គមបច្ចុប្បន្ន។

**១៤. ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា៖** ការអប់រំកាយ និងកីឡាជាសមាសភាគមួយនៃវិស័យអប់រំ ដែលជាមធ្យោបាយហាត់ពត់ រាងកាយ និងបញ្ញាស្មារតីរបស់មនុស្សឱ្យមានការលូតលាស់ល្អ កម្លាំងមាំមួន និងមានសុខភាព ល្អ។ ប្រការនេះជួយកសាងធនធានមនុស្សឱ្យក្លាយជាពលរដ្ឋល្អ រួមចំណែកកសាង និងការពារជាតិមាតុភូមិ។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តកម្មវិធីអប់រំកាយ និងកីឡាក្នុងម៉ោងសិក្សា (២ម៉ោងក្នុងមួយសប្តាហ៍) នៅសាលាចំនួន ២៧៨៦, រៀបចំប្រកួតកីឡាសិស្សនៅកម្រិតរាជធានី ខេត្ត និងការប្រកួតកីឡាជ្រើសរើសជើងឯកសិស្សបឋមសិក្សា និង មធ្យមសិក្សាទូទាំងប្រទេសប្រចាំឆ្នាំ។

តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តអនុវត្តៈ

- **កម្មវិធីក្រៅម៉ោងសិក្សា៖** ដាក់បញ្ចូលការអនុវត្តកម្មវិធីអប់រំកាយ និងកីឡា ទៅក្នុងកម្មវិធីកីឡាក្រៅម៉ោងសិក្សា និងការអប់រំសិស្សឱ្យយល់ពីសារៈសំខាន់នៃកីឡា ក្នុងការលើកកម្ពស់សុខភាព និងជីវភាពរស់នៅ
- **ការរៀបចំកម្មវិធីសិក្សាថ្មី និងការលើកកម្ពស់គុណវុឌ្ឍិគ្រូកីឡា៖** ការរៀបចំកម្មវិធីសិក្សាទំនើប ដោយសហការជាមួយអង្គការ Hearts of Gold និងការបណ្តុះបណ្តាលគ្រូកីឡា តាមរូបមន្តបរិញ្ញាបត្រ ឬ ១២+៤
- **ការផ្សារភ្ជាប់៖** ការអប់រំកាយជាមួយនឹងកីឡាតាមគ្រឹះស្ថានសិក្សា និងកីឡាកម្រិតខ្ពស់ (ការលេងបាល់គ្រប់ប្រភេទ ការបង្កើតក្លឹបកីឡា)
- **ការរៀបចំការប្រកួត៖** លើកទឹកចិត្តឱ្យសហព័ន្ធកីឡារៀបចំការប្រកួតកីឡា ដើម្បីជ្រើសរើសកីឡាករមានសក្តានុពលឱ្យចូលក្នុងក្រុមកីឡាករថ្នាល និងកីឡាករជម្រើសជាតិ។

**១៥ .ការលើកកម្ពស់សុខភាពសិក្សានៅតាមសាលារៀន៖** ចំណុចគន្លឹះមួយក្នុងចំណោមអាទិភាពទាំងបួនរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈ៖

- **ការលើកកម្ពស់សុខភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំ៖** ការរៀបចំបន្ទប់សុខភាព ការផ្តល់សេវាពិនិត្យសុខភាព និងការផ្តល់ថ្នាំបង្ការ។ ការរៀបចំបន្ទប់សុខភាពសិក្សាគ្រប់ជ្រុងជ្រោយមុនគេនៅសាលាបឋមសិក្សាចតុមុខ និងសាលារៀនជាច្រើនទៀតបានយកបទពិសោធនេះទៅអនុវត្តនៅសាលារៀនរបស់ខ្លួនជាបន្តបន្ទាប់។ នៅឆ្នាំ ២០២២ ក្រសួងទទួលបានពានរង្វាន់ «ទិវាពិភពលោកគ្មានថ្នាំជក់» ពីអង្គការសុខភាពពិភពលោក (WHO)
- **ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ៖** បរិក្ខារលាងសម្អាតដៃ បង្គន់អនាម័យ និងការគ្រប់គ្រងកាកសំណល់។ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាល បានសាងសង់បង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃចំនួន ២,៦៩៣ នៅតាមសាលារៀនអស់ថវិកា ៩លានដុល្លារ និងសាងសង់ដោយសហគមន៍។ គ្រឹះស្ថានសិក្សារដ្ឋ ១០០% មានបង្គន់អនាម័យ
- **ការលើកកម្ពស់អាហារូបត្ថម្ភ និងគុណភាពចំណីអាហារ៖** កម្មវិធីផ្តល់អាហារតាមសាលារៀន ការលើកកម្ពស់មីក្រូសារជាតិក្នុងចំណីអាហារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន
- **ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងមេត្រីភាព៖** អនាម័យ បរិស្ថានស្អាត សួនផ្កា និងទីលានសម្រាប់អនុវត្តការអប់រំកាយ និងកីឡា
- **ការលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា៖** ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ និងការបំពាក់ឧបករណ៍បង្ការការពារ

- **ការលើកកម្ពស់ការអប់រំសុខភាព៖** ការអនុវត្តកម្មវិធីសិក្សា២ ម៉ោងក្នុង ១ សប្តាហ៍ ការរៀបចំសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងការបណ្តុះបណ្តាលគ្រូមុខវិជ្ជាអប់រំសុខភាព
- **ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា៖** ក្រសួងបានសហការជាមួយក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ព្រមទាំងដៃគូអភិវឌ្ឍផ្សេងទៀតដោយរៀបចំជាគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅនៅឆ្នាំ២០២២។ គោលការណ៍នេះមាន ៩ស្តង់ដាស្របតាមយុទ្ធសាស្ត្រទាំង៩ នៃគោលនយោបាយជាតិស្តីពីសុខភាពសិក្សារួមមាន ២៦សូចនាករ និង ៥៧សូចនាកររង។

## ៥. សេចក្តីសន្និដ្ឋាន

សន្និបាតអប់រំ យុវជន និងកីឡាឆ្នាំ២០២៤ បានបញ្ជាក់ពីភាពជោគជ័យក្នុងការសម្រេចបាននូវផែនការសកម្មភាពស្របទៅតាមគោលដៅដែលបានកំណត់នៅឆ្នាំ២០២៣ និងផ្តល់នូវអនុសាសន៍ល្អៗជាច្រើនសម្រាប់អនុវត្តនៅឆ្នាំសិក្សាបន្ទាប់ទៀត។

## ៦. ឧបសម្ព័ន្ធ

១. តារាងផែនការសកម្មភាពអាទិភាពសម្រាប់អនុវត្តឆ្នាំ២០២៤ និងឆ្នាំបន្តបន្ទាប់

២. សុន្ទរកថា៖

- សុន្ទរកថាបើកសន្និបាតដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សុន្ទរកថាស្វាគមន៍និងរបាយការណ៍បូកសរុបសន្និបាតអប់រំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សុន្ទរកថា និងប្រសាសន៍សំណេះសំណាលរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ឧបសម្ព័ន្ធទី១៖ វិធានការគន្លឹះឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាសម្រាប់អនុវត្តឆ្នាំសិក្សា២០២៣-២០២៤ និងឆ្នាំបន្តបន្ទាប់ បន្ថែមលើទិសដៅដែលបានកំណត់ក្នុងរបាយការណ៍សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០២២-២០២៣ និងទិសដៅការងារឆ្នាំសិក្សា២០២៣-២០២៤

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| **១. អនុសាសន៍សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១០ ចំណុចក្នុងពិធីបិទ** | | |
| 1. បន្តពង្រឹងអភិបាលកិច្ចសាលារៀន និងអភិវឌ្ឍប្រព័ន្ធអប់រំឱ្យកាន់តែរឹងមាំ, មានភាពបុរេសកម្ម, ទំនើបកម្ម និងឆ្លើយតបទៅនឹងបរិការណ៍ជាតិ និងអន្តរជាតិ ដែលបាននិងកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័ស តាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូ និងការធានាបាននូវការសេវាអប់រំ ដែលមានប្រសិទ្ធភាព និងគុណភាពប្រកបដោយសមធម៌ បរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | ២០២៤-២៨ | អគអរ, អគរហ, អគយវ នាយកដ្ឋានពាក់ព័ន្ធ |
| 2. បន្តពិនិត្យកែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់អ្នកសិក្សា ដូចជាចាប់ផ្តើមអនុវត្តការសិក្សាពេញមួយថ្ងៃ, និងកែលម្អសៀវភៅសិក្សាគោល ដើម្បីឱ្យស្របគ្នាជាមួយបណ្តាប្រទេសជឿនលឿន | ២០២៤-២៨ | អគអរ, អគរហ, អគយវ, នា. អកស នា.អកត, នា.បស, នា.មចទ |
| 3. ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្របង្រៀន វិធីសាស្ត្ររៀន និងវិធីសាស្ត្រវាយតម្លៃថ្មី ដែលអាចអនុញ្ញាតឱ្យសិស្សអភិវឌ្ឍបំណិននៃការគិត ប្រកបដោយការត្រិះរិះពិចារណា ដោះស្រាយបញ្ហាដែលទាក់ទងនឹងជីវិតប្រចាំថ្ងៃ, និងអនុវត្តចំណេះដឹងវិទ្យាសាស្ត្រក្នុងជីវិតប្រចាំថ្ងៃ | ២០២៤-២៨ | អគអរ, អគរហ នា. អកស, នា.បស នា.មចទ, នា.តវជ, នា.ធគអ |
| 4. បន្តកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយត្រូវពង្រឹងគុណវុឌ្ឍិគ្រូបង្រៀន ចេញថ្មី និងធ្វើវិក្រឹតការគ្រូបង្រៀន, កែលម្អការបណ្តុះបណ្តាលគ្រូដើម្បីបំពេញតាម "ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន" និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ២០២៤-២៨ | អគអរ, អគរហ, នា. បវ, នា.បល |
| 5. បន្តអភិវឌ្ឍការអប់រំឌីជីថល ដោយត្រូវបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត, បំពាក់បន្ទប់ពិសោធន៍ឌីជីថល, ភ្ជាប់បណ្តាញអគ្គិសនី និងអ៊ីនធើណិតនៅតាមគ្រឹះស្ថានសិក្សា, លើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពឌីជីថលដល់គ្រូបង្រៀន, បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងការបង្រៀននិងរៀន, កែលម្អមាតិកាឌីជីថល និងបង្កើតមជ្ឈមណ្ឌលអប់រំឌីជីថល និងផ្សព្វផ្សាយវេទិកាឌីជីថលឱ្យកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ | ២០២៤-២៨ | អគអរ, អគរហ, អគឧស, នា.បវព, នា.បវ |
| 6. បន្តលើកកម្ពស់សុខភាពអនាម័យនៅតាមគ្រឹះស្ថានសិក្សា ត្រៀមវិធានការឆ្លើយតប និងចូលរួមទប់ស្កាត់ភ្លាមៗ និងបង្កើនការអប់រំអំពីសុវត្ថិភាពសុខភាពសិក្សា, សុវត្ថិភាពចំណីអាហារ, កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព ដូចជារៀបចំបន្ទប់សុខភាពស្តង់ដា, បរិស្ថានសាលារៀនបៃតង, សាលារៀនស្អាតគ្មានសំរាម, និងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ | ២០២៤-២៨ | អគអរ, អគរហ នា.សស,នា.សណ |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| 7. ជំរុញភាពជាដៃគូសាធារណៈនិងសហគមន៍ក្នុងការអប់រំ ដោយចាប់ផ្តើមអនុវត្តនៅតាមសាលារៀនគំរូ និងរៀបចំសេចក្តីណែនាំអនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សា ក្នុងគោលដៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួម ដូចជាការបង្កើតមូលនិធិសមធម៌ ដើម្បីប្រើប្រាស់ថវិកាបដិភាគដោយស្ម័គ្រចិត្តពីមាតាបិតាសិស្សសម្រាប់គាំទ្រដល់ការបន្ថែមមុខវិជ្ជាថ្មីៗ, ការបង្កើតទំនាក់ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀនដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស, និងការអប់រំមាតាបិតាឱ្យផ្តល់តម្លៃបន្ថែមទៀតដល់ការអប់រំ និងលើកទឹកចិត្តពួកគាត់ឱ្យចូលរួមជាមួយការសិក្សារបស់កូនកាន់តែច្រើន | ២០២៤-២៨ | អគអរ៖ នា. អកត, នា.បស, នា.មចទ |
| 8. បន្តអភិវឌ្ឍកុមារ និងយុវជនឱ្យមានស្មារតីទទួលខុសត្រូវ មានជំនឿលើសមត្ថភាពរបស់ខ្លួន និងប្រកាន់ខ្ជាប់នូវទង្វើវិជ្ជមានក្នុងសង្គម មានសីលធម៌ និងការរស់នៅក្នុងភាពជាពលរដ្ឋល្អ តាមរយៈការបំផុសចលនា «កូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ» កម្មវិធីយុវជនស្ម័គ្រចិត្ត, និងការលើកទឹកចិត្តឱ្យយុវជនចុះជួយដល់មូលដ្ឋាននៅតាមសហគមន៍, ព្រមទាំងបន្តបណ្តុះបណ្តាលជំនាញបច្ចេកទេស និងជំនាញទន់ដល់យុវជន សំដៅឆ្លើយតបបានទៅនឹងឱកាសការងារ និងភាពរឹងមាំនៃកោសិកាសង្គម | ២០២៤-២៨ | អគយវ៖ នា. យវ, នា. គម, នា. សក |
| 9. បន្តលើកកម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និងសុខុមាលភាពល្អ, កាយសម្បទាមាំមួន, ឆន្ទៈមោះមុត, អំណត់ព្យាយាម, មានវិន័យ, មានស្មារតីក្រុម, គំនិតច្នៃប្រឌិត, និងមានការតស៊ូស្វិតស្វាញ។ ជាមួយនេះ ពង្រឹងការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា, ពង្រឹងយន្តការ ដែលមានស្រាប់រួមទាំងសហព័ន្ធកីឡា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា ការបណ្តុះបណ្តាលធនធានមនុស្ស និងការលើកទឹកចិត្តដែលជាកត្តាចម្បងក្នុងការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការត្រៀមខ្លួនរបស់អត្តពលិក, និងការពង្រឹងគុណភាពនៃការប្រកួតគ្រប់កម្រិត | ២០២៤-២៨ | អគកឡ, នា. អកឡ នា. អកសន, ម.ជហក, វ.អក, នា.វពកឡ, ម.ជពសក |
| 10. បន្តការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ, ការកសាងគោលនយោបាយ និងផែនការអប់រំ, និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ និងគ្រូបង្រៀនឱ្យបានពេញលេញ និងមានភាពរស់រវើកនិងប្រទាក់ក្រឡាគ្នា ដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ | ២០២៤-២៨ | អគបផ, អគហេ, អគអរ, នា.ផក, នា.គប, នា.បល, នា. ហវ, នា.បវ |
| **២. សន្និបាតអប់រំក៏បានដាក់ចេញនូវអាទិភាពចំនួន ១៥ ដើម្បីឆ្លើយតបនឹងអនុសាសន៍សម្តេចធិបតី** | | |
| **១.ការពង្រឹងអភិបាលកិច្ច និងកំណែទម្រង់សាលារៀន៖** | | អគអរ, មន្ទីរអយក |
| (១) ការពង្រឹងវិន័យ និងអប់រំសិស្សឱ្យស្រឡាញ់សាលារៀន៖<br>- **កម្រិតបឋមសិក្សា៖** ត្រូវរៀបចំឯកសណ្ឋាន និងសម្លៀកបំពាក់ស្អាត ការអប់រំ ណែនាំសិស្សនៅពេលគោរពទង់ជាតិ ដោយបង្ហាត់អំពីការតម្រង់ជួររបៀបរបប ការហាត់កីឡា ការយកចិត្តទុកដាក់អំពីសុខភាពនិងសុខមាលភាពរបស់សិស្ស ការបណ្តុះមនសិកាស្នេហាជាតិ ការធ្វើសមាធិ ការលេងភ្លេង ការបង្កើតក្រុមប្រឹក្សាកុមារ និងយុវជន ការផ្តល់រង្វាន់ និងការអនុវត្តទណ្ឌកម្មតាមបែបវិជ្ជមាន | ២០២៤-២៥ | អគអរ, នា.បស, សាលារៀន |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| - **កម្រិតមធ្យមសិក្សា៖** ត្រូវរៀបចំបរិស្ថានសិក្សាដែលគាំទ្រដល់ការសិក្សា ការផ្តល់ប្រឹក្សាអាជីព ការជួយដោះស្រាយបញ្ហាសិស្ស កម្មវិធីមិត្តអប់រំមិត្ត ការរៀបចំ ពិព័រណ៍ស្នាដៃ សិស្សដើម្បីលើកទឹកចិត្តដល់ការសិក្សា និងស្វ័យសិក្សា ការបណ្តុះបំណិនសតវត្សទី២១ និងការផ្តល់ឱកាសដល់សិស្សក្នុងការប្រកួតប្រជែងដើម្បីបញ្ចេញស្នាដៃ | ២០២៤-២៥ | អគអវ, នា.មចទ, សាលារៀន |
| (២) ការងារជាមួយមាតាបិតា៖ នាយកសាលាត្រូវធ្វើការងារជាមួយមាតាបិតា ដើម្បីផ្តល់ ការគាំទ្របន្ថែមដល់សិស្សដូចជា ការរៀបចំកម្មវិធីបំប៉ន ទស្សនកិច្ចសិក្សា ការប្រជុំជាប្រចាំ ការបង្កើតប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតាជាពិសេសនៅពេលសិស្សអវត្តមាន និងការផ្សព្វផ្សាយលទ្ធផលសិក្សា | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មចទ, សាលារៀន |
| (៣) ការងារជាមួយគ្រូបង្រៀន៖ សាលារៀនត្រូវការពារផលប្រយោជន៍របស់គ្រូ យកចិត្តទុកដាក់ដល់សុខទុក្ខរបស់បុគ្គលិក ការរៀបចំយន្តការស្វ័យគ្រប់គ្រង ការផ្តល់ការគាំទ្រដល់គ្រូបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យា បន្ទប់ពិសោធន៍ ការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំ ការបង្កើនគុណវុឌ្ឍិ ការស្រាវជ្រាវប្រតិបត្តិដើម្បីកែលម្អវិធីសាស្ត្របង្រៀន និងការផ្តល់ការលើកទឹកចិត្តតាមគ្រប់រូបភាព | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មចទ, នា.បវ, សាលារៀន |
| (៤) ការពង្រឹងការដឹកនាំ និងគ្រប់គ្រង៖ សាលារៀនត្រូវបង្កើត<br>- គណៈកម្មការ គ្រប់គ្រងសាលារៀន និងគ្រប់គ្រងថ្នាក់រៀន ការរៀបចំផែនការកែលម្អសាលារៀន ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ<br>- ការបែងចែកតួនាទី ភារកិច្ចដល់គណៈគ្រប់គ្រង តាមគោលការណ៍ស្វ័យភាព និងការចុះកិច្ចសន្យាការងាររវាងគណៈគ្រប់គ្រងសាលារៀន ជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន<br>- ការបង្កើនភាពជាម្ចាស់ និងគណនេយ្យភាព<br>- ការបណ្តុះស្មារតី ពង្រឹងសមត្ថភាពខ្លួនឯងជាប្រចាំ<br>- ការគ្រប់គ្រងប្រកបដោយតម្លាភាព<br>- ការរៀបចំបរិស្ថានសាលារៀនស្អាត<br>- ការបង្កើតបណ្ណាល័យស្តង់ដា និងមានផាសុខភាពសម្រាប់ការអាន | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មចទ, សាលារៀន |
| **២.ការពង្រឹងវិន័យ សីលធម៌ និងឥរិយាបថសិស្ស៖** | | អគអវ, មន្ទីរអេយក |
| (១) ការអប់រំសិស្ស៖<br>- បណ្តុះស្មារតីសិស្សឱ្យមករៀនទាន់ពេលវេលា<br>- ការបណ្តុះទម្លាប់ល្អដល់កុមារ ភាពស្អាតនៃរាងកាយ ការស្លៀកពាក់ របៀបហូបអាហារ ការប្រើប្រាស់សម្ភារៈសិក្សា ការចូលបន្ទប់ទឹក ការលាង) (សម្អាតដៃ របៀបសំពះ សុភាពរាបសារ សេចក្តីក្លាហានក្នុងការនិយាយ និងទំនាក់ទំនង ជាដើម | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មចទ, សាលារៀន |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| - ការយល់ដឹងពីសិល្បៈ តន្ត្រី វប្បធម៌ និងបរិស្ថានជុំវិញ រួមទាំងការធ្វើសមាធិដើម្បីយល់ហេតុផល ការអប់រំតាមបែបវិជ្ជមាន ការលើកទឹកចិត្តចំពោះឥរិយាបថល្អ និងមានសេចក្ដីក្លាហានក្នុងការទាក់ទងរវាងកុមារនិងកុមារ រវាងកុមារនិង រៀមច្បងឬចាស់ព្រឹទ្ធាចារ្យ មាតាបិតា លោកគ្រូ អ្នកគ្រូ<br>- ការបង្កើតកម្មវិធីក្រៅម៉ោងសិក្សា ដើម្បីលើកកម្ពស់ការចូលរួមរបស់ព្រះសង្ឃក្នុងការលើកកម្ពស់សីលធម៌ និងចរិយាធម៌របស់ សិស្ស។ | | |
| (២) ការងារជាមួយគ្រូបង្រៀន៖<br>- ពង្រឹងសីលធម៌ និងឥរិយាបថរបស់គ្រូឱ្យទៅជាគំរូដល់សិស្ស<br>- ការអភិវឌ្ឍវិធីសាស្ត្របង្រៀន របៀបនៃការសិក្សារៀនសូត្ររបស់សិស្ស<br>- ការយល់ដឹងអំពីភាសាទំនាក់ទំនង បរិស្ថានសិក្សាទាំងក្នុងបរិវេណ និងបរិស្ថានជុំវិញសាលារៀន | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, នា.បវ, សាលារៀន |
| (៣) បរិស្ថានសិក្សា៖<br>- បង្កើតបរិស្ថានសាលារៀនស្អាត<br>- ការលើកកម្ពស់អនាម័យ និងបរិស្ថានបៃតង<br>- ការអនុវត្តសកម្មភាពបន្ថែមទាំងក្នុងថ្នាក់ និងក្រៅថ្នាក់<br>- ការអប់រំសុខភាពសិក្សាដើម្បីបណ្ដុះទម្លាប់ល្អ វិន័យ សីលធម៌ និងឥរិយាបថ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, នា.បវ, សាលារៀន |
| **៣.ការលើកកម្ពស់អាហារូបត្ថម្ភតាមសាលារៀន៖** | | អគអរ, មន្ទីរអយក |
| (១) ការផ្លាស់ប្ដូរពីកម្មវិធីអាហារពេលបែបបុរាណ ទៅជាកម្មវិធីអាហារពេលព្រឹកដោយ ប្រើប្រាស់កសិផលក្នុងសហគមន៍តាមរយៈ<br>- ផ្សព្វផ្សាយ និងកៀរគរសហគមន៍ឱ្យចូលរួមវិភាគទានបន្ថែមដល់ចុងភៅ និងទិញសម្ភារ ផ្ទះបាយ<br>- សាលារៀនត្រូវរៀបចំទីតាំងឱ្យបានល្អ<br>- សហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីផ្សព្វផ្សាយ និងហាមឃាត់ការលក់ អាហារគ្មានសុវត្ថិភាពនៅក្បែរបរិវេណសាលារៀន<br>- សហការជាមួយអាជ្ញាធរ ដៃគូអភិវឌ្ឍ និងសហគមន៍ ឱ្យជួយផ្ដល់គ្រាប់ពូជដំណាំ និងបច្ចេកទេស ឬរបៀបនៃការដាំដុះដំណាំ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, នា. សស, សាលារៀន |
| (២) ការយកចិត្តទុកដាក់ក្នុងការអនុវត្តកម្មវិធីអាហារតាមសាលារៀន ពីគណៈគ្រប់គ្រង សាលារៀន លោកគ្រូ អ្នកគ្រូ ដោយមានយន្តការអនុវត្តច្បាស់លាស់ និងអ្នក ពាក់ព័ន្ធបានបំពេញតួនាទី និងភារកិច្ចប្រកបដោយការទទួលខុសត្រូវ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, នា.សស, សាលារៀន |
| (៣) សហគមន៍ចូលរួម និងគាំទ្រទាំងពេលវេលា សម្ភារៈ និងថវិកា តាមរយៈការផ្គត់ផ្គង់បន្លែ ត្រី សាច់ និងគ្រឿងទេស | ២០២៤-២៥ | អគអរ,នា.បស, |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
| --- | --- | --- |
| | | នា.មចទ,សាលារៀន, សហគមន៍ |
| **៤. ការជំរុញការចូលរួមរបស់សហគមន៍តាមរយៈមូលនិធិសមធម៌៖** | | អគអរ, មន្ទីរអយក |
| - បង្កឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធសហការគ្នា ក្នុងការជួយសិស្សឱ្យចេះរៀន និងជួយកែលម្អបរិស្ថានថ្នាក់រៀន និងសាលារៀន | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន, សហគមន៍ |
| - លើកទឹកចិត្តឱ្យសិស្ស គ្រូបង្រៀន និងមាតាបិតាឱ្យរួមគ្នាកំណត់កិច្ចការត្រូវធ្វើក្នុងការជួយសិស្ស និងសាលារៀន | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន, សហគមន៍ |
| - លើកទឹកចិត្តគ្រប់ភាគីពាក់ព័ន្ធក្នុងការជួយគ្រូបង្រៀនឱ្យមានទឹកចិត្តបង្រៀន និងគ្រប់គ្រងសិស្សឱ្យអាចរៀនបានកាន់តែប្រសើរ ឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន, សហគមន៍ |
| - ប្រជុំផ្សព្វផ្សាយ និងកៀរគរធនធានតាមសហគមន៍ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន, សហគមន៍ |
| - បង្កើតគណៈកម្មការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន, សហគមន៍ |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| **៥. ការបង្រៀន និងរៀនពេញមួយថ្ងៃ៖** | | អគអរ, មន្ទីរអយក |
| - ការបង្រៀន និងរៀនពេញមួយថ្ងៃ តាមកម្មវិធីសិក្សាទំនើប ដោយបង្កើនម៉ោងសិក្សា ពង្រីកការអនុវត្តកម្មវិធី សិក្សានិងមុខវិជ្ជាសិក្សា លើកកម្ពស់ការអប់រំឌីជីថល ការបង្រៀនភាសាបរទេស និងការអប់រំស្នែម ភាសាជាតិ ភាសាបរទេស កុំព្យូទ័រ រ៉ូបូទិក ។ល។ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ |
| - មុនពេលចាប់ផ្តើមដំណើរការរៀនពេញមួយថ្ងៃ សាលារៀនត្រូវសិក្សាពីការចំណាយរបស់សិស្ស អគារសិក្សា ទីតាំងភូមិសាស្ត្រ ជំនួបជាមួយគ្រូ និងជំនួបជាមួយមាតាបិតា | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ |
| - ការកំណត់មុខសញ្ញាចំណាយដូចជា បុគ្គលិក រដ្ឋបាលសាលារៀន ការអភិវឌ្ឍ សាលារៀន និងសន្សំទុក | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន |
| - ការប្រជុំពិភាក្សារវាងគណៈកម្មការគ្រប់គ្រងសាលារៀនជាមួយគ្រូបង្រៀន ជាមួយ មាតាបិតា និងអ្នកពាក់ព័ន្ធ ដើម្បីពន្យល់អំពីដំណើរការ និងលទ្ធផលរំពឹងទុក និងមានការឯកភាពគ្នា | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន, សហគមន៍ |
| **៦.ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ៖** | | អគអរ, មន្ទីរអយក |
| - អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាប្រចាំលើវិធីសាស្ត្របង្រៀន និងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការបង្រៀន | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, នា. បវព |
| - បំពាក់សម្ភារបរិក្ខារបម្រើឱ្យការអប់រំឌីជីថលនៅទីចាត់ការ បន្ទប់រៀន បណ្ណាល័យ និងបន្ទប់កុំព្យូទ័រ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, នា. បវព |
| - លើកទឹកចិត្តសិស្ស និងគ្រូបង្រៀនឱ្យចូលរួមដោយមិនគិតពីកត្តាបរាជ័យ | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, សាលារៀន |
| - សហការជាមួយក្រសួង និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ដើម្បីភ្ជាប់សេវាដល់សាលារៀន | ២០២៤-២៥ | អគអរ, នា. អកត, នា.បស, នា.មចទ, នា. បវព |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| - សហការជាមួយក្រសួងមានសមត្ថកិច្ច ក្នុងការបិទការផ្សព្វផ្សាយកម្មវិធីផ្សេងៗ ដែលរំខានសិស្សនៅលើឧបករណ៍ឌីជីថលរបស់ពួកគេ | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ, នា. បវព |
| **៧.ការអនុវត្តកម្មវិធីសិក្សាបន្ថែមក្រៅម៉ោងសិក្សា** | | អគអវ, មន្ទីរអយក |
| - បង្កើតគណៈកម្មការគ្រប់គ្រងការអនុវត្តកម្មវិធី | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - ជួបជាមួយអ្នកអាណាព្យាបាលសិស្ស | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - ស្វែងរក និងទាក់ទងអង្គភាព ឬអង្គការដៃគូ សហគ្រិនភាព ឬ សាលាបច្ចេកទេស ដើម្បីជួយគាំទ្រដល់ការអនុវត្ត | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - បង្កើតរចនាសម្ព័ន្ធគ្រូប្រឹក្សាអាជីព និងជ្រើសរើសគ្រូអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - ផ្សព្វផ្សាយព័ត៌មានដល់សិស្ស និងអ្នកអាណាព្យាបាលនៅកម្មវិធីក្រៅម៉ោងសិក្សា | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - ជ្រើសរើសសិស្សតាមកម្មវិធី ដែលពួកគេពេញចិត្ត | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| **៨.សាលារៀនស្អាតក្នុងក្របខណ្ឌយុទ្ធនាការសាលារៀនគ្មានសំរាម៖** | | អគអវ, មន្ទីរអយក |
| ដើម្បីធ្វើឱ្យសាលារៀនស្អាតគ្មានសំរាម គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកពាក់ព័ន្ធ ត្រូវអនុវត្តវិធានការ៤គឺ៖ | | |
| - ចក្ខុវិស័យ និងការប្ដេជ្ញាចិត្ត៖ គណៈគ្រប់គ្រង និងបុគ្គលិកត្រូវមានការប្ដេជ្ញាចិត្តខ្ពស់ មានស្មារតីការងារជាក្រុម ភាពជាម្ចាស់ និងចក្ខុវិស័យ ដើម្បីកែលម្អសាលារៀនស្របតាមស្ដង់ដាសាលាកុមារមេត្រី សាលាមេត្រីបរិស្ថាន និងសូចនាករស្ដង់ដាអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - ការចូលរួម៖ ព្រះសង្ឃ គ្រូបង្រៀន សិស្ស មាតាបិតា សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវចូលរួមគាំទ្រក្នុងគ្រប់រូបភាព | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - ភាពជាអ្នកដឹកនាំ៖ សមត្ថភាពក្នុងការកៀរគរធនធាន ការបង្កើតជំនឿទុកចិត្ត ការគ្រប់គ្រងប្រកបដោយតម្លាភាព | ២០២៤-២៥ | អគអវ, នា. អកត, នា.បស, នា.មបទ |
| - ការបង្កើតយន្តការគ្រប់គ្រង៖ ការចូលរួមរបស់ក្រុមប្រឹក្សាកុមារ និងបុគ្គលិក កសាង និងការថែទាំបរិស្ថានសិក្សា | ២០២៤-២៥ | អគអវ, នា. អកត, |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
| --- | --- | --- |
| | | នា.បស, នា.មចទ |
| **៩.មជ្ឈមណ្ឌលឧត្តមភាពនៅឧត្តមសិក្សា៖** | | អគឧស, គ្រឹះស្ថានឧត្តមសិក្សា |
| - **ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព៖** វិនិយោគលើគ្រឹះស្ថានឧត្តមសិក្សា ដែលមានសក្តានុពល ដូចជាការកែលម្អ ហេដ្ឋារចនាសម្ព័ន្ធ អគារសិក្សា អន្តេវាសិកដ្ឋាន មន្ទីរពិសោធ កសិដ្ឋាន មជ្ឈមណ្ឌលឌីជីថល | ២០២៤-២៥ | អគឧស, នា.ឧស, នា.សវ, គ្រឹះស្ថានឧត្តមសិក្សា |
| - **ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន៖**<br>▪ ធានាស្វ័យភាព គណនេយ្យភាព ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថល ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធអភិបាលកិច្ច និងការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា<br>▪ ការកសាងផែនការយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវ<br>▪ ការបញ្ចូលអ្នកមានសញ្ញាបត្រថ្នាក់បណ្ឌិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការ<br>▪ ការបង្កើតកម្មវិធីថ្នាក់ក្រោយបណ្ឌិត ការសិក្សាលើជំនាញពាក់ព័ន្ធនឹងការងារទាំងរយៈពេលខ្លី និងវែង<br>▪ ការរៀបចំប្រព័ន្ធវាយតម្លៃការបំពេញការងារផ្អែកលើសមិទ្ធកម្ម | ២០២៤-២៥ | អគឧស, នា.ឧស, នា.សវ, គ្រឹះស្ថានឧត្តមសិក្សា |
| - **ការធ្វើទំនើបកម្មកម្មវិធីសិក្សា និងការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន៖**<br>▪ ធ្វើទំនើបកម្ម និងការអភិវឌ្ឍកម្មវិធីសិក្សាដោយផ្អែកលើលទ្ធផល (OBE) រួមទាំងការផ្តល់សិទ្ធិដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការកែសម្រួល និងការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការបញ្ចូលមុខវិជ្ជាថ្មីៗ និងការបង្កើតកម្មវិធីសិក្សាជំនាញថ្មី<br>▪ ការបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សា<br>▪ ការវាយតម្លៃទទួលស្គាល់គុណភាពកម្មវិធីសិក្សា និងការរៀននិងបង្រៀន តាមរយៈប្រព័ន្ធឌីជីថល ការបង្កើតប្រព័ន្ធផ្ទេរក្រេឌីតការសិក្សា (Credit Transfer) ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា<br>▪ ការផ្សារភ្ជាប់សាកលវិទ្យាល័យជាមួយកម្មវិធីអគារវៃឆ្លាត និងទីក្រុងវៃឆ្លាត ដោយសហការជាមួយក្រុមហ៊ុនក្នុង និងក្រៅប្រទេស | ២០២៤-២៥ | អគឧស, នា.ឧស, នា.សវ, គ្រឹះស្ថានឧត្តមសិក្សា |
| - **វិធានការលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន៖**<br>▪ បង្កើនគុណវុឌ្ឍិសាស្ត្រាចារ្យ ដោយផ្តល់អាហារូបករណ៍ដើម្បីបង្កើនគុណវុឌ្ឍិគ្រូថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង ថ្នាក់បណ្ឌិត | ២០២៤-២៥ | អគឧស, នា.ឧស, នា.សវ, គ្រឹះស្ថានឧត្តមសិក្សា |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| ▪ អនុវត្តវិធីសាស្ត្របង្រៀនទំនើប ដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១ តាមរយៈការសិក្សាបែបត្រឡប់ ការបង្រៀនតាមបែបសិក្សាគម្រោង (អនុវត្តផ្ទាល់ក្នុងមន្ទីរពិសោធន៍ កសិដ្ឋាន ឬជាក្រុម) ការសិក្សាបែបពិសោធន៍ ការសិក្សាបែបអនុវត្តផ្ទាល់ តាមរយៈម៉ូដែល Fab-lab ការបង្រៀនភាសាបរទេស បំណិនសហគ្រិនភាព បំណិនបច្ចេកវិទ្យា និងបំណិនឌីជីថល<br>▪ ការគាំទ្រដល់និស្សិត ដូចជាការសិក្សាគម្រោង ការស្រាវជ្រាវ ការពិសោធន៍ ការចុះកម្មសិក្សា និងការចល័តនិស្សិតជាមួយសាកលវិទ្យាល័យអន្តរជាតិ ស្ថាប័នដៃគូ សហគ្រាសឯកជន និងឧស្សាហកម្ម ការបង្កើតក្លឹបសិក្សា ស្វ័យសិក្សា និងការជួយនិស្សិតរៀនយឺត | | |
| - **ការពង្រឹងអន្តរជាតិភាវូបនីយកម្ម៖**<br>▪ បង្កើតកម្មវិធីសិក្សាអន្តរជាតិរួមមាន កម្មវិធីសិក្សាទ្វេ/ភ្លោះ និងកម្មវិធីសិក្សារួមគ្នា ជាពិសេសសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត តាមរយៈការសហការជាមួយសាកលវិទ្យាល័យដៃគូនៅក្នុងនិងក្រៅប្រទេស និងក្រុមហ៊ុនឧស្សាហកម្ម<br>▪ ការផ្លាស់ប្តូរគ្រូបង្រៀន អ្នកស្រាវជ្រាវ និងនិស្សិត<br>▪ ការអនុវត្តគម្រោងស្រាវជ្រាវរួមគ្នា ការអញ្ជើញសាស្ត្រាចារ្យ និងអ្នកជំនាញពីបរទេសមកជួយបង្រៀនមុខវិជ្ជាថ្មីៗ | ២០២៤-២៥ | អគឧស, នា.ឧស, នា.សវ, គ្រឹះស្ថានឧត្តមសិក្សា |
| - **ការពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅឧត្តមសិក្សា៖**<br>▪ ការលើកកម្ពស់ការស្រាវជ្រាវ និងបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវជាតិនិងអន្តរជាតិ<br>▪ ការពង្រឹងសមត្ថភាព គ្រប់គ្រងការស្រាវជ្រាវ<br>▪ ការផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវនិងការបង្កើតប្រាក់ចំណូល<br>▪ ការវាយតម្លៃស្នាដៃស្រាវជ្រាវដើម្បីផ្តល់ឋានៈសាស្ត្រាចារ្យ<br>▪ ការរៀបចំវេទិកាផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ<br>▪ ការបង្កើតមូលនិធិស្រាវជ្រាវជាតិ<br>▪ ការបង្កើតសង្គមវិទ្យាសាស្ត្រ (Professional Scientific Society) ដើម្បីចែករំលែកបទពិសោធ<br>▪ ការបង្កើតភាពជាដៃគូរវាងសាកលវិទ្យាល័យ និងសាកលវិទ្យាល័យ (Consortium Universities) សាកលវិទ្យាល័យនិងក្រុមហ៊ុនឧស្សាហកម្មឯកជន (University-Industry Linkage) សាកលវិទ្យាល័យ និងសហគមន៍ (University-Community Partnership) | ២០២៤-២៥ | អគឧស, នា.ឧស, នា.សវ, គ្រឹះស្ថានឧត្តមសិក្សា |
| - **ការបង្កើនចំនួននិស្សិតចូលរៀន និងបរិយាបន្ន៖**<br>▪ ការអនុវត្តកម្មវិធីភាពជាដៃគូ ការអប់រំស្វែងតាមគំរូភាពជាដៃគូរវាងមធ្យមសិក្សានិងឧត្តមសិក្សា<br>▪ ការផ្តល់អាហារូបករណ៍ដល់ និស្សិតក្រីក្រនិងមានពិការភាព<br>▪ ការផ្តល់ថវិកាគាំទ្រនិស្សិតចូលរៀននៅឧត្តមសិក្សា។ | ២០២៤-២៥ | អគឧស, នា.ឧស, នា.សវ, គ្រឹះស្ថានឧត្តមសិក្សា |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
| --- | --- | --- |
| **១០. ការអភិវឌ្ឍឧត្តមសិក្សាក្នុងបរិបទបច្ចេកវិទ្យាឌីជីថល៖** | | អគឧស, គ្រឹះស្ថានឧត្តមសិក្សា |
| ការគាំទ្រដល់ការអប់រំឌីជីថលនៅកម្រិតឧត្តមសិក្សារួមមាន: | | |
| - អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា | ២០២៤-២៥ | អគឧស, នា.សណ នា.ឧស, នា.បវព |
| - ការធានាគុណភាព និងស្តង់ដា | ២០២៤-២៥ | អគឧស, នា.សណ នា.បវព |
| - ការបត់បែនទៅតាមការផ្លាស់ប្តូរបច្ចេកវិទ្យា | ២០២៤-២៥ | អគឧស, នា.ឧស, នា.សជវ |
| - ការធានាសុវត្ថិភាពទិន្នន័យឯកជនភាព | ២០២៤-២៥ | អគឧស, នា.ឧស, នា.សជវ |
| - ការពង្រឹង ភាពជាដៃគូជាមួយក្រុមហ៊ុន | ២០២៤-២៥ | អគអរ, អគឧស, នា.សណ, នា.បវព |
| - ការបន្តការអភិវឌ្ឍវិជ្ជាជីវៈ | ២០២៤-២៥ | អគអរ, អគឧស, នា.សណ, នា.បវព |
| - ការអភិវឌ្ឍបណ្តាញសាកលវិទ្យាល័យសាយប៊័រ (Cyber University Network) ដែលមានគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនសម្រាប់ការអនុវត្តការបង្រៀននិងរៀន តាមអនឡាញ | ២០២៤-២៥ | អគឧស, នា.ឧស, នា.សជវ, គ្រឹះស្ថានឧត្តមសិក្សា |
| **១១. ការអប់រំបរិយាបន្ននៅកម្ពុជា៖** | | អគអរ, មន្ទីរអយក |
| ដើម្បីធានាបាននូវការផ្តល់សេវាអប់រំ ពិសេសប្រកបដោយគុណភាព ក្រសួងបាន៖<br>- ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស និងនាយកដ្ឋានអប់រំពិសេស៖ ការរៀបចំគោលនយោបាយស្តីពីការអប់រំកុមារពិការ គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ឯកសារជំនួយស្មារតីសម្រាប់គ្រូបង្រៀនវិទ្យាល័យអប់រំពិសេស ឯកសារជំនួយសម្រាប់ការកំណត់អត្តសញ្ញាណកុមារមានពិការភាពក្រោមអាយុ ៥ឆ្នាំ និងសម្របសម្រួលកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ | ២០២៤-២៥ | អគអរ, វ.អពស, នា.អរពស |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| - ការបន្តវិនិយោគលើវិទ្យាល័យអប់រំពិសេសចំនួន៦ ៖ ដើម្បីអនុវត្តកម្មវិធីអប់រំដល់កុមារមានពិការភាពនៅទូទាំងប្រទេស រួមទាំងកុមារខ្សោយសតិបញ្ញានិងអូទីស្សឹម និងការអនុវត្ត កម្មវិធីសមាហរណកម្ម ដោយកុមារត្រូវរៀននៅគ្រឹះស្ថានសិក្សារដ្ឋពាក់កណ្ដាលថ្ងៃ និងនៅសាលារៀនអប់រំពិសេសពាក់កណ្ដាលថ្ងៃទៀត | ២០២៤-២៥ | អគអរ, វ.អពស, នា.អរពស, នា.មចទ |
| - ការផ្ដល់ប្រាក់ឧបត្ថម្ភពិសេស៖ ចំនួន ៨ សែនរៀលលើបៀវត្សគ្រូបង្រៀន ដែលកើនឡើងជាលំដាប់ ដើម្បីថែរក្សាអ្នកឯកទេសខាងផ្នែកអប់រំពិសេស | ២០២៤-២៥ | អគអរ, វ.អពស, នា.អរពស |
| - ការបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ៖ សហការជាមួយអង្គការគ្រួសារថ្មីក្នុងការធ្វើសវនកម្មគុណភាពប្រចាំឆ្នាំ និងសហការជាមួយដៃគូអន្តរជាតិក្នុងការពិនិត្យត្រចៀក និងការគាំទ្របច្ចេកទេស | ២០២៤-២៥ | អគអរ, វ.អពស, នា.អរពស, ដៃគូ |
| - ការផ្ដល់ការអប់រំពហុភាសានៅកម្រិតមត្តេយ្យសិក្សា និងបីឆ្នាំដំបូងនៃបឋមសិក្សាសម្រាប់កុមារជនជាតិភាគតិច នៅខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ | ២០២៤-២៥ | អគអរ, វ.អពស, នា.អរពស, នា.បស |
| - ការប្រើប្រាស់គំរូស្ពានចម្លង៖ រៀនពីភាសាជនជាតិភាគតិច (ភាសាព្នង ការ៉ែត គ្រឹង ទំពួន ព្រៅ និងចារ៉ាយ) ដើម្បីឱ្យពួកគេអាចរៀនជាភាសាជាតិទាំងស្រុងនៅថ្នាក់ទី៤ | ២០២៤-២៥ | អគអរ, វ.អពស, នា.អរពស, នា.បស |
| - ការរៀបចំផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា៖ កម្ពុជាជាប្រទេសតែមួយគត់នៅតំបន់ អាស៊ីអាគ្នេយ៍ដែលលើកកម្ពស់ការអប់រំពហុភាសាតាមរយៈការកំណត់គោលការណ៍ស្ដីពីការអនុវត្តកម្មវិធីអប់រំពីរភាសា ការរៀបចំឯកសារបណ្ដុះបណ្ដាលគ្រូអប់រំពហុភាសា ឯកសារបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សាអប់រំពហុភាសាជាដើម | ២០២៤-២៥ | អគអរ, នា.អរពស, វអពស, |
| - ការបញ្ចូលសាលាសហគមន៍ចូលជាគ្រឹះស្ថានសិក្សារដ្ឋ៖ ផ្ដល់ថវិកាដំណើរការ សាលារៀន និងបញ្ចូលគ្រូជនជាតិដើមភាគតិចចំនួន ៥០នាក់ចូលក្នុងក្របខណ្ឌរដ្ឋ ដើម្បីធានាថាកុមារជនជាតិដើមភាគតិចទទួលការអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិតដើម្បីក្លាយជាមូលធនមនុស្ស | ២០២៤-២៥ | អគអរ, នា.អរពស, |
| **១២. មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត៖** | | អគអរ, មន្ទីរអេយក |
| ដើម្បីជំរុញមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យដំណើរការល្អ និងប្រែក្លាយជាមជ្ឈមណ្ឌល អប់រំពេញមួយជីវិត ទាមទារនូវកត្តាជាច្រើនរួមមាន៖ | | |
| - **ការបំពេញបន្ថែមលើកម្មវិធីសិក្សាសាលារដ្ឋ**៖ ស្របតាមតម្រូវការជាក់ស្ដែងរបស់ យុវជន និងសិស្ស ដូចជាកម្មវិធីបណ្ដុះបណ្ដាលភាសាបរទេស បច្ចេកវិទ្យា ព័ត៌មានវិទ្យា ការបណ្ដុះបណ្ដាលជំនាញ និងការបើកវគ្គខ្លីៗសម្រាប់យុវជន និងសិស្សចំណេះទូទៅ ព្រមទាំងមានវិធីសាស្ត្រទាក់ទាញសិស្សឱ្យមករៀន | ២០២៤-២៥ | អគអរ, នា.អកប, នា. តទវ |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| - **ការផ្សារភ្ជាប់កម្មវិធីបណ្តុះបណ្តាលជាមួយតម្រូវការជាក់ស្តែងក្នុងសហគមន៍៖** ការសិក្សាតម្រូវការទីផ្សារ ការបណ្តុះបណ្តាលជំនាញកសិកម្ម និងការរៀបចំកម្មវិធីប្រកបដោយភាព ច្នៃប្រឌិតនិងនវានុវត្តន៍ ដូចជាវគ្គខ្លីៗខាងផ្នែកគរុកោសល្យ សិប្បកម្មដែក ការផលិតវីដេអូ ការបណ្តុះបំណិនរកប្រាក់ចំណូលជាដើម | ២០២៤-២៥ | អគអរ, នា.អកប, នា. តទវ |
| - **ការចូលរួម និងការសហការ៖** ការបង្កើតគណៈកម្មការគ្រប់គ្រងដែលសកម្ម និងមានមនសិការខ្ពស់ ដោយមានការចូលរួមពីយុវជនស្ម័គ្រចិត្ត និងការគាំទ្រពីនាយកដ្ឋានអប់រំ ក្រៅប្រព័ន្ធ និងអង្គការដៃគូ ដូចជាអង្គការ DVVI ព្រមទាំងធ្វើការអភិវឌ្ឍសមត្ថភាពគណៈកម្មការគ្រប់គ្រងឱ្យមានសមត្ថភាពពេញលេញទាំងជំនាញទន់ និងជំនាញរឹង | ២០២៤-២៥ | អគអរ, នា.អកប, នា. តទវ |
| - **ការធានានិរន្តរភាព៖** តាមរយៈការផ្តល់ថវិការដ្ឋ ការបង្កើតសកម្មភាពរកចំណូល ដើម្បីទ្រទ្រង់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ការកៀរគរធនធានពីប្រភពផ្សេងៗ និងការលើកទឹកចិត្តដល់បុគ្គលិក | ២០២៤-២៥ | អគអរ, នា.អកប, នា. តទវ |
| **១៣.ក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា និងការផ្លាស់ប្តូរ ឥរិយាបថជាវិជ្ជមាន៖** | ២០២៤-២៥ | អគយវ, មន្ទីរអយក |
| ដើម្បីធានាបាននូវការគ្រប់គ្រងសាលារៀន និងការរៀននិងការបង្រៀនប្រកបដោយ គុណភាព និងប្រសិទ្ធភាព ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារត្រូវចូលរួមលើកកម្ពស់៖ | | អគយវ៖ នា. យវ, នា. គម, នា. សក |
| - **ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា៖** ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ កម្មវិធីមិត្តអប់រំមិត្ត យុទ្ធនាការលើកកម្ពស់ការយល់ដឹងពី សុខភាពបន្តពូជ និងការប្រយុទ្ធប្រឆាំងការប្រើប្រាស់សារធាតុញៀន | ២០២៤-២៥ | អគយវ៖ នា. យវ, នា. គម, នា. សក |
| - **ការងារស្ម័គ្រចិត្ត៖** ដើម្បីលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារសង្គម ហាត់ការ និងការបណ្តុះបំណិនបច្ចេកទេស | ២០២៤-២៥ | អគយវ៖ នា. យវ, នា. គម, នា. សក |
| - **ការបង្កើតក្លឹបសិក្សា៖** ការលើកកម្ពស់ស្វ័យសិក្សា និងការសិក្សារៀនសូត្រក្រៅម៉ោងសិក្សា | ២០២៤-២៥ | អគយវ៖ នា. យវ, នា. គម, នា. សក |
| - **ការបណ្តុះបំណិនសតវត្សរ៍ទី២១៖** ការចូលរួមក្នុងការប្រឡងប្រណាំង និងកម្មវិធីយុវជន ដើម្បីបង្កើនចំណេះដឹង បំណិនជីវិត បំណិនឌីជីថល បំណិនត្រិះរិះពិចារណា ការធ្វើការជាក្រុម និងបង្កើតទម្លាប់និងឥរិយាបថល្អ ដែលមានភាពចាំបាច់សម្រាប់យុវជននៅក្នុង សង្គមបច្ចុប្បន្ន | ២០២៤-២៥ | អគយវ៖ នា. យវ, នា. គម, នា. សក |
| **១៤. ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា៖** | ២០២៤-២៥ | អគកឡ,មន្ទីរអយក |
| តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ក្រសួងអប់រំ យុវជន និងកីឡានឹងត្រូវបន្តអនុវត្តដូចខាងក្រោម៖ | | |
| - **កម្មវិធីក្រៅម៉ោងសិក្សា៖** ដាក់បញ្ចូលការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាទៅក្នុងកម្មវិធីកីឡាក្រៅម៉ោងសិក្សា និងការអប់រំសិស្សឱ្យយល់ពីសារៈសំខាន់នៃកីឡាក្នុងការលើកកម្ពស់សុខភាព និងជីវភាពរស់នៅ | ២០២៤-២៥ | អគកឡ និងគ្រប់អង្គភាពក្រោមឱវាទ |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| - **ការរៀបចំកម្មវិធីសិក្សាថ្មី និងការលើកកម្ពស់គុណវុឌ្ឍិគ្រូកីឡា៖** ការរៀបចំកម្មវិធីសិក្សាទំនើបដោយសហការជាមួយអង្គការ Hearts of Gold និងការបណ្តុះបណ្តាលគ្រូកីឡាតាមរូបមន្តបរិញ្ញាបត្រ ឬ ១២+៤ | ២០២៤-២៥ | អគកឡ និងគ្រប់អង្គភាពក្រោមឱវាទ |
| - **ការផ្សារភ្ជាប់៖** ការអប់រំកាយជាមួយនឹងកីឡាតាមគ្រឹះស្ថានសិក្សានិងកីឡាកម្រិតខ្ពស់ (ការលេងបាល់គ្រប់ប្រភេទ ការបង្កើតក្លឹបកីឡា) | ២០២៤-២៥ | អគកឡ និងគ្រប់អង្គភាពក្រោមឱវាទ |
| - **ការរៀបចំការប្រកួត៖** លើកទឹកចិត្តឱ្យសហព័ន្ធកីឡារៀបចំការប្រកួតកីឡា ដើម្បីជ្រើសរើសកីឡាករមានសក្តានុពលឱ្យចូលក្នុងក្រុមកីឡាករថ្នាលនិងកីឡាករជម្រើសជាតិ | ២០២៤-២៥ | អគកឡ និងគ្រប់អង្គភាពក្រោមឱវាទ |
| **១៥ .ការលើកកម្ពស់សុខភាពសិក្សានៅតាមសាលារៀន៖** | | អគអរ, មន្ទីរអយក |
| ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈ | | |
| - **ការលើកកម្ពស់សុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ៖** ការរៀបចំបន្ទប់សុខភាព ការផ្តល់សេវាពិនិត្យសុខភាព និងការផ្តល់ថ្នាំបង្ការ។ ការរៀបចំ «បន្ទប់សុខភាពសិក្សាគ្រប់ជ្រុងជ្រោយ» មុនគេនៅសាលាបឋមសិក្សាចតុមុខ និងសាលារៀនជាច្រើនទៀតបានយកបទពិសោធនេះ ទៅអនុវត្តនៅសាលារៀនរបស់ខ្លួនជាបន្តបន្ទាប់។ នៅឆ្នាំ២០២២ ក្រសួងទទួលបានពានរង្វាន់ «ទិវាពិភពលោកគ្មានថ្នាំជក់» ពីអង្គការសុខភាពពិភពលោក (WHO) | ២០២៤-២៥ | អគអរ, នា.អកត, នា.បស, នា.មចទ, នា.សស |
| - **ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ៖** បរិក្ខារលាងសម្អាតដៃ បង្គន់អនាម័យ និងការគ្រប់គ្រងកាកសំណល់។ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាល បានសាងសង់បង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃចំនួន ២,៦៩៣ នៅតាមសាលារៀន អស់ថវិកា ៩លានដុល្លារ និងសាងសង់ដោយសហគមន៍។ គ្រឹះស្ថានសិក្សារដ្ឋ ១០០% មានបង្គន់អនាម័យ | ២០២៤-២៥ | អគអរ, នា.អកត, នា.បស, នា.មចទ, នា.សស |
| - **ការលើកកម្ពស់អាហារូបត្ថម្ភ និងគុណភាពចំណីអាហារ៖** កម្មវិធីផ្តល់អាហាតាម សាលារៀន ការលើកកម្ពស់មីក្រូសារជាតិក្នុងចំណីអាហារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន | ២០២៤-២៥ | អគអរ, នា.អកត, នា.បស, នា.មចទ, នា.សស |
| - **ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងមេត្រីភាព៖** អនាម័យ បរិស្ថានស្អាត សួនផ្កា និងទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡា | ២០២៤-២៥ | អគអរ, នា.អកត, នា.បស, នា.មចទ, នា.សស |
| - **ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា៖** ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ និងការបំពាក់ឧបករណ៍បង្ការការពារ | ២០២៤-២៥ | អគអរ, នា.អកត, នា.បស, នា.មចទ, នា.សស |

| សកម្មភាព | ពេលវេលា | អង្គភាពអនុវត្ត |
|---|---|---|
| - **ការលើកកម្ពស់ការអប់រំសុខភាព៖** ការអនុវត្តកម្មវិធីសិក្សា២ ម៉ោងក្នុង ១សប្តាហ៍ ការរៀបចំសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងការបណ្តុះបណ្តាលគ្រូមុខវិជ្ជាអប់រំសុខភាព | ២០២៤-២៥ | អគអរ, នា.អកត, នា.បស, នា.មចទ, នា.សស |
| - **ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា៖** ក្រសួងបានសហការ ជាមួយក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ព្រមទាំងដៃគូអភិវឌ្ឍផ្សេងទៀត ដោយរៀបចំជា «គោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សា ចំណេះទូទៅ» នៅឆ្នាំ២០២២។ គោលការណ៍នេះមាន ៩ស្តង់ដា ស្របតាមយុទ្ធសាស្ត្រទាំង៩ នៃគោលនយោបាយជាតិស្តីពីសុខភាពសិក្សា ដែលមាន ២៦សូចនាករ និង ៥៧ សូចនាកររង។ | ២០២៤-២៥ | អគអរ, នា.អកត, នា.បស, នា.មចទ, នា.សស |

## ការកំណត់អំពីការប្រើប្រាស់អក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

| ឈ្មោះអង្គភាព | | អក្សរកាត់ | ឈ្មោះអង្គភាព | | អក្សរកាត់ |
|---|---|---|---|---|---|
| **ល.រ** | **អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ** | **អគរហ** | **ល.រ** | **អគ្គនាយកដ្ឋានឧត្តមសិក្សា** | **អគឧស** |
| ១ | នាយកដ្ឋានរដ្ឋបាល | នា. រប | ១ | នាយកដ្ឋានឧត្តមសិក្សា | នា. ឧស |
| ២ | នាយកដ្ឋានបុគ្គលិក | នា. បល | ២ | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | នា. សវ |
| ៣ | នាយកដ្ឋានហិរញ្ញវត្ថុ | នា. ហវ | ៣ | គណៈកម្មការទទួលស្គាល់គុណភាពអប់រំ | គទគអ |
| ៤ | នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន | នា. ពអស | **ល.រ** | **អគ្គនាយកដ្ឋានយុវជន** | **អគយវ** |
| ៥ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | នា. បវព | ១ | នាយកដ្ឋានយុវជន | នា. យវ |
| ៦ | នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | នា. ទវអ | ២ | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល | នា. គម |
| ៧ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | នា. សទរ | ៣ | នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ | នា. សក |
| ៨ | នាយកដ្ឋាននីតិកម្ម | នា. នក | **ល.រ** | **អគ្គនាយកដ្ឋានកីឡា** | **អគកឡ** |
| ៩ | នាយកដ្ឋានសំណង់ | នា. សណ | ១ | នាយកដ្ឋានអប់រំកាយ និងកីឡា | នា. អកឡ |
| ១០ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | នា. សផក | ២ | នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត | នា. អកសន |
| ១១ | អង្គភាពលទ្ធកម្ម | អ. អល | ៣ | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ម.ជហក |
| **ល.រ** | **អគ្គាធិការដ្ឋាន** | **អគធក** | ៤ | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | វិ. អក |
| ១ | នាយកដ្ឋានធានាគុណភាពអប់រំ | នា. ធគអ | ៥ | នាយកដ្ឋានរៀបចំព្រឹត្តិការណ៍កីឡា | នា. រពកឡ |
| ២ | នាយកដ្ឋាននាយកដ្ឋានកិច្ចការប្រឡង | នា. កប្រឡ | ៦ | មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យា និងស្ថិតិកីឡា | ម.ជពសក |
| ៣ | អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | នា. អរហ | **ល.រ** | **អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ** | **អគបផ** |
| **ល.រ** | **អគ្គនាយកដ្ឋានអប់រំ** | **អគអរ** | ១ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | នា. ពអ |

| | | | | | |
|---|---|---|---|---|---|
| ១ | នាយកដ្ឋានអប់រំកុមារតូច | នា. អកត | ២ | នាយកដ្ឋានគោលនយោបាយ | នា. គប |
| ២ | នាយកដ្ឋានបឋមសិក្សា | នា. បស | ៣ | នាយកដ្ឋានផែនការ | នា. ផក |
| ៣ | នាយកដ្ឋានអប់រំពិសេស | នា. អពស | ៤ | នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ | នា. ពវ |
| ៤ | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | នា. មចទ | **ឍ.វ** | **គ្រឹះស្ថានឧត្តមសិក្សា** | |
| ៥ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | នា. អកប | ១ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សភភព |
| ៦ | នាយកដ្ឋានសុខភាពសិក្សា | នា. សស | ២ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | សភនវស |
| ៧ | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | នា. អកស | ៣ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | សជគ |
| ៨ | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ | នា. បវ | ៤ | វិទ្យាស្ថានជាតិអប់រំ | វជអ |
| ៩ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | នា. តទវ | ៥ | វិទ្យាស្ថានជាតិអប់រំពិសេស | វជអព |
| ១០ | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ | គបច | ៦ | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | វគភ |
| ១១ | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | សគមម | ៧ | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | វគប |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

# សុន្ទរកថា
# ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
# ថ្លែងក្នុង
# ពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា
# ឆ្នាំសិក្សា ២០២២-២០២៣ និងទិសដៅឆ្នាំសិក្សា ២០២៣-២០២៤

**វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤**

- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គនាយក អគ្គនាយករង និងប្រធានអង្គភាព
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- លោក លោកស្រី ប្រតិភូអប់រំ យុវជន និងកីឡារាជធានី-ខេត្ត
- អង្គសន្និបាតទាំងមូល ជាទីរាប់អាន !

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយដោយបានចូលរួមក្នុងពិធីបើក "សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០២២-២០២៣ និងទិសដៅសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤" ដែលជាឱកាសដ៏ល្អមួយសម្រាប់យើងទាំងអស់គ្នាធ្វើការពិនិត្យមើលឡើងវិញរួមគ្នាស្តីពី វឌ្ឍនភាពរបស់វិស័យអប់រំ យុវជន និងកីឡាដែលសម្រេចបានក្នុងឆ្នាំកន្លងទៅ ក៏ដូចជាលើកទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់ និងជាការឱកាសចាប់ផ្តើមដ៏ល្អមួយរបស់វិស័យអប់រំ យុវជន និងកីឡាក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា បានចាត់ទុកវិស័យអប់រំជាវិស័យអាទិភាពទី១ ឈានឆ្ពោះទៅអភិវឌ្ឍមូលធនមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន។

ក្នុងពិធីដ៏មានអត្ថន័យនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងប្រតិភូរាជធានី ខេត្ត ព្រមទាំងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតអប់រំប្រចាំឆ្នាំ មានរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី៣១ ខែមីនា ដល់ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ទាំងការចូលរួមដោយផ្ទាល់នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាក្តី ទាំងការចូលរួមតាមប្រព័ន្ធអនឡាញក្តី ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនអង្គសន្និបាតអំពី វិធានការគន្លឹះចំនួន ៤ ដែល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនៅក្នុងកិច្ចប្រជុំដំបូងរបស់គណៈរដ្ឋមន្ត្រី នីតិកាលទី៧ នៃរដ្ឋសភា ក្នុងគោលដៅពង្រឹងគុណភាពគ្រឹះស្ថានសិក្សារដ្ឋចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សា រួមមានៈ ទី១).ការពង្រឹងអភិបាលកិច្ចសាលារៀន, ទី២).ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា, និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង, វិន័យ, សីលធម៌ និងឥរិយាបថរបស់សិស្ស, ទី៣).ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួត ពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន, និងទី៤). ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុង ការអប់រំស្របតាមពាក្យស្លោក «ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ» ។ បន្ថែមពីលើនេះ ក្រសួងបានកំណត់អាទិភាពចំនួន៤បន្ថែមទៀតគឺ ទី៥).ការអប់រំឌីជីថល, ទី៦).ការបង្កើតមជ្ឈមណ្ឌល ឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា, ទី៧).ការកសាងប្រព័ន្ធនិងការអភិវឌ្ឍសមត្ថភាព, និងទី៨) ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

**អង្គសន្និបាតទាំងមូល ជាទីមេត្រី!**

ការកំណត់អាទិភាពសម្រាប់វិស័យអប់រំ យុវជន និងកីឡាដូចបានរៀបរាប់ខាងលើ ពិតជាបានគិតគូរគ្រប់ជ្រុងជ្រោយ ដោយឈរលើមូលដ្ឋាននៃការអនុវត្តកំណែទម្រង់អប់រំ ដែលបានដាក់ចេញជាបន្តបន្ទាប់ និងទទួលបាននូវលទ្ធផលជាច្រើនគួរជាទីមោទនៈ ទាំងផ្នែកបរិមាណវិស័យ និងគុណវិស័យ។ មកទល់ពេលនេះ យើងមានសាលារៀនគ្រប់កម្រិតសិក្សា ស្ទើរតែគ្រប់ទីតាំងភូមិសាស្ត្រនៅទូទាំងប្រទេស ស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី ក្នុងគោលដៅបង្ហិតសាលារៀនឱ្យទៅជិតលំនៅដ្ឋានរបស់ប្រជាជន។ ជាក់ស្តែង ក្នុងឆ្នាំសិក្សា២០២៣-២០២៤ សាលារៀនចំណេះទូទៅ និងមត្តេយ្យសិក្សាមាន ១៩,៣៤១ កន្លែង ក្នុងនោះសាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៨,៨៩១ កន្លែង សាលាបឋមសិក្សា ៨,២៥២ (ឯកជន ៨៥៤) អនុវិទ្យាល័យ ១,៣៤១ (ឯកជន ៩៩) និងវិទ្យាល័យ ៨៩៧ (ឯកជន ៣១៦)។ គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១៦៩កន្លែង ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៧៨ និងគ្រឹះស្ថានឧត្តមសិក្សាឯកជន ៩១ ។

សិស្ស និងនិស្សិតសរុប ៤,០៩៦,៧៥៨នាក់ ក្នុងនោះ

- កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាព ៤០០,៩៥៩នាក់ ស្រី ៥០.២% និងមានអត្រាចូលរៀនកុមារអាយុ ៥ ឆ្នាំកើនឡើងពី ៥៩.៩% នៅឆ្នាំ២០១៤ ដល់ ៦៥.៤% នៅឆ្នាំ២០២៤
- សិស្សបឋមសិក្សា ២,២៦៥,៧៨៣នាក់ ស្រី ៤៧.៩% និងមានអត្រាពិតនៃការសិក្សាកើនឡើងពី ៩៨.២% នៅឆ្នាំ២០១៤ ដល់ ៩៩.៦% នៅឆ្នាំ២០២៤
- សិស្សមធ្យមសិក្សាបឋមភូមិ ៧១១,១១៣នាក់ ស្រី ៥៣.៣% និងមានអត្រារួមនៃការសិក្សាកើនឡើងពី ៥៥.៣% នៅឆ្នាំ២០១៤ ដល់ ៦៥.៥% នៅឆ្នាំ២០២៤
- សិស្សមធ្យមសិក្សាទុតិយភូមិ ៤៣០,៧៩២នាក់ ស្រី ៥៥% និងមានអត្រារួមនៃការសិក្សាកើនឡើងពី ២៤.៩% នៅឆ្នាំ២០១៤ ដល់ ៤៦.៧% នៅឆ្នាំ២០២៤
- សិស្សមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស ៣,៥១២នាក់ ស្រី ៣៥.៤%

- និស្សិតឧត្តមសិក្សា ២៨៤,៥៩៩នាក់ ស្រី ៥២.៣% និងមានអត្រារួមនៃការសិក្សា (អាយុ១៨-២២ឆ្នាំ)កើនឡើងពី ១២.៥% នៅឆ្នាំ២០១៤ ដល់១៧.៩% នៅឆ្នាំ២០២៤។

អ្នកសិក្សាបានទទួលការអប់រំក្រៅប្រព័ន្ធតាមគ្រប់កម្មវិធីសរុប ៤០,៨៤៤នាក់ ក្នុងនោះ អ្នកចូលរៀនកម្មវិធីអក្ខរកម្មអប់រំក្រៅប្រព័ន្ធ ១៦,៥៨៧នាក់ អ្នកសិក្សាជំនាញមុខរបរងាយៗ ១១,២០៣នាក់ អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សានិងមធ្យមសិក្សា ៨,៣១០នាក់ និងអ្នកសិក្សាបំពេញវិជ្ជាបឋមភូមិ និងទុតិយភូមិ ៤,៧៤៤នាក់។

ក្រុមប្រឹក្សាកុមារកម្ពុជាមានសមាជិកសរុប១,៥៦៣,២៩៤នាក់ និងក្រុមប្រឹក្សាយុវជនកម្ពុជា មានសមាជិកសរុប ៣៧៤,៦៨៤នាក់។ កាយរឹទ្ធិជាតិកម្ពុជាមានសមាជិកសរុប ១៨០,០០០នាក់ ក្នុងនោះ កាយរឹទ្ធិប្អូន ១៨,១១៦នាក់ កាយរឹទ្ធិជំទង់ ១២៣,៥៩៥នាក់ កាយរឹទ្ធិរៀមច្បង ២២,១១៧នាក់ មេដឹកនាំកាយរឹទ្ធិ ១៣,៥៦៧នាក់ និងសមាជិកកិត្តិយស ២,៥០៥នាក់។

ក្រសួងបានប្រមូលផ្តុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស និងកីឡាករ ១,៣៨៤នាក់ មកធ្វើការហាត់ហ្វឹកហ្វឺនបង្កើនសមត្ថភាពបច្ចេកទេស ដើម្បីចូលរួមការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងចូលរួមការប្រកួតកីឡាជាលក្ខណៈអន្តរជាតិនានា ប្រកបដោយលទ្ធផលគួរជាទីមោទនៈ។

ក្រសួងបានយកចិត្តទុកដាក់លើគ្រូបង្រៀន ដោយបានចាត់ទុកថា គ្រូបង្រៀននៅកម្ពុជានឹងត្រូវទទួលបានការជឿទុកចិត្ត និងការទទួលស្គាល់ថាជា "អ្នកផលិតចំណេះដឹង អ្នកអនុវត្តពិតប្រាកដនៅកម្រិតសាលារៀន និងជាដៃគូសម្រាប់កែលម្អគោលនយោបាយ"។ ដើម្បីសម្រេចបាននូវគោលដៅនេះ ក្រសួងបាននិងកំពុងអនុវត្តកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយផ្តោតលើ៖ (១)ការកែលម្អកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការគ្រូ, (២)ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេសខាងផ្នែកខ្លឹមសារមេរៀន, គរុកោសល្យនិងវិធីសាស្ត្របង្រៀនសម្បូរបែប និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន, (៣)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ និងសម្ភារឧបទេសទំនើបសម្បូរបែប, (៤)ការអភិវឌ្ឍភាពជាអ្នកដឹកនាំនិងគ្រប់គ្រង, (៥)ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ, និង (៦)ការធានាគុណភាពនៃការបណ្តុះបណ្តាល។

ក្រសួងបានបន្តអភិវឌ្ឍសមត្ថភាពនិងពង្រឹងគុណភាពគ្រូឧទ្ទេស តាមរយៈការលើកកម្ពស់គុណវុឌ្ឍិ, អនុម័តស្តង់ដាគ្រូឧទ្ទេស និងអនុម័តគោលការណ៍ផ្តល់ឋានៈជាគ្រូឧទ្ទេស និងគ្រូឧទ្ទេសរងនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង បន្ទាប់ពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅវិទ្យាស្ថានគរុកោសល្យទាំងពីរត្រូវបានបញ្ចប់ ដើម្បីធានានិរន្តរភាពនិងការអភិវឌ្ឍ។

ក្រសួងបានកែលម្អកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ដោយបានបញ្ចូលកញ្ចប់អំណានដំបូងនិងគណិតវិទ្យាថ្នាក់ដំបូង ទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា, អនុម័តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បរិញ្ញាបត្រ+២, សម្រេចកំណត់គុណវុឌ្ឍិគ្រូ (គ្រូមត្តេយ្យ ១២+២, គ្រូបឋមសិក្សា ១២+៤ ឬបរិញ្ញា+១, គ្រូកម្រិតអប់រំមូលដ្ឋាន ១២+៤ ឬបរិញ្ញា+១) និងអនុម័តសៀវភៅណែនាំស្តីពី ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។ ជាមួយនេះ ក្រសួងបានផ្តោតលើការរៀននិងបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូងនៅកម្រិតបឋមសិក្សា, ការបង្កើនការចូលរៀននិងពង្រឹងការរៀនមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងភាសាបរទេសនៅកម្រិតមធ្យមសិក្សាចំណេះទូទៅ រួមទាំងវិធីសាស្ត្របង្រៀនថ្មីៗ។

ក្រសួងបានអនុវត្តកំណែទម្រង់សាលារៀនយ៉ាងសកម្ម សំដៅទទួលបាននូវសាលារៀនល្អ នាយកសាលាល្អ គ្រូបង្រៀនល្អ បរិស្ថានសាលារៀនល្អ និងមានការចូលរួមយ៉ាងផុលផុសពីសំណាក់សហគមន៍ គ្រួសារ និងអ្នកពាក់ព័ន្ធ។

ក្រសួងបានបញ្ចូលវិធានការគន្លឹះទាំង៤ ដែលបានដាក់ចេញដោយ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ទៅក្នុងស្តង់ដាសាលារៀនគំរូ ដោយផ្តោតលើ ៖

ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន ក្នុងគោលដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស ផ្លាស់ប្តូរវប្បធម៌សាលារៀន ពង្រឹងវិន័យ សីលធម៌ ចរិយាធម៌ សុជីវធម៌ គុណធម៌ និងឥរិយាបថល្អរបស់បុគ្គលិកអប់រំ និងសិស្សានុសិស្ស ដោយផ្តោតលើការពង្រឹងការគ្រប់គ្រងសាលារៀន រួមទាំងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន, ការរៀបចំផែនការអភិវឌ្ឍសាលារៀន ការធ្វើតេស្តស្តង់ដា និងការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក។

ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ដើម្បីពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ដោយគ្រឹះស្ថានសិក្សាត្រូវខិតខំប្រឹងប្រែងអនុវត្តកម្មវិធីសិក្សាថ្មី ជាពិសេសការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សាបន្ថែម ដើម្បីបង្កើនម៉ោងសិក្សាឱ្យបានយ៉ាងហោចណាស់ ២ ម៉ោងសិក្សាបន្ថែមទៀត ដោយផ្តោតលើ (១) កម្មវិធីអភិវឌ្ឍបំណិនមូលដ្ឋាន (២) កម្មវិធីប្រឹក្សាអាជីព និង (៣) កម្មវិធីអភិវឌ្ឍយុវជន។

ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស ដោយសាលារៀនត្រូវអនុវត្តតាមគោលនយោបាយជាតិស្តីពីសុខភាពសិក្សា និងបទដ្ឋានគតិយុត្តិស្តីពី សុខភាពសិក្សា ជាពិសេសត្រូវយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន ការរៀបចំអនុវត្តកម្មវិធីអាហារូបត្ថម្ភ ដើម្បីធ្វើឱ្យកុមារមានស្ថានភាពអាហារូបត្ថម្ភប្រសើរឡើង ដូចជាកម្មវិធីអាហារពេលព្រឹក ឬអាហារសម្រន់សម្រាប់កុមារប្រកបដោយគុណភាព និងការផ្តល់ការឧបត្ថម្ភឬអាហារូបករណ៍ដល់សិស្សក្រីក្រ។

ទី៤. ការលើកកម្ពស់ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីលើកកម្ពស់ការអប់រំ ដោយផ្តោតលើការជំរុញនិងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ដូចជាការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន, ការបង្កើនគណនេយ្យភាពនិងតម្លាភាពរបស់សាលារៀន និងការគាំទ្ររបស់សហគមន៍។

ក្រសួងបានចេញប្រកាសដាក់ឱ្យអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ សាលាបឋមសិក្សាគំរូ និងសាលាមធ្យមសិក្សាគំរូ រួមជាមួយនឹងយន្តការគាំទ្រ និងអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីធានាបានការអនុវត្តមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។ ក្នុងឆ្នាំ២០២៤ សាលារៀនចំនួន ៧៩៣ ត្រូវបានជ្រើសរើសជាសាលារៀនគោលដៅអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីធ្វើអធិការកិច្ច ផ្តល់ការគាំទ្រ និងជំរុញការអនុវត្ត ក្នុងនោះសាលាមត្តេយ្យសិក្សា ៩៦ សាលាបឋមសិក្សា ៣៤៨ និងសាលាមធ្យមសិក្សា ៣៤៩។ ក្រសួងបាននិងកំពុងជំរុញការអនុវត្តសាលារៀនគំរូតាមគ្រប់រូបភាព ដោយប្រើប្រាស់យន្តការ និងធនធានសរុប ទាំងថវិការដ្ឋ និងដៃគូអភិវឌ្ឍ ក្នុងនោះក្រសួងបានប្រជុំជាមួយអង្គភាពនៅរដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីពិនិត្យស្ថានភាពឥណទានថវិកាឆ្នាំ២០២៤ ក្នុងគោលបំណងកៀរគរឥណទានថវិកាពីសកម្មភាពផ្សេងទៅផ្តោតលើការ

អនុវត្តសាលារៀនគំរូ ដោយសរុបថវិកាបាន ១៥,៥៤៣,២០០,000 រៀល។ ជាមួយនេះ ក្រសួងបានធ្វើការវាយតម្លៃ និងទទួលស្គាល់ជ័យលាភីសាលារៀនគំរូចំនួន ១២០ ដោយផ្អែកលើគោលការណ៍៖

- សាលារៀនធ្លាប់ទទួលបានជ័យលាភីជានាយកល្អ និងសាលារៀនស្អាត
- សាលារៀនដែលទទួលជ័យលាភីជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ
- សាលារៀនដែលមានសិស្សនិទ្ទេស A, និទ្ទេស ABC, និងភាគរយប្រឡងជាប់ច្រើន ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- សាលារៀនដែលបានចូលរួមវង្វាយតម្លៃការសិក្សាកម្រិតតំបន់ SEA-PLM និងកម្រិតអន្តរជាតិ PISA និងមានសិស្សទទួលបានពិន្ទុខ្ពស់
- សាលារៀនជំនាន់ថ្មី វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងសាលារៀនទទួលបានពិន្ទុខ្ពស់ក្នុងការវាយតម្លៃស្តង់ដាសាលារៀនគំរូ

នៅក្នុងការអនុវត្តសាលារៀនគំរូឆ្នាំទី១ សាលារៀនទាំង ១២០នេះនឹងត្រូវក្រសួងប្រកាស ទទួលស្គាល់ក្នុងឱកាសសន្និបាតអប់រំនាពេលនេះ។ ក្រសួងសូមលើកចិត្តឱ្យសាលារៀនទាំង ១២០ និងសាលារៀនដទៃទៀត បន្តធ្វើការកែលម្អ និងអនុវត្តឱ្យបានពេញលេញនូវស្តង់ដាសាលារៀនគំរូ នៅឆ្នាំបន្តបន្ទាប់ទៀត។

ដើម្បីគាំទ្រដល់កំណែទម្រង់សាលារៀន ក្រសួងបានកែលម្អការងារ**អធិការកិច្ច** ដែលជាកិច្ចការដ៏សំខាន់មួយក្នុងការគាំទ្រសាលារៀនគំរូ ដោយក្រសួងបានបន្ស៊ីឧបករណ៍អធិការកិច្ចជាមួយស្តង់ដាសាលារៀនគំរូ ដើម្បីក្តាប់បានស្ថានភាពរបស់សាលារៀននីមួយៗ និងឈានទៅរៀបចំសកម្មភាពជាក់លាក់សម្រាប់ចុះជួយគាំទ្រ។

**ការរៀបចំតេស្តស្តង់ដា** ដើម្បីពង្រឹងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅកម្រិត សាលារៀន និងជាមូលដ្ឋានសម្រាប់រៀបចំផែនការកែលម្អសាលារៀន ដោយក្រសួងបាននិងកំពុងរៀបចំជាសេចក្តីណែនាំ ដើម្បីជំរុញឱ្យសាលាបឋមសិក្សា និងសាលាមធ្យមសិក្សាអនុវត្តតេស្តស្តង់ដាបានច្បាស់លាស់។ ជាមួយនេះ ក្រសួងនឹងពិនិត្យមើលយន្តការ និងគោលការណ៍ពាក់ព័ន្ធនឹងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សទាំងកម្រិតតំបន់ SEA-PLM និងកម្រិតអន្តរជាតិ PISA ដើម្បីបន្ស៊ីរវាងស្តង់ដានៃវង្វាយតម្លៃ កម្មវិធីសិក្សា វិធីសាស្រ្តបង្រៀន និងសៀវភៅសិក្សាគោល។

**ការអនុវត្តវិធីសាស្ត្របង្រៀន ដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មី** ក្នុងនោះក្រសួងបាន និងកំពុងជំរុញឱ្យសាលារៀនអនុវត្តវិធីសាស្រ្តបង្រៀនថ្មី ដូចគ្នានឹងការបង្រៀនតាមបែបគម្រោង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនជាដើម ដែលបានដាក់ឱ្យអនុវត្តនៅក្នុងសាលារៀនជំនាន់ថ្មី។

**ការបង្រៀននិងរៀនពេញមួយថ្ងៃ** នឹងត្រូវដាក់ឱ្យអនុវត្តនៅតាមគ្រឹះស្ថានសិក្សាដែលមានលទ្ធភាពសមស្របទាំងចំនួនបន្ទប់រៀននិងគ្រូបង្រៀន ដើម្បីបង្កើនម៉ោងសិក្សារបស់សិស្ស និងអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា។

**ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា** នៅតាមគោលដៅសាលារៀនគំរូ តាមរយៈការជំរុញឱ្យសាលារៀនរៀបចំ និងបង្កើនម៉ោងសិក្សា ពី៤ម៉ោងក្នុង ១ថ្ងៃ នាពេលបច្ចុប្បន្ន ទៅ ៦ម៉ោងក្នុង ១ថ្ងៃ ឬត្រូវជា ៤០ម៉ោង ក្នុង១សប្តាហ៍។

**ការអនុវត្តអំណាន និងគណិតវិទ្យាថ្នាក់ដំបូង** ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់របស់សិស្ស នៅបឋមសិក្សានិងភូមិសិក្សាបន្តបន្ទាប់ទៀត ដោយក្រសួងបាននិងកំពុងពង្រឹងគុណភាពនៃការអប់រំនៅកម្រិតបឋមសិក្សា តាមរយៈ (១)ការលើកកម្ពស់អំណានដំបូង, (២) គណិតវិទ្យាថ្នាក់ ដំបូង, (៣)ការបង្កើនចំនួនគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣, និង (៤)ការបង្កើត «សាលាគំរូអំណាននិងគណិតវិទ្យាថ្នាក់ដំបូង»។

**សេចក្តីណែនាំស្តីពី ការបង្កើតគ្រឹះស្ថានសិក្សា រួមទាំងសាលារៀនឧបសម្ព័ន្ធ** ដើម្បីកំណត់បានវិសាលភាពគ្រប់ដណ្តប់នៃសេវាអប់រំនៅតាមគ្រឹះស្ថានសិក្សានីមួយៗ ឱ្យបានច្បាស់លាស់ ដោយគិតគូរទាំងនិន្នាការប្រជាសាស្ត្រ និងកត្តាសង្គម-សេដ្ឋកិច្ច រួមទាំងពិនិត្យឡើងវិញនូវករណីនៃការបង្កើតសាលាឧបសម្ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងនិងដឹកនាំ និងប្រសិទ្ធភាពនៃការបំពេញការងារនៅគ្រប់លំដាប់ថ្នាក់។

ឆ្លើយតបនឹង**កំណែទម្រង់មុខងារសាធារណៈ** ក្រសួងបានធ្វើការវិភាគមុខងារបែបស៊ីជម្រៅតាមស្មារតីនៃការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ ដោយបានកាត់ចោលមុខងារត្រួតស៊ីគ្នាក្នុងការអនុវត្តភារកិច្ច និងបានកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួងឱ្យស្របទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ការកែសម្រួលរចនាសម្ព័ន្ធនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងអនុវត្តកំណែទម្រង់វិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាព រួមជាមួយនឹងការរៀបចំផែនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពមន្ត្រីរាជការ។

ក្រសួងក៏បានសិក្សាអំពី **ការបែងចែកតំបន់ជួបការលំបាក** ដើម្បីធ្វើឱ្យប្រសើរឡើងនូវការពង្រាយគ្រូ និងរក្សាបុគ្គលិកអប់រំនៅតាមសាលារៀនទូទាំងប្រទេស សំដៅធានាបាននូវសមធម៌ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ក្នុងនោះក្រសួងបានពិនិត្យ និងកែសម្រួលការកំណត់លក្ខខណ្ឌស្តីពី តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ឱ្យទៅជាការកំណត់សាលារៀនជួបការលំបាក ដែលសំដៅដល់សាលារៀនស្ថិតក្នុងភូមិសាស្ត្រងាយរងគ្រោះដោយកត្តាធម្មជាតិស្ថិតនៅតំបន់ដាច់ស្រយាល ខ្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងសហគមន៍ ស្ថិតក្នុងសហគមន៍ងាយរងគ្រោះដោយកត្តាផ្សេងៗ និងលទ្ធផលសិក្សាទាប។

ក្រសួងក៏បានធ្វើការសិក្សាស្តីពី **ស្ថានភាពពង្រាយគ្រូបង្រៀន** និងកំពុងពិគ្រោះយោបល់ និងដាក់ចេញវិធានការដោះស្រាយជាក់លាក់ ដើម្បីធានាបានការផ្តល់និងការប្រើប្រាស់បុគ្គលិកអប់រំនៅកម្រិតសាលារៀនប្រកបដោយប្រសិទ្ធភាព ជាពិសេសដាក់ចេញនូវវិធានការកាត់បន្ថយជាបណ្តើរៗចំនួនសិស្សក្នុងបន្ទប់រៀន ដើម្បីធានាគុណភាពអប់រំ។

**ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស** ដើម្បីពង្រឹងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ដោយផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រូបង្រៀន អ្នកដឹកនាំនិងគ្រប់គ្រងអ្នកស្រាវជ្រាវ និងអ្នកវាយតម្លៃអប់រំ ព្រមទាំងបង្កើតយន្តការសម្រាប់តម្រង់ទិសការងារ ការចុះជួយបង្វឹកការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ផងដែរ។

ការជំរុញការអនុវត្ត**គន្លងអាជីព** ដែលក្រសួងបានអនុម័តរួចហើយនូវក្របខណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំង ក្របខណ្ឌនិងផែនការសកម្មភាពស្តីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលារៀន។ មកទល់ពេលនេះ អង្គភាពចំនួន ៤ ត្រូវបានទទួលស្គាល់ជាអង្គភាពផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងបានបើកវគ្គចំនួន ៣៧ ប្រធានបទរួចហើយ។

ក្រសួងបានបន្តលើកទឹកចិត្ត និងជំរុញឱ្យមានការប្រឡងប្រណាំងសាលារៀនល្អ គ្រូបង្រៀនល្អ នាយកល្អ សាលារៀនគំរូ និងនៅពេលនេះក្រសួងនឹងប្រកាស ប្រធានមន្ទីរគំរូ ដែលបានខិតខំដឹកនាំវិស័យអប់រំនៅថ្នាក់ក្រោមជាតិបានល្អ និងជួយសាលារៀនឱ្យសម្រេចបានតាមស្តង់ដាសាលារៀនគំរូ។

ឆ្លើយតបនឹង**កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ** ក្រសួងបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងបានធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធកម្មវិធី និងអនុកម្មវិធី ក៏ដូចជាការបង្កើនការទទួលខុសត្រូវរបស់អង្គភាពអនុវត្ត ការធ្វើបច្ចុប្បន្ន

កម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា និងការពង្រឹងការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ព្រមទាំងការរៀបចំរបាយការណ៍សមិទ្ធកម្ម ផងដែរ។

ក្រសួងក៏បានពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅក្នុងវិស័យអប់រំ ទាំងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅថ្នាក់ជាតិ និងនៅតាមសាលារៀន ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការរៀបចំផែនការ ការពិនិត្យតាមដាន ការវាយតម្លៃ និងរបាយការណ៍។ មកទល់ពេលនេះ យើងមានប្រព័ន្ធព័ត៌មានច្រើនដូចជា EMIS, FMIS, HRMIS, SIS, Sala Digital ។ល។ ដែលក្រសួងមានទិសដៅរៀបចំកែលម្អប្រព័ន្ធព័ត៌មានទាំងនេះឱ្យបានល្អ និងធ្វើសុខុដុមនីយកម្មជាមួយគ្នាទាំងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការងារគ្រប់គ្រងសាលារៀនជាទូទៅ ដើម្បីធានាសុក្រឹតភាពទិន្នន័យ ការវិភាគទិន្នន័យ និងការប្រើប្រាស់ទិន្នន័យសម្រាប់ការសម្រេចចិត្តផ្នែកគោលនយោបាយ ដើម្បីងាយស្រួលក្នុងការកំណត់សាលារៀនអាទិភាព ដែលត្រូវផ្តល់ការគាំទ្រពីក្រសួង ឬពីគម្រោងនានា និងដើម្បីដោះស្រាយបញ្ហាប្រឈមរបស់សាលារៀន។

ឆ្លើយតបនឹង ***កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ*** ក្រសួងបាន៖ (១)លើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំរបស់ក្រុមការងារកំណែទម្រង់វិមជ្ឈការប្រចាំក្រសួង (២)ត្រួតពិនិត្យ និងគាំទ្រដល់ការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក (៣)កែសម្រួលរចនាសម្ព័ន្ធតួនាទី មុខងាររបស់មន្ទីរអប់រំ យុវជន និងកីឡាដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤)ផ្សព្វផ្សាយអនុក្រឹត្យលេខ ២១៣ ដល់ថ្នាក់ដឹកនាំបច្ចេកទេស (៥)បើកវគ្គបណ្តុះបណ្តាលស្តីពី គោលការណ៍ បែបបទ និងនីតិវិធីអនុវត្តមុខងារអប់រំ យុវជន និងកីឡាជូនដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស (៦)ពង្រឹងនីតិវិធីក្នុងការតែងតាំងនាយក នាយករងសាលារៀនដោយថ្នាក់ក្រោមជាតិ និង (៧)ពង្រឹងការត្រួតពិនិត្យ ដើម្បីធានាថាថ្នាក់ក្រោមជាតិអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួង។

ខ្ញុំជឿជាក់ថា សន្និបាតរយៈពេល៣ថ្ងៃនេះ នឹងប្រែក្លាយអាទិភាពការងារដូចបានរៀបរាប់ខាងលើទៅជាផែនការសកម្មភាពជាក់លាក់ និងកំណត់សូចនាករសមិទ្ធកម្មច្បាស់លាស់ សម្រាប់ការអនុវត្ត និងការពិនិត្យតាមដាន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ខ្ញុំសូមលើកទឹកចិត្ត ឯកឧត្តម លោកជំទាវ លោក លោកស្រី ធ្វើការពិភាក្សានិងផ្លាស់ប្តូរយោបល់ ព្រមទាំងចែករំលែកបទពិសោធ និងឧត្តមានុវត្តន៍ទៅវិញទៅមក ដើម្បីរិះរកវិធានការសម្រាប់ អនុវត្តនៅក្នុងឆ្នាំខាងមុខ ឱ្យកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល សំដៅឆ្លើយតបទៅនឹងសំណូមពរថ្មីៗនៃការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា។ ខ្ញុំមានក្តីរំពឹង និងភាពជឿជាក់យ៉ាងមុតមាំថា អង្គសន្និបាតដែលនឹងប្រព្រឹត្តទៅរយៈពេលបីថ្ងៃនេះ នឹងដំណើរការដោយរលូន និងទទួលបាននូវផ្លែផ្កាតាមការរំពឹងទុក។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត និងអង្គសន្និបាតទាំងមូល សមប្រកបដោយសុខភាពល្អ និងសម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច ព្រមទាំងទទួលនូវភាពសុខដុមរមនា និងសុភមង្គលក្នុងក្រុមគ្រួសាររៀងៗខ្លួន ជាពិសេសសូមជូនពរក្នុងឱកាសឆ្នាំថ្មី ប្រពៃណីជាតិ ដែលនឹងឈានមកដល់ក្នុងពេលដ៏ខ្លីខាងមុខ។

ខ្ញុំសូមប្រកាសបើកជាផ្លូវការ សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២២-២០២៣ និងទិសដៅសម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ ចាប់ពីពេលនេះតទៅ ៕

**សូមអរគុណ**!

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# សុន្ទរកថាស្វាគមន៍ និងរបាយការណ៍បូកសរុបលទ្ធផលសន្និបាតអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ថ្លែងក្នុងពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២២-២០២៣ និងទិសដៅឆ្នាំសិក្សា ២០២៣-២០២៤

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤

សូមគោរព៖

- **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវ ប្រធានក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ តំណាងអង្គទូតនានា និងដៃគូអភិវឌ្ឍ
- លោក លោកស្រី ប្រតិភូអប់រំ យុវជន និងកីឡា រាជធានី ខេត្ត
- អង្គសន្និបាតទាំងមូល ជាទីមេត្រី !

ថ្ងៃនេះជាទិវាប្រកបដោយនក្ខត្តឫក្សដែលយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយអង្គពិធីទាំងមូលមានកិត្តិយស សូមធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុង «ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២២-២០២៣ និងទិសដៅឆ្នាំសិក្សា ២០២៣-២០២៤» នៅវេលានេះ។

ក្នុងឱកាសដ៏មហាប្រសើរនេះ ខ្ញុំបាទមានកិត្តិយសសូមការអនុញ្ញាតរាយការណ៍ជូន **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ព្រមទាំងអង្គសន្និបាតទាំងមូលអំពី សមិទ្ធផលការងារ សំខាន់ៗ ក្នុងឆ្នាំសិក្សា២០២២-២០២៣ ជាពិសេសលទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡារយៈពេល ៦ខែ ដើមអាណត្តិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលមានខ្លឹមសារដូចតទៅ៖

## ១. ផ្នែកបរិមាណវិស័យ

ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ សាលារៀនចំណេះទូទៅ និងមត្តេយ្យសិក្សាមានចំនួន ១៩,៣៤១កន្លែង ក្នុងនោះសាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៨,៨៩១កន្លែង សាលា បឋមសិក្សា ៨,២៥២ (ឯកជន ៨៥៤) អនុវិទ្យាល័យ ១,៣៤១ (ឯកជន ៩៩) និងវិទ្យាល័យ ៨៩៧ (ឯកជន ៣១៦)។ គ្រឹះស្ថានឧត្តមសិក្សាទូទាំង

ប្រទេសមាន ១៦៩កន្លែង ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៧៨ និងគ្រឹះស្ថានឧត្តមសិក្សាឯកជន ៩១។ ការកើនឡើងនៃចំនួនអនុវិទ្យាល័យ វិទ្យាល័យ និងសិស្សមធ្យមសិក្សា បានធ្វើឱ្យចំនួនសិស្សក្នុងបន្ទប់រៀន កើនឡើងច្រើន គ្រូមិនអាចអនុវត្តវិធីសាស្ត្របង្រៀនថ្មី និងប៉ះពាល់ដល់គុណភាពនៃការសិក្សា។ ក្នុងន័យនេះ ក្រសួងនឹងអនុវត្តតាមគោលការណ៍ពង្រឹង ៨០% ពង្រីក ២០% តាម អនុសាសន៍របស់ **សម្តេចធិបតី**។

សិស្ស និងនិស្សិតសរុប ៤,០៩៦,៧៥៨នាក់ ក្នុងនោះ

- កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាព ៤០០,៩៥៩នាក់ ស្រី ៥០.២% និង មានអត្រាចូលរៀនកុមារអាយុ ៥ ឆ្នាំកើនឡើងពី ៥៩.៩% នៅឆ្នាំ២០១៤ ដល់ ៦៥.៤% នៅឆ្នាំ២០២៤
- សិស្សបឋមសិក្សា ២,២៦៥,៧៨៣នាក់ ស្រី ៤៧.៩% និងមានអត្រាពិតនៃការសិក្សាកើនឡើងពី ៩៨.២% នៅឆ្នាំ២០១៤ ដល់ ៩៩.៦% នៅឆ្នាំ២០២៤ និងអត្រារួមនៃការសិក្សា ១១០%
- សិស្សមធ្យមសិក្សាបឋមភូមិ ៧១១,១១៣នាក់ ស្រី ៥៣.៣% និងមានអត្រារួមនៃការសិក្សាកើនឡើងពី ៥៥.៣% នៅឆ្នាំ២០១៤ ដល់ ៦៥.៥% នៅឆ្នាំ២០២៤
- សិស្សមធ្យមសិក្សាទុតិយភូមិ ៤៣០,៧៩២នាក់ ស្រី ៥៥% និងមានអត្រារួមនៃការសិក្សាកើនឡើងពី ២៤.៩% នៅឆ្នាំ២០១៤ ដល់ ៤៦.៧% នៅឆ្នាំ២០២៤
- សិស្សមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស ៣,៥១២នាក់ ស្រី ៣៥.៤%
- និស្សិតឧត្តមសិក្សា ២៨៤,៥៩៩នាក់ ស្រី ៥២.៣% និងមានអត្រារួមនៃការសិក្សា (អាយុ១៨-២២ឆ្នាំ)កើនពី ១២.៥% នៅឆ្នាំ២០១៤ ដល់១៧.៩% នៅឆ្នាំ ២០២៤។

អ្នកសិក្សាបានទទួលការអប់រំក្រៅប្រព័ន្ធតាមគ្រប់កម្មវិធីសរុប ៤០,៨៤៤នាក់ ក្នុងនោះ អ្នកចូលរៀនកម្មវិធីអក្ខរកម្មអប់រំក្រៅប្រព័ន្ធ ១៦,៥៨៧នាក់ អ្នកសិក្សាជំនាញមុខរបរងាយៗ ១១,២០៣នាក់ អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សានិងមធ្យមសិក្សា ៨,៣១០នាក់ និងអ្នកសិក្សាបំពេញវិជ្ជាបឋមភូមិ និងទុតិយភូមិ ៤,៧៤៤ នាក់។

ក្រុមប្រឹក្សាកុមារកម្ពុជាមានសមាជិកសរុប ១,៥៦៣,២៩៤នាក់ និងក្រុមប្រឹក្សាយុវជនកម្ពុជាមានសមាជិកសរុប ៣៧៤,៦៨៤នាក់។ កាយរឹទ្ធិជាតិកម្ពុជាមានសមាជិកសរុប ១៨០,០០០នាក់ ក្នុងនោះកាយរឹទ្ធិប្អូន ១៨,១១៦នាក់ កាយរឹទ្ធិជំទង់ ១២៣,៥៩៥នាក់ កាយរឹទ្ធិរៀមច្បង ២២,១១៧នាក់ មេដឹកនាំកាយរឹទ្ធិ ១៣,៥៦៧ នាក់ និងសមាជិកកិត្តិយស ២,៥០៥នាក់។

ក្រសួងបានប្រមូលផ្តុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស និងកីឡាករ ១,៣៨៤នាក់ មកធ្វើការ ហាត់ហ្វឹកហ្វឺនបង្កើនសមត្ថភាពបច្ចេកទេស ដើម្បីចូលរួមការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅឆ្នាំ ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងចូលរួមការប្រកួតកីឡាជាលក្ខណៈអន្តរជាតិនានា ប្រកបដោយលទ្ធផលគួរជាទីមោទនៈ។

បុគ្គលិកអប់រំសរុប ១២៤,៥១៧នាក់ ស្ត្រី ៤៧.៥% ក្នុងនោះថ្នាក់ជាតិ ៤,៩៧៨ នាក់ ស្ត្រី ៣៣.៣% និងថ្នាក់ក្រោមជាតិ ១១៩,៥៣៩នាក់ ស្ត្រី ៤៨.១% ក្នុងនោះបុគ្គលិកមិនបង្រៀន ៣៣,៣៥៥នាក់ ស្ត្រី ៣១.៩% និងបុគ្គលិកបង្រៀន ៨៦,១៨៤នាក់ ស្ត្រី ៥៤.៣%។ ដើម្បីតម្លើងបៀវត្សដល់គ្រូបង្រៀន ចំនួនបុគ្គលិកអប់រំដែលជ្រើសរើសថ្មីត្រូវបានកាត់បន្ថយពី ៥,០០០នាក់ មកត្រឹម ៣,០០០នាក់ក្នុងមួយឆ្នាំ។ ម៉្យាងវិញទៀត ក្នុងរយៈពេល ១០ឆ្នាំ

ចុងក្រោយនេះ បុគ្គលិកអប់រំចំនួន ១,០៦៩នាក់ត្រូវបានផ្ទេរចេញពីក្រសួងអប់រំ យុវជន និងកីឡាទៅបម្រើការនៅក្រសួងផ្សេង ជាពិសេសក្រសួងមហាផ្ទៃ ដើម្បីបម្រើការងារក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក។ បុគ្គលិកអប់រំចំនួន ៥,១១៦នាក់បាន បោះបង់ចោលការងារជាមធ្យម ៥០០នាក់ក្នុង១ឆ្នាំ និងបុគ្គលិកអប់រំចំនួន ១២,៨៦៦នាក់ បានចូលនិវត្តន៍ជាមធ្យម ១,២៨៦នាក់ ចូលនិវត្តន៍ក្នុង១ឆ្នាំ។ ដូចនេះ ក្នុងមួយឆ្នាំក្រសួងអប់រំ យុវជន និងកីឡាទទួលបានក្របខណ្ឌចំនួន ៣,០០០នាក់ និងបាត់ទៅវិញ ១,៩០៤នាក់ ពោលគឺនៅសល់ ១,០៩៦នាក់ ក្នុង១ឆ្នាំប៉ុណ្ណោះ។

## ២. ផ្នែកគុណវិស័យ

ក្រសួងបាន និងកំពុងអនុវត្តយ៉ាងសកម្មនូវវិធានការគន្លឹះ ៤ ចំណុចរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ដែលបានដាក់ចេញអនុសាសន៍ដ៏ខ្ពង់ខ្ពស់ នាសម័យប្រជុំដំបូងគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៧ សំដៅលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតសំខាន់លើការពង្រឹងគុណភាពសាលារៀនរដ្ឋ ចាប់ពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សា៖ ទី១) ការពង្រឹងអភិបាលកិច្ចសាលារៀន, ទី២) ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាព ក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស, ទី៣) ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា, ទី៤) ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីការអប់រំ។ បន្ថែមពីលើនេះ ក្រសួងបានកំណត់អាទិភាពចំនួន៤បន្ថែមទៀតគឺ ទី៥).ការអប់រំឌីជីថល, ទី៦).ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា, ទី៧).ការកសាងប្រព័ន្ធនិងការអភិវឌ្ឍសមត្ថភាព, និងទី៨) ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

ខ្ញុំសូមគោរពរាយការណ៍ជូននូវវឌ្ឍនភាពសំខាន់ៗដែលសម្រេចបាន ក្នុងរយៈពេល ៦ខែ ដើមអាណត្តិទី៧ ដូចតទៅ ៖

### ២.១ ការអនុវត្តសាលារៀនគំរូ

ក្រសួងបានចេញប្រកាសដាក់ឱ្យអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ សាលាបឋមសិក្សាគំរូ និងសាលាមធ្យមសិក្សាគំរូ រួមជាមួយនឹងយន្តការគាំទ្រ និងអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីធានាបានការអនុវត្តមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។ ក្នុងឆ្នាំ២០២៤ សាលារៀនចំនួន ៧៩៣ ត្រូវបានជ្រើសរើសជាសាលារៀនគោលដៅអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីធ្វើអធិការកិច្ច ផ្តល់ការគាំទ្រ និងជំរុញការអនុវត្ត ក្នុងនោះសាលាមត្តេយ្យសិក្សា ៩៦ សាលាបឋមសិក្សា ៣៤៨ និងសាលាមធ្យមសិក្សា ៣៤៩។ ក្រសួងបាននិងកំពុងជំរុញការអនុវត្តសាលារៀនគំរូតាមគ្រប់រូបភាពដោយប្រើប្រាស់យន្តការនិងធនធានសរុប ទាំងថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍ ក្នុងនោះក្រសួងបានប្រជុំជាមួយអង្គភាពនៅរដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីពិនិត្យស្ថានភាពឥណទានថវិកាឆ្នាំ២០២៤ ក្នុងគោលបំណង កៀរគរឥណទានថវិកាពីសកម្មភាពផ្សេងទៅផ្តោតលើការអនុវត្តសាលារៀនគំរូ ដោយសរុបថវិកាបាន ១៥,៥៤៣,២០០,០០០ រៀល ឬស្មើនឹង ៣.៨លានដុល្លារ។ ជាមួយនេះ ក្រសួងបានធ្វើការវាយតម្លៃ និងទទួលស្គាល់ជ័យលាភីសាលារៀនគំរូចំនួន ១២០ ដោយផ្អែកលើគោលការណ៍៖

- សាលារៀនធ្លាប់ទទួលបានជ័យលាភីជានាយកល្អ និងសាលារៀនស្អាត
- សាលារៀនដែលទទួលជ័យលាភីជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ
- សាលារៀនដែលមានសិស្សនិទ្ទេស A, និទ្ទេស ABC, និងភាគរយប្រឡងជាប់ច្រើនក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- សាលារៀនដែលបានចូលរួមវង្វាយតម្លៃការសិក្សាកម្រិតតំបន់ SEA-PLM និងកម្រិតអន្តរជាតិ PISA និងមានសិស្សទទួលបានពិន្ទុខ្ពស់
- សាលារៀនជំនាន់ថ្មី វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងសាលារៀនទទួលបានពិន្ទុខ្ពស់ក្នុងការវាយតម្លៃស្តង់ដាសាលារៀនគំរូ។

នៅក្នុងការអនុវត្តសាលារៀនគំរូឆ្នាំទី១ ក្រសួងបានចេញប្រកាសទទួលស្គាល់សាលារៀនទាំង ១២០ នៅក្នុងឱកាសសន្និបាតអប់រំ និងបានលើកទឹកចិត្តឱ្យសាលារៀនទាំង ១២០ និងសាលារៀនដទៃទៀតបន្តធ្វើការកែលម្អ និងអនុវត្តឱ្យបានពេញលេញនូវស្តង់ដាសាលារៀនគំរូនៅឆ្នាំបន្តបន្ទាប់ទៀត។ ជាមួយគ្នានេះ ក្រសួងបានទទួលស្គាល់ **មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតស្រែក្នុង** ស្ថិតក្នុងស្រុកជុំគីរី ខេត្តកំពត ជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតគំរូ ដោយមើលឃើញអំពីលទ្ធផលនៃការបំពេញការងារល្អ និងភាពជាអ្នកដឹកនាំល្អរបស់លោកនាយក។

ដើម្បីគាំទ្រដល់កំណែទម្រង់សាលារៀន ក្រសួងបានកែលម្អការងារអធិការកិច្ច ដែលជាកិច្ចការដ៏សំខាន់មួយក្នុងការគាំទ្រសាលារៀនគំរូ ដោយក្រសួងបានបន្ស៊ីឧបករណ៍អធិការកិច្ច ជាមួយស្តង់ដាសាលារៀនគំរូ ដើម្បីក្តាប់បានស្ថានភាពរបស់សាលារៀននីមួយៗ និងឈាន ទៅរៀបចំសកម្មភាពជាក់លាក់សម្រាប់ចុះជួយគាំទ្រ។

**ការរៀបចំតេស្តស្តង់ដា៖** ដើម្បីពង្រឹងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅកម្រិតសាលារៀន និងជាមូលដ្ឋានសម្រាប់រៀបចំផែនការកែលម្អសាលារៀន។ ក្រសួងបាន និងកំពុងរៀបចំសេចក្តីណែនាំ ដើម្បីជំរុញឱ្យសាលាបឋមសិក្សា និងសាលាមធ្យមសិក្សាអនុវត្តតេស្តស្តង់ដាបានច្បាស់លាស់។ ការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស និងឆមាស លទ្ធផលនឹងត្រូវយកមកកែលម្អការបង្រៀននិងរៀន។ ម៉្យាងវិញទៀត ក្រសួងចាប់ផ្តើមយកសំណួរតេស្តកម្រិតតំបន់ និងកម្រិតអន្តរជាតិមកអនុវត្តតាមសាលារៀន ដើម្បីធានាសង្គតិភាពរវាងការរៀន និងការបង្រៀន និងការធ្វើតេស្ត។

**ការអនុវត្តវិធីសាស្ត្របង្រៀន ដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មី៖** ដោយក្រសួងបាន និងកំពុងជំរុញឱ្យសាលារៀនគំរូអនុវត្ត «វិធីសាស្ត្របង្រៀនថ្មី« ដូចជាការបង្រៀនតាមបែបគម្រោង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនជាដើម ដើម្បីពង្រឹងគុណភាពអប់រំ និងលើកកម្ពស់បំណិនសតវត្សរ៍ទី២១ និងឆ្លើយតបនឹងតេស្ត PISA។

**យុទ្ធសាស្ត្រការបង្រៀននិងរៀនពេញមួយថ្ងៃ៖** ក្រសួងបានដាក់ឱ្យអនុវត្តការរៀន និង បង្រៀនពេញមួយថ្ងៃ ដោយប្រើមូលនិធិសមធម៌នៅតាមសាលាបឋមសិក្សាចំនួន ២០កន្លែង។ ជាមួយនេះ ក្រសួងបាននិងកំពុងរៀបចំយុទ្ធសាស្ត្របង្រៀនពេញមួយថ្ងៃ តាមរយៈការលើកកម្ពស់អំណានបន្ថែម និងការធ្វើស្វ័យសិក្សា ដោយប្រើប្រាស់សន្លឹកកិច្ចការ កម្មវិធីកីឡា ការងារសង្គម ការបង្រៀនសិល្បៈ និងវប្បធម៌ខ្មែរ ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី**។

**ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា៖** ក្រសួងបានជំរុញឱ្យសាលារៀនដែលមានសក្តានុពល ដើម្បីបង្កើនម៉ោងសិក្សាពី ៤ម៉ោងក្នុង ១ថ្ងៃ នាពេលបច្ចុប្បន្នទៅ ៦ម៉ោងក្នុង១ថ្ងៃ ឬ ៤០ម៉ោង ក្នុង១សប្តាហ៍ ដោយគិតគូរអំពី

លទ្ធភាពនៃបន្ទប់រៀន និងចំនួនគ្រូបង្រៀន។ ក្រសួងបានចេញសេចក្តីណែនាំ ដើម្បីដោះស្រាយបញ្ហាវត្តមានរបស់គ្រូបង្រៀន និងវត្តមានរបស់សិស្ស ព្រមទាំងការពង្រឹងវិន័យនៅក្នុងនិងក្រៅសាលារៀន។ ក្រសួងបានជំរុញឱ្យសាលារៀនរៀបចំយន្តការ និងបង្កើតក្លឹបសិក្សាដើម្បីធ្វើស្វ័យសិក្សា និងការជួយសិស្សរៀនយឺត។ ជាមួយនេះ ក្រសួងបានចេញសេចក្តីណែនាំស្តីពី ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានសិក្សាមធ្យមសិក្សាសាធារណៈដែលជាផ្នែកមួយជំរុញ «ភាពជាដៃគូសាធារណៈនិងសហគមន៍ក្នុងការអប់រំ» ក្នុងគោលដៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួម ជាពិសេសការបង្កើតទំនាក់ ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស។

**ការអនុវត្តអំណាន និងគណិតវិទ្យាថ្នាក់ដំបូង៖** គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់របស់សិស្សនៅបឋមសិក្សា និងភូមិសិក្សាបន្តបន្ទាប់ទៀត។ ក្រសួងបាននិងកំពុងពង្រឹងគុណភាពនៃការអប់រំកម្រិតបឋមសិក្សាតាមរយៈ៖ (១)ការលើកកម្ពស់អំណានដំបូង (២)គណិតវិទ្យាថ្នាក់ដំបូង (៣)បង្កើនចំនួនគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣, និង(៤)បង្កើត «សាលាគំរូ អំណាននិងគណិតថ្នាក់ដំបូង»។ ការលើកកម្ពស់«អំណានថ្នាក់ដំបូង» និង«គណិតវិទ្យាថ្នាក់ដំបូង» ជាពិសេសការបណ្តុះបណ្តាលគ្រូ និងការពង្រីកការអនុវត្តនៅទូទាំងប្រទេសមានគោលដៅលើកកម្ពស់គុណភាពអប់រំ តាមរយៈការបង្កើនលទ្ធផលសិក្សារបស់សិស្សពោលគឺ កុមារកម្ពុជាចេះអានសរសេរ និងគិតលេខទាំងអស់គ្នា។ ជាលទ្ធផល ក្រសួងបានសហការ ជាមួយដៃគូអភិវឌ្ឍ អនុវត្តកញ្ចប់សម្ភារអំណានថ្នាក់ទី១ បានគ្រប់សាលាបឋមសិក្សាក្នុង ២២ រាជធានី ខេត្ត អំណានថ្នាក់ទី២ បានអនុវត្តក្នុង ១៩ខេត្ត និងអំណានថ្នាក់ទី៣ បានអនុវត្តនៅខេត្តកំពង់ឆ្នាំង។ កញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ទី១ បានអនុវត្តនៅ ៨ខេត្ត និងកញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ទី២ បានអនុវត្តនៅ ៦ខេត្ត។ ក្រសួងបានបញ្ចូលកញ្ចប់អំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង ក្នុងការបណ្តុះបណ្តាលគ្រូនៅតាមសាលាគរុកោសល្យ។

**សេចក្តីណែនាំស្តីពីការបង្កើតគ្រឹះស្ថានសិក្សារួមទាំងសាលារៀនឧបសម្ព័ន្ធ៖** ដើម្បីកំណត់បានទំហំគ្របដណ្តប់នៃសេវាអប់រំរបស់សាលារៀននីមួយៗបានច្បាស់លាស់ រួមទាំងការបង្កើតសាលាឧបសម្ព័ន្ធ ដើម្បីជានាប្រសិទ្ធភាពនៃការគ្រប់គ្រង ដឹកនាំ និងប្រសិទ្ធភាពការងារនៅគ្រប់កម្រិត។ សេចក្តីណែនាំនេះនឹងចេញឱ្យអនុវត្តនាពេលឆាប់ៗនេះ។ បញ្ហាប្រឈមកន្លងមកគឺ ប្រជាពលរដ្ឋបានទៅរស់នៅតំបន់ដីថ្មី និងបានបង្កើតជារោងដោលដោយគ្មានការទទួលស្គាល់ពីក្រសួង (ចំនួនជាង ៣០០) ជាហេតុធ្វើឱ្យតម្រូវការក្នុងការសាងសង់អគារថ្មីកើនឡើងខ្លាំង លើសពីលទ្ធភាពជាក់ស្តែង។

**២.២ កំណែទម្រង់មុខងារសាធារណៈ**

**ការពិនិត្យឡើងវិញមុខងារក្រសួង និងអនុក្រឹត្យថ្មី៖** ក្រសួងបានធ្វើការវិភាគមុខងារបែប ស៊ីជម្រៅតាមស្មារតីនៃការធ្វើវិចារណកម្ម ដោយបានកាត់ចោលមុខងារត្រួតស៊ីគ្នាក្នុងការអនុវត្ត ភារកិច្ច និងបានកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនឱ្យស្របទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។ ការកែសម្រួលរចនាសម្ព័ន្ធនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងអនុវត្តកំណែទម្រង់វិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាព និងរៀបចំផែនការអភិវឌ្ឍបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពមន្ត្រីរាជការ ក្នុងគោលដៅសម្រេចចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ខាងមុខ។ ក្រសួងបានពិនិត្យ និងកាត់បន្ថយនាយកដ្ឋានចំនួន៤ និងការិយាល័យចំនួន ៣៤ និងបានប្រែក្លាយ

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុទៅជាអគ្គលេខាធិការដ្ឋាន ដើម្បីសម្របសម្រួលការងារ ព្រមទាំងបង្កើតអគ្គនាយកដ្ឋានថ្មីមួយគឺ អគ្គនាយកដ្ឋានអភិវឌ្ឍ ធនធានមនុស្ស។

**ការរៀបចំផែនការអភិវឌ្ឍសមត្ថភាព៖** ដើម្បីពង្រឹងការគ្រប់គ្រងធនធានមនុស្ស ដោយផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀន ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង និងអ្នកស្រាវជ្រាវ និងវាយតម្លៃ ព្រមទាំងបង្កើតយន្តការតម្រង់ទិសការងារ ការចុះជួយបង្វឹកការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ជាកិច្ចបន្ទាប់ ក្រសួងនឹងរៀបចំ និងអនុម័តផែនការស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ២០២៤-២០២៨ ឱ្យបានមុនដំណាច់ឆមាសទី១ ឆ្នាំ២០២៤ និងកំណត់អាទិភាពបណ្តុះបណ្តាលអ្នកជំនាញឱ្យបានពី ១០០ ទៅ ២០០នាក់ ក្នុងរយៈពេល ២ឆ្នាំ។

**ការសិក្សាបែងចែកតំបន់ជួបការលំបាក៖** គឺជាកិច្ចការដ៏សំខាន់នៃការគ្រប់គ្រងបុគ្គលិក ជាពិសេសការធ្វើឱ្យប្រសើរឡើងនូវការផ្តល់ និងរក្សាបុគ្គលិកអប់រំនៅតាមសាលារៀនទូទាំងប្រទេសសំដៅធានាបានសមធម៌ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព។ ក្រសួងបាន ពិនិត្យកែសម្រួលការកំណត់លក្ខខណ្ឌស្តីពី តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ឱ្យទៅជាការកំណត់សាលារៀនជួបការលំបាក ដែលសំដៅដល់សាលារៀនស្ថិតក្នុងភូមិសាស្ត្រងាយរងគ្រោះដោយកត្តាធម្មជាតិ ស្ថិតនៅតំបន់ដាច់ស្រយាល និងខ្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងសហគមន៍ ស្ថិតក្នុងសហគមន៍ងាយរងគ្រោះដោយកត្តាផ្សេងៗ និងលទ្ធផលសិក្សាទាប។ ក្រសួងនឹងប្រើប្រាស់ថវិកាដែលសន្សំបាន ដើម្បីប្រើប្រាស់សម្រាប់លើកទឹកចិត្តគ្រូឱ្យមានប្រសិទ្ធភាព ក្នុងគោលដៅពង្រាយគ្រូឱ្យបានដល់សាលាដែលជួបការលំបាកពិតៗ។

**ការសិក្សាលើដំណោះស្រាយបញ្ហាខ្វះអគារសិក្សា ថ្នាក់រៀន ការខ្វះគ្រូ និងបន្ទប់រៀន ដែលមានសិស្សច្រើនលើសលប់៖** ក្រសួងបានធ្វើការសិក្សាស្តីពី ស្ថានភាពអគារសិក្សា ខ្វះគ្រូ បង្រៀន និងបន្ទប់រៀនដែលមានសិស្សច្រើន និងកំពុងពិគ្រោះយោបល់ និងដាក់ចេញវិធានការដោះស្រាយជាក់លាក់ ដើម្បីធានាបានការធ្វើផែនការ និងការប្រើប្រាស់បុគ្គលិកអប់រំនៅកម្រិតសាលារៀន។ វិធានការដោះស្រាយរួមមាន៖ ការធ្វើចំណោលតម្រូវការគ្រូបង្រៀនរយៈពេលវែង ការរៀបចំផែនការដោយសហការជាមួយនាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ និងភាគីពាក់ព័ន្ធដែលមានលក្ខណៈពីក្រោមឡើងលើ និងពីលើចុះក្រោម ដើម្បីកាត់បន្ថយកត្តាខ្វះខាត ការផ្គត់ផ្គង់គ្រូបង្រៀនដោយចៃដន្យ ការរៀបចំគោលការណ៍បែងចែកគ្រូ ដោយវិភាគទៅលើទីតាំងដែលអាចប្រើប្រាស់ ឬដាក់ដំណើរការបង្រៀនបែបឌីជីថលបាន ការផ្លាស់ប្តូរគ្រូបង្រៀន ត្រូវពិនិត្យលក្ខខណ្ឌ និងកែសម្រួលដើម្បីធ្វើបច្ចុប្បន្នកម្ម ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

**ការជំរុញការអនុវត្តគន្លងអាជីព** ដែលក្រសួងបានអនុម័តរួចហើយនូវក្របខណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំងក្របខណ្ឌនិងផែនការសកម្មភាពស្តីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន។ គន្លងអាជីពចែកចេញជា៣ផ្នែក៖ គ្រូបង្រៀន គណៈគ្រប់គ្រង និងអ្នកបច្ចេកទេស និងជា ៣កម្រិត៖ ល្អ ឆ្នើម និងឈានមុខ។ មកទល់ពេលនេះ ក្រសួងបានផ្តល់សិទ្ធិក្នុងការ ផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់អង្គភាពចំនួន ៤ និងបានបើកវគ្គចំនួន ៣៧ប្រធានបទរួចហើយ ដើម្បីផ្តល់ឱកាសដល់បុគ្គលិកអប់រំក្នុងការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងវិធីសាស្ត្របង្រៀន។ ជាមួយគ្នានេះ ក្រសួងក៏បណ្តុះស្មារតីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពេញមួយជីវិតការងារដល់បុគ្គលិកអប់រំ ដោយផ្តោតលើ៖

១).ធានាឱ្យមានក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ
២).ធានាថាបុគ្គលិកអប់រំគ្រប់រូបនឹងទទួលបានវគ្គវិក្រឹតការទៀងទាត់
៣).ធានាការផ្សារភ្ជាប់រវាងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពបុគ្គលិកអប់រំ និង
៤).ធានាឱ្យមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការផ្សារភ្ជាប់កំណែទម្រង់គ្រូបង្រៀន និងកំណែទម្រង់សាលារៀន។

**ការលើកកម្ពស់ការប្រឡងប្រណាំង៖** ក្រសួងបានលើកទឹកចិត្ត និងជំរុញឱ្យមានការប្រឡងប្រណាំងសាលារៀនល្អ គ្រូបង្រៀនល្អ នាយកល្អ សាលារៀនគំរូ និងប្រធានមន្ទីរគំរូឱ្យបានកាន់តែច្រើន តាមរយៈការរៀបចំយន្តការវាយតម្លៃនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និង នៅថ្នាក់ជាតិ។ គ្រូបង្រៀនល្អ នាយកល្អ និងអ្នកជំនាញល្អ ត្រូវបានបញ្ចូលទៅក្នុងគន្លងអាជីព ដោយស្វ័យប្រវត្តិ។

### ២.៣ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ក្រសួងបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងបានធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធ កម្មវិធី និងអនុកម្មវិធី ក៏ដូចជាការបង្កើនការទទួលខុសត្រូវរបស់អង្គភាពអនុវត្ត ការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា និងការពង្រឹងការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ព្រមទាំងការរៀបចំរបាយការណ៍សមិទ្ធកម្មផងដែរ។

### ២.៤ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

ក្រសួងក៏បានពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅក្នុងវិស័យអប់រំ ទាំងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅថ្នាក់ជាតិ និងនៅតាមសាលារៀន ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការរៀបចំ ផែនការ ការពិនិត្យតាមដាន ការវាយតម្លៃ និងរបាយការណ៍។ មកទល់ពេលនេះ ក្រសួងមាន ប្រព័ន្ធព័ត៌មានច្រើនដូចជា EMIS, FMIS, HRMIS, SIS, Sala Digital។ល។ ដែលក្រសួង មានទិសដៅរៀបចំកែលម្អប្រព័ន្ធព័ត៌មានទាំងនេះឱ្យបានល្អ និងធ្វើសុខដុមនីយកម្មជាមួយគ្នា ទាំងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការងារគ្រប់គ្រងសាលារៀនជាទូទៅ ដើម្បីធានាសុក្រឹតភាពទិន្នន័យ ការវិភាគទិន្នន័យ និងការប្រើប្រាស់ទិន្នន័យសម្រាប់ការសម្រេចចិត្តផ្នែកគោលនយោបាយ ដើម្បីងាយស្រួលក្នុងការកំណត់សាលារៀនអាទិភាព ដែលត្រូវផ្តល់ការគាំទ្រពីក្រសួង ឬពីគម្រោងនានា និងដើម្បីដោះស្រាយបញ្ហាប្រឈមរបស់សាលារៀន។

### ២.៥ កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

ក្រសួងបានធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូដែលផ្តោតលើ (១)ការកែលម្អកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូ, (២)ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេសខាងផ្នែកខ្លឹមសារមេរៀន, គរុកោសល្យ និងវិធីសាស្ត្របង្រៀនសម្បូរបែប និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន, (៣)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ និងសម្ភារឧបទេសទំនើបសម្បូរបែប, (៤)ការអភិវឌ្ឍភាពជាអ្នកដឹកនាំនិងគ្រប់គ្រង, (៥)ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ, និង(៦)ការធានាគុណភាពនៃការបណ្តុះបណ្តាល។ ក្នុងពេលខាងមុខ ក្រសួងនឹង៖

១) បន្តអនុវត្តកំណែទម្រង់សាលាគរុកោសល្យ តាមរយៈ (i) បង្កើនគុណវុឌ្ឍិ ១២+៤ ឬ បរិញ្ញាបត្រ+១ សម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ និងបរិញ្ញា+២ សម្រាប់ គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ (ii) កែលម្អការបណ្តុះបណ្តាលគ្រូ ដើម្បីបំពេញតាម "ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន" និង (iii) ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

២) ឈានឆ្ពោះទៅអនុវត្តអាជ្ញាប័ណ្ណគ្រូបង្រៀន(គ្រូបង្រៀនកិច្ចសន្យាពិសេស) សម្រាប់សាលារៀននៅជនបទ និងជួបការលំបាក ដោយប្រើប្រាស់គុណវុឌ្ឍិដូចគ្នា

៣) អនុវត្តវិធីសាស្ត្របង្រៀនថ្មីសម្រាប់មធ្យមសិក្សាស្របទៅនឹងកម្មវិធីវាយតម្លៃ PISA ជាពិសេសផ្តោតលើចំណេះដឹង និងបំណិនសតវត្សរ៍ទី២១ ដូចដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មី និងអនុវត្តអំណានដំបូង និងគណិតវិទ្យាដំបូង នៅកម្រិតបឋមសិក្សា

៤) ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្របង្រៀន វិធីសាស្ត្ររៀន និងវិធីសាស្ត្រវាយតម្លៃថ្មីដែលអាចអនុញ្ញាតឱ្យសិស្សអភិវឌ្ឍបំណិននៃការគិតប្រកបដោយការត្រិះរិះពិចារណា និងដោះស្រាយបញ្ហាដែលទាក់ទងនឹងជីវិតប្រចាំថ្ងៃ

៥) លើកកម្ពស់ការអប់រំឌីជីថល និងវេទិកាសិក្សាអេឡិចត្រូនិក ដើម្បីចែករំលែកឧត្តមានុវត្តន៍ដល់គ្រូបង្រៀន

៦) ការផ្តល់ឋានៈដល់គ្រូឧទ្ទេស។

## ២.៦ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្រសួងបាន (១)លើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំរបស់ក្រុមការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង (២)ត្រួតពិនិត្យ និងគាំទ្រដល់ការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (៣) កែសម្រួលរចនាសម្ព័ន្ធតួនាទី មុខងាររបស់មន្ទីរអប់រំ យុវជន និង កីឡា ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤)ផ្សព្វផ្សាយអនុក្រឹត្យលេខ ២១៣ ដល់ ថ្នាក់ដឹកនាំបច្ចេកទេស (៥)បើកវគ្គបណ្តុះបណ្តាលស្តីពី គោលការណ៍ បែបបទ និងនីតិវិធី អនុវត្តមុខងារអប់រំ យុវជន និងកីឡាជូនដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស (៦)ពង្រឹងនីតិវិធីក្នុងការតែងតាំងនាយក នាយករងសាលារៀនដោយថ្នាក់ក្រោមជាតិ និង (៧)ពង្រឹងការត្រួតពិនិត្យ ដើម្បីធានាថាថ្នាក់ក្រោមជាតិអនុវត្តតាមគោលការណ៍ណែនាំ របស់ក្រសួង។

- **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- **អង្គសន្និបាតទាំងមូលជាទីមេត្រី**

សន្និបាតអប់រំ យុវជន និងកីឡាឆ្នាំនេះ បានដំណើរការចាប់ពីថ្ងៃទី៣១ ខែមីនា ដល់ថ្ងៃទី២ ខែមេសា ឆ្នាំ ២០២៤ ដើម្បីបូកសរុបវាយតម្លៃការងារដែលបានអនុវត្តក្នុងឆ្នាំសិក្សាកន្លងមកនិងលើកទិសដៅការងារសម្រាប់ឆ្នាំសិក្សាខាងមុខទៀត។ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ជ្រាបថា៖ មុននឹងមានសន្និបាតនៅថ្នាក់ជាតិនេះ ក្រសួងបានណែនាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំងអស់ឱ្យរៀបចំរបាយការណ៍សន្និបាត ដើម្បីប្រមូលធាតុចូលពីថ្នាក់ក្រោមជាតិ មកពិភាក្សាដោះស្រាយក្នុងសន្និបាតនៅថ្នាក់ជាតិដែលមានអ្នកចូលរួមផ្ទាល់ប្រមាណ ២ ០០០នាក់ និងមានអ្នកចូលរួមជាច្រើនទៀត តាមប្រព័ន្ធអនឡាញ។

នៅក្នុងសន្និបាតអប់រំក្នុងរយៈពេល៣ថ្ងៃកន្លងមកនេះ ក្រសួងបានជ្រើសរើសប្រធានបទ បទបង្ហាញ និងបទអន្តរាគមន៍ដែលមានខ្លឹមសារជាយុទ្ធសាស្ត្រស្របទៅនឹងវិធានការគន្លឹះទាំង ៤ ដែលជាអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដើម្បីពង្រឹងគុណភាពអប់រំ និងស្របទៅនឹងការអនុវត្តស្តង់ដាសាលារៀនគំរូ ។

ខ្ញុំបាទសូមគោរពរាយការណ៍ជូន ដោយសង្ខេបនូវលទ្ធផលនៃការពិភាក្សា និងការដាក់ចេញនូវវិធានការ ១៥ចំណុច ដែលសាលារៀនទាំងអស់ត្រូវយកទៅអនុវត្ត ដូចខាងក្រោម៖

**១.ការពង្រឹងអភិបាលកិច្ច និងកំណែទម្រង់សាលារៀន៖** អភិបាលកិច្ចសាលារៀនត្រូវបានពង្រឹង ដោយឈរលើកត្តាគន្លឹះចំនួន ៣គឺ៖ លទ្ធផលសិក្សារបស់សិស្ស ការដឹកនាំនិងគ្រប់គ្រង និងការចូលរួមរបស់មាតាបិតានិងសហគមន៍។

ការពង្រឹងអភិបាលកិច្ចសាលារៀនមានគោលបំណងបង្កើនប្រសិទ្ធភាព ស្វ័យភាព តម្លាភាព និងគណនេយ្យភាពរបស់សាលារៀនចំពោះសហគមន៍របស់ខ្លួន ដោយចាប់ផ្តើមពីការពង្រឹងវិន័យ សណ្តាប់ធ្នាប់ និងឥរិយាបថរបស់គណៈគ្រប់គ្រងសាលារៀនមុនគេ បន្ទាប់មកគ្រូបង្រៀន សិស្ស និងមាតាបិតា។ សាលារៀនត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងឱ្យបានរឹងមាំ រួមបញ្ចូលទាំងក្រុមសិស្សជួយសិស្ស ក្រុមគ្រូជួយគ្រូ និងធានាគុណភាពនៃការសិក្សា និងតម្លាភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ដែលជាមូលដ្ឋានក្នុងការទាក់ទាញសហគមន៍ឱ្យចូលរួម។ សាលារៀនត្រូវពង្រឹងសាមគ្គីភាពនៅក្នុងសាលារៀន និងទំនាក់ទំនងល្អជាមួយសហគមន៍ និងអាជ្ញាធរដែនដី។ ជាមួយគ្នានេះ សាលារៀនត្រូវយកចិត្តទុកដាក់ដល់សុខភាព សមត្ថភាព ជីវភាព និងគុណភាពទាំងបុគ្គលិក សិស្សានុសិស្ស និងសហគមន៍។ ដើម្បីធ្វើកំណែទម្រង់សាលារៀន អ្នកដឹកនាំ និងគ្រប់គ្រងត្រូវ៖

**(១) ការពង្រឹងវិន័យ និងអប់រំសិស្សឱ្យស្រឡាញ់សាលារៀន៖**

- **នៅកម្រិតបឋមសិក្សា៖** ត្រូវរៀបចំឯកសណ្ឋាន និងសម្លៀកបំពាក់ស្អាត ការអប់រំណែនាំសិស្សនៅពេលគោរពទង់ជាតិ ដោយបង្ហាត់អំពីការតម្រង់ជួរ របៀបរបប ការហាត់កីឡា ការយកចិត្តទុកដាក់អំពីសុខភាពនិងសុខមាលភាពរបស់សិស្ស ការបណ្តុះមនសិការស្នេហាជាតិ ការធ្វើសមាធិ ការលេងភ្លេង ការបង្កើតក្រុមប្រឹក្សាកុមារ និងយុវជន ការផ្តល់រង្វាន់ និងការអនុវត្តទណ្ឌកម្មតាមបែបវិជ្ជមាន។
- **នៅកម្រិតមធ្យមសិក្សា៖** ត្រូវរៀបចំបរិស្ថានសិក្សាដែលគាំទ្រដល់ការសិក្សា ការផ្តល់ប្រឹក្សាអាជីព ការជួយដោះស្រាយបញ្ហាសិស្ស កម្មវិធីមិត្តអប់រំមិត្ត ការរៀបចំពិព័រណ៍ស្នាដៃសិស្សដើម្បីលើកទឹកចិត្តដល់ការសិក្សានិងស្វ័យសិក្សា ការបណ្តុះបំណិនសតវត្សរ៍ទី២១ និងការផ្តល់ឱកាសដល់សិស្សក្នុងការប្រកួតប្រជែងដើម្បីបញ្ចេញស្នាដៃ។

**(២) ការងារជាមួយមាតាបិតា៖** នាយកសាលាត្រូវធ្វើការងារជាមួយមាតាបិតា ដើម្បីផ្តល់ការគាំទ្របន្ថែមដល់សិស្សដូចជា ការរៀបចំកម្មវិធីបំប៉ន ទស្សនកិច្ចសិក្សា ការប្រជុំជាប្រចាំ ការបង្កើតប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតា ជាពិសេសនៅពេលសិស្សអវត្តមាន និងការផ្សព្វផ្សាយលទ្ធផលសិក្សា។

**(៣) ការងារជាមួយគ្រូបង្រៀន៖** សាលារៀនត្រូវការពារផលប្រយោជន៍របស់គ្រូ យកចិត្តទុកដាក់ដល់សុខទុក្ខរបស់បុគ្គលិក ការរៀបចំយន្តការស្វ័យគ្រប់គ្រង ការផ្តល់ការគាំទ្រដល់គ្រូបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យាបន្ទប់ពិសោធន៍ ការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការបង្កើនគុណវុឌ្ឍិ ការស្រាវជ្រាវប្រតិបត្តិដើម្បីកែលម្អវិធីសាស្ត្របង្រៀន និងការផ្តល់ ការលើកទឹកចិត្តតាមគ្រប់រូបភាព។

**(៤) ការពង្រឹងការដឹកនាំ និងគ្រប់គ្រង៖** សាលារៀនត្រូវបង្កើត (១)គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រប់គ្រងថ្នាក់រៀន ការរៀបចំផែនការកែលម្អសាលារៀន ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ (២)ការបែងចែកតួនាទីភារកិច្ចដល់គណៈគ្រប់គ្រងតាមគោលការណ៍ ស្វ័យភាព និងការចុះកិច្ចសន្យាការងាររវាងគណៈគ្រប់គ្រងសាលារៀន ជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន (៣)ការបង្កើនភាពជាម្ចាស់និងគណនេយ្យភាព (៤)ការបណ្តុះស្មារតី ពង្រឹងសមត្ថភាពខ្លួនឯងជាប្រចាំ (៥)ការគ្រប់គ្រងប្រកបដោយតម្លាភាព (៦)ការរៀបចំបរិស្ថានសាលារៀនស្អាត (៧)ការបង្កើតបណ្ណាល័យស្តង់ដា និងមានផាសុខភាពសម្រាប់ការអាន។

**២.ការពង្រឹងវិន័យ សីលធម៌ និងឥរិយាបថសិស្ស៖** គោលដៅនៃការអប់រំ គឺការលើកកម្ពស់វិជ្ជាសម្បទា(២០ពិន្ទុ) បំណិនសម្បទា (១៦) និងចរិយាសម្បទារបស់សិស្ស ជាពិសេសការអភិវឌ្ឍផ្នែកស្មារតី រាងកាយ សុខភាព វិន័យ សីលធម៌ ចំណេះដឹង បំណិន និងឥរិយាបថល្អ។ សាលារៀនត្រូវ៖

**១) ការអប់រំសិស្ស៖** បណ្តុះស្មារតីសិស្សឱ្យមករៀនទាន់ពេលវេលា ការបណ្តុះទម្លាប់ល្អដល់កុមារ (ភាពស្អាតនៃរាងកាយ ការស្លៀកពាក់ របៀបហូបអាហារ ការប្រើប្រាស់សម្ភារៈសិក្សា ការចូលបន្ទប់ទឹក ការលាងសម្អាតដៃ របៀបសំពះ សុភាពរាបសារ សេចក្តីក្លាហានក្នុងការ និយាយ និងទំនាក់ទំនងជាដើម) ការយល់ដឹងពីសិល្បៈ តន្ត្រី វប្បធម៌ និងបរិស្ថានជុំវិញ រួមទាំងការធ្វើសមាធិដើម្បីយល់ហេតុផល ការអប់រំតាមបែបវិជ្ជមាន ការលើកទឹកចិត្តចំពោះ ឥរិយាបថល្អ និងមានសេចក្តីក្លាហានក្នុងការទាក់ទងរវាងកុមារនិងកុមារ រវាងកុមារនិងរៀមច្បង ឬចាស់ព្រឹទ្ធាចារ្យ មាតាបិតា លោកគ្រូ អ្នកគ្រូ និងការបង្កើតកម្មវិធីក្រៅម៉ោងសិក្សា ដើម្បីលើកកម្ពស់ការចូលរួមរបស់ព្រះសង្ឃក្នុងការលើកកម្ពស់សីលធម៌ និងចរិយាធម៌របស់សិស្ស។

**២) ការងារជាមួយគ្រូបង្រៀន៖** ពង្រឹងសីលធម៌ និងឥរិយាបថរបស់គ្រូឱ្យទៅជាគំរូដល់សិស្ស ការអភិវឌ្ឍវិធីសាស្ត្របង្រៀន របៀបនៃការសិក្សារៀនសូត្ររបស់សិស្ស ការយល់ដឹងអំពីភាសាទំនាក់ទំនង បរិស្ថានសិក្សាទាំងក្នុងបរិវេណ និងបរិស្ថានជុំវិញសាលារៀន។

**៣) បរិស្ថានសិក្សា៖** បង្កើតបរិស្ថានសាលារៀនស្អាត ការលើកកម្ពស់អនាម័យ និងបរិស្ថានបៃតង ការអនុវត្តសកម្មភាពបន្ថែមទាំងក្នុងថ្នាក់និងក្រៅថ្នាក់ ការអប់រំសុខភាពសិក្សាដើម្បីបណ្តុះទម្លាប់ល្អ វិន័យ សីលធម៌ និងឥរិយាបថ។

**៣.ការលើកកម្ពស់អាហារូបត្ថម្ភតាមសាលារៀន៖** កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ត្រូវបានអនុវត្តនៅក្នុងសាលារៀនគោលដៅ ១,១១៤ ក្នុងខេត្តចំនួន ១០ ដែលស្ថិតនៅក្នុងតំបន់ដែលប្រឈមនឹងអសន្តិសុខស្បៀង។ កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានដោះស្រាយបញ្ហាអសន្តិសុខស្បៀងក្នុងចំណោមសិស្ស ដោយធានាថាសិស្សអាចទទួលបានអាហារមួយពេល ទៀងទាត់ និងមានជីវជាតិ។ ឧត្តមានុវត្តន៍នៃកម្មវិធីនេះគឺ៖

**១) ការអប់រំប្រកបដោយសមធម៌៖** ដោយបានលើកកម្ពស់សុវត្ថិភាពស្បៀង អាហារូបត្ថម្ភ និងអនាម័យទឹកស្អាត ការលូតលាស់ខួរក្បាលនិងរាងកាយ ការផ្លាស់ប្តូរទម្លាប់របស់សិស្សឱ្យបរិភោគអាហារមានតុល្យភាព សុខភាព និងសុខមាលភាពរបស់សិស្ស ភាពឆ្លាតវៃ វិន័យ សាមគ្គីភាព ភាពក្លាហាន និងសីលធម៌ ការបណ្តុះទម្លាប់ល្អ ការមករៀនទាន់ពេល ការធ្វើការជាក្រុម។ តាមរយៈកម្មវិធីនេះ លទ្ធផលសិក្សារបស់សិស្សកាន់តែល្អប្រសើរ អត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់ត្រូវបានកាត់បន្ថយ។

២) **ការផ្តល់សន្តិសុខសង្គម៖** កាត់បន្ថយចំណាយរបស់មាតាបិតាលើការបរិភោគអាហារ បានមួយពេល និងជួយបង្កើនជីវភាពគ្រួសារ។

៣)**ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន៖** យុទ្ធនាការទិញស្បៀងតាមសហគមន៍បានជំរុញឱ្យកសិករតាមសហគមន៍ខិតខំដាំដំណាំតាមតម្រូវការក្នុងកម្រិតខ្នាតតូច និងបានបង្កើតទីផ្សារសម្រាប់កសិករក្នុងសហគមន៍ ការលើកកម្ពស់ការដាំដុះបន្លែ ការចិញ្ចឹមសត្វ និងការបង្កើត ប្រភពចំណូលដល់កសិករ ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការគាំទ្រដល់វិស័យកសិកម្ម ក្នុងស្រុក និងពង្រឹងខ្សែសង្វាក់ផ្គត់ផ្គង់តាមមូលដ្ឋាន។ សាលារៀនមួយចំនួនបានជំរុញឱ្យមានការដាំដំណាំក្នុងសាលារៀន ដើម្បីអាចរកប្រាក់ចំណូលពីកម្មវិធីនេះផងដែរ។

កត្តាជានាជោគជ័យដល់ការអនុវត្តកម្មវិធីអាហារូបត្ថម្ភតាមសាលារៀន រួមមាន៖

- ការផ្លាស់ប្តូរពីកម្មវិធីអាហារពេលព្រឹកបែបបុរាណ ទៅជាកម្មវិធីអាហារពេលព្រឹកដោយប្រើប្រាស់កសិផលក្នុងសហគមន៍ តាមរយៈ
    - ផ្សព្វផ្សាយ និងកៀរគរសហគមន៍ឱ្យចូលរួមវិភាគទានបន្ថែមដល់ចុងភៅ និងទិញសម្ភារៈផ្ទះបាយ
    - សាលារៀនត្រូវរៀបចំទីតាំងឱ្យបានល្អ
    - សហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីផ្សព្វផ្សាយ និងហាមឃាត់ការលក់អាហារគ្មានសុវត្ថិភាពនៅក្បែរបរិវេណសាលារៀន
    - សហការជាមួយអាជ្ញាធរ ដៃគូអភិវឌ្ឍ និងសហគមន៍ ឱ្យជួយផ្តល់គ្រាប់ពូជដំណាំ និងបច្ចេកទេស ឬរបៀបនៃការដាំដុះដំណាំ
- ការយកចិត្តទុកដាក់ក្នុងការអនុវត្តកម្មវិធីអាហារតាមសាលារៀន ពីគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ ដោយមានយន្តការអនុវត្តច្បាស់លាស់ និងអ្នកពាក់ព័ន្ធបានបំពេញតួនាទី និងភារកិច្ចប្រកបដោយការទទួលខុសត្រូវ
- សហគមន៍ចូលរួម និងគាំទ្រទាំងពេលវេលា សម្ភារៈ និងថវិកា តាមរយៈការ ផ្គត់ផ្គង់បន្លែ ត្រី សាច់ និងគ្រឿងទេស។

**៤. ការជំរុញការចូលរួមរបស់សហគមន៍តាមរយៈមូលនិធិសមធម៌៖** ការចូលរួមរបស់សហគមន៍ ក្នុងការលើកកម្ពស់គុណភាពអប់រំមានច្រើនរូបភាព។ ដើម្បីជានាបានភាពជោគជ័យ សាលារៀនត្រូវអនុវត្តដូចខាងក្រោម៖

- បង្កឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធសហការគ្នា ក្នុងការជួយសិស្សឱ្យចេះរៀន និងជួយកែលម្អបរិស្ថានថ្នាក់រៀន និងសាលារៀន
- លើកទឹកចិត្តឱ្យសិស្ស គ្រូបង្រៀន និងមាតាបិតាឱ្យរួមគ្នាកំណត់កិច្ចការត្រូវធ្វើ ក្នុងការជួយសិស្ស និងសាលារៀន
- លើកទឹកចិត្តគ្រប់ភាគីពាក់ព័ន្ធក្នុងការជួយគ្រូបង្រៀនឱ្យមានទឹកចិត្តបង្រៀន និងគ្រប់គ្រងសិស្សឱ្យអាចរៀនបានកាន់តែប្រសើរ ឆ្លើយតបនឹងតម្រូវការរបស់សហគមន៍
- ប្រជុំផ្សព្វផ្សាយ និងកៀរគរធនធានតាមគោលការណ៍ស្ម័គ្រចិត្តតាមសហគមន៍

- បង្កើតគណៈកម្មការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ។

**៥.ការបង្រៀននិងរៀនពេញមួយថ្ងៃ៖** គោលការណ៍ណែនាំស្តីពី ការរៀនពេញមួយថ្ងៃនឹងត្រូវដាក់ចេញឱ្យអនុវត្តនៅតាមសាលារៀនដែលមានសក្តានុពល ទាំងលទ្ធភាព អគារសិក្សា បន្ទប់រៀន និងគ្រូបង្រៀន ក្នុងគោលបំណង៖

- សិស្សមានទំនុកចិត្តចំពោះសាលារៀនដែលមានសក្តានុពល ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព
- ការលើកកម្ពស់គុណភាពអប់រំ និងការបង្កើតឱកាសសិក្សាវែងឆ្ងាយ ព្រមទាំងការបង្ការមិនឱ្យសិស្សយកពេលទៅប្រព្រឹត្តអំពើអបាយមុខផ្សេងៗ
- សាលារៀនមានការរីកចម្រើនខាងផ្នែកកែលម្អបរិស្ថាន ការអនុវត្តកម្មវិធីសិក្សា បានគ្រប់ជ្រុងជ្រោយ ការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ ជាពិសេសការលើកកម្ពស់អំណាន និងការរៀបចំសកម្មភាពក្រៅម៉ោងសិក្សា ដូចជាសិល្បៈ តន្ត្រី វប្បធម៌ គេហវិជ្ជា បណ្ណាល័យ ការអប់រំសីលធម៌ វិន័យ និងសមាធិ
- ការប្រើប្រាស់ធនធានសម្ភារៈរបស់សាលារៀន និងម៉ោងសិក្សាឱ្យអស់លទ្ធភាព
- ការកៀរគរសហគមន៍ឱ្យចូលរួមគាំទ្រ និងវិនិយោគលើវិស័យអប់រំ ចាប់ពីកម្រិតបឋមសិក្សា
- មាតាបិតាមានឱកាសពេញលេញ ក្នុងការប្រកបរបរចិញ្ចឹមជីវិត។

ដើម្បីពង្រឹងគុណភាពនៅកម្រិតបឋមសិក្សា ក្រសួងនឹងរៀបចំកែទម្រង់កម្មវិធីសិក្សាពីការរៀនមួយពេលទៅការរៀននិងបង្រៀនពេញមួយថ្ងៃ រៀបចំក្រុមជានាគុណភាពផ្ទៃក្នុង រៀបចំបុគ្គលិកសិក្សាឱ្យសមស្របតាមសមត្ថភាពជំនាញ រៀបចំកម្មវិធីសិក្សាផ្តោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ចាត់ចែងនិងគ្រប់គ្រងសៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ រៀបចំបន្ទប់រៀននិងថ្នាក់រៀនជាបណ្តើរៗឱ្យមានបច្ចេកវិទ្យា បង្កើនការបង្រៀនភាសាបរទេស និងរៀបចំបរិស្ថានសាលារៀនទាំងមូលឱ្យក្លាយជាទីមេត្រី។ ឧត្តមានុវត្តន៍នៃការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ មានដូចជា៖

- ការបង្រៀននិងរៀនពេញមួយថ្ងៃ តាមកម្មវិធីសិក្សាទំនើប ដោយបង្កើនម៉ោងសិក្សា ពង្រីកការអនុវត្តកម្មវិធីសិក្សានិងមុខវិជ្ជាសិក្សា ការលើកកម្ពស់ការអប់រំឌីជីថល ការបង្រៀនភាសាបរទេស និងការអប់រំស្នែមភាសាជាតិ ភាសាបរទេស កុំព្យូទ័រ រ៉ូបូទិក ។ល។
- មុនពេលចាប់ផ្តើមដំណើរការរៀនពេញមួយថ្ងៃ សាលារៀនត្រូវសិក្សាពីការចំណាយរបស់សិស្ស អគារសិក្សា ទីតាំងភូមិសាស្ត្រ ជំនួបជាមួយគ្រូ និងជំនួបជាមួយមាតាបិតា
- ការកំណត់មុខសញ្ញាចំណាយដូចជា បុគ្គលិក រដ្ឋបាលសាលារៀន ការអភិវឌ្ឍសាលារៀន និងសន្សំទុក
- ការប្រជុំពិភាក្សារវាងគណៈកម្មការគ្រប់គ្រងសាលារៀនជាមួយគ្រូបង្រៀន ជាមួយមាតាបិតា និងអ្នកពាក់ព័ន្ធ ដើម្បីពន្យល់អំពីដំណើរការ និងលទ្ធផលរំពឹងទុក និងមានការឯកភាពគ្នា។

**៦.ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ៖** បរិវត្តកម្មនៅក្នុងវិស័យអប់រំកំពុងបោះជំហានទៅរកទម្រង់នៃការអប់រំឌីជីថល ដែលឆ្លើយតបយ៉ាងប្រត្យក្សទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥។ ក្រសួងបាននិងកំពុងបន្តអភិវឌ្ឍ និងជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ទែមនៃការអប់រំ ដើម្បីកសាងមូលធនមនុស្សសម្រាប់សេដ្ឋកិច្ចឌីជីថល តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំនៅសាលារៀនជំនាន់ថ្មី។ អត្ថប្រយោជន៍នៃការអប់រំឌីជីថល៖

- សិស្សរៀនដោយខ្លួនឯង និងឆ្លាតជាងមុន
- សិស្សស្គាល់ពីបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់
- ឱកាសសិក្សាទូលំទូលាយ និងសិស្សមានទំនួលខុសត្រូវ
- ការចូលរួមរបស់គ្រូបង្រៀន និងមាតាបិតាកាន់តែស៊ីជម្រៅ

វិធីសាស្ត្រសម្បូរបែបនៃការសិក្សាបច្ចេកវិទ្យាឌីជីថល រួមមាន៖

- ការរៀនសម្របខ្លួន ការកត់ចំណាំ និងល្បែងសិក្សា
- ការរៀនលាយបញ្ចូលគ្នា បច្ចេកវិទ្យាថ្នាក់រៀន ការរៀនបែបវិភាគ
- ការរៀនតាមប្រព័ន្ធអ៊ិនធើណិត ទូរសព្ទ
- ការធ្វើពិសោធន៍តាមបែបឌីជីថល, ការធ្វើ simulation,

ដើម្បីជំរុញការប្រើប្រាស់ឌីជីថល ក្រសួងនឹងបន្ត៖

- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាប្រចាំលើវិធីសាស្ត្របង្រៀន និងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការបង្រៀន
- បំពាក់សម្ភារបរិក្ខារបម្រើឱ្យការអប់រំឌីជីថលនៅទីចាត់ការ បន្ទប់រៀន បណ្ណាល័យ និងបន្ទប់កុំព្យូទ័រ
- លើកទឹកចិត្តសិស្ស និងគ្រូបង្រៀន ឱ្យចូលរួមដោយមិនគិតពីកត្តាបរាជ័យ
- សហការជាមួយក្រសួង និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធើណិត ដើម្បីភ្ជាប់សេវា ដល់សាលារៀន
- សហការជាមួយក្រសួងមានសមត្ថកិច្ចក្នុងការបិទការផ្សព្វផ្សាយកម្មវិធីផ្សេងៗ ដែលរំខានសិស្សនៅលើឧបករណ៍ឌីជីថលរបស់ពួកគេ។

**៧.ការអនុវត្តកម្មវិធីសិក្សាបន្ថែមក្រៅម៉ោងសិក្សា៖** បានបណ្តុះនូវបំណិនសម្បទាបន្ថែមដល់សិស្ស ដែលរួមមាន៖

- ការបណ្តុះជំនាញបន្ថែម ភាពច្នៃប្រឌិត ការធ្វើការជាក្រុម ទំនាក់ទំនង និងមានចរិយាធម៌
- ការទទួលស្គាល់ស្នាដៃនិងស្នារតីលះបង់ ភាពជាគំរូរបស់យុវជន និងភាពជាអ្នកដឹកនាំ
- ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា កម្មវិធីជំនាញស្វែម អំណានក្នុងបណ្ណាល័យ សិល្បៈ កសិកម្ម អប់រំកាយកីឡា និងវប្បធម៌

ដូចនេះដើម្បីអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា សាលារៀនត្រូវ៖

- បង្កើតគណៈកម្មការគ្រប់គ្រងការអនុវត្តកម្មវិធី
- ជួបជាមួយអ្នកអាណាព្យាបាលសិស្ស
- ស្វែងរក និងទាក់ទងអង្គភាព ឬអង្គការដៃគូ សហគ្រិនភាព ឬសាលាបច្ចេកទេស ដើម្បីជួយគាំទ្រដល់ការអនុវត្ត
- បង្កើតរចនាសម្ព័ន្ធគ្រូប្រឹក្សាអាជីព និងជ្រើសរើសគ្រូអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា
- ផ្សព្វផ្សាយព័ត៌មានដល់សិស្ស និងអ្នកអាណាព្យាបាលនៅកម្មវិធីក្រៅម៉ោងសិក្សា
- ជ្រើសរើសសិស្សតាមកម្មវិធី ដែលពួកគេពេញចិត្ត។

**៨.សាលារៀនស្អាតក្នុងក្របខណ្ឌយុទ្ធនាការសាលារៀនគ្មានសំរាម៖** គឺជាការលើកកម្ពស់សុខភាពអនាម័យរបស់អ្នកអប់រំនិងអ្នកសិក្សា ការចូលរួមថែរក្សាបរិស្ថាន សាលារៀន សហគមន៍ឱ្យមានភាពបៃតងតាមរយៈការអប់រំអំពីការទុកដាក់សំរាម ការញែកសំរាម ការកែច្នៃសំរាមឡើងវិញ ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងការបណ្ដុះស្មារតីឱ្យស្រឡាញ់បរិស្ថាន ដើម្បីជានាឱ្យបាននូវសិស្សស្អាត ថ្នាក់រៀនស្អាត គ្រូបង្រៀនស្អាត សាលារៀនស្អាត និងសហគមន៍ស្អាត។

ដើម្បីធ្វើឱ្យសាលារៀនស្អាតគ្មានសំរាម គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកពាក់ព័ន្ធ ត្រូវអនុវត្តវិធានការ ៤ គឺ៖

**(១) ចក្ខុវិស័យ និងការប្ដេជ្ញាចិត្ត៖** គណៈគ្រប់គ្រង និងបុគ្គលិកត្រូវមានការប្ដេជ្ញាចិត្តខ្ពស់ មានស្មារតីការងារជាក្រុម ភាពជាម្ចាស់ និងចក្ខុវិស័យ ដើម្បីកែលម្អសាលារៀនស្របតាមស្តង់ដាសាលាកុមារមេត្រី សាលាមេត្រីបរិស្ថាន និងសូចនាករស្តង់ដាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ។

**(២) ការចូលរួម៖** ព្រះសង្ឃ គ្រូបង្រៀន សិស្ស មាតាបិតា សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវចូលរួមគាំទ្រក្នុងគ្រប់រូបភាព។

**(៣) ភាពជាអ្នកដឹកនាំ៖** សមត្ថភាពក្នុងការកៀរគរធនធាន ការបង្កើតជំនឿទុកចិត្ត ការគ្រប់គ្រងប្រកបដោយតម្លាភាព។

**(៤) ការបង្កើតយន្តការគ្រប់គ្រង៖** ការចូលរួមរបស់ក្រុមប្រឹក្សាកុមារ និងបុគ្គលិក កសាង និងក្នុងការថែទាំបរិស្ថានសិក្សា។

**៩.មជ្ឈមណ្ឌលឧត្តមភាពនៅឧត្តមសិក្សា៖** ដើម្បីឆ្លើយតបនឹងយុគសម័យថ្មី នៃឧស្សាហកម្ម៤.0 ក្រសួងបានបន្តអនុវត្តកំណែទម្រង់ឧត្តមសិក្សា ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលអាណត្តិទី៧ ជាពិសេសមុំទី១ ការអភិវឌ្ឍមូលធនមនុស្ស និងមុំទី៥ ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល។ កំណែទម្រង់ឧត្តមសិក្សាផ្តោតលើ៖

**(១) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព៖** ដោយត្រូវវិនិយោគលើគ្រឹះស្ថានឧត្តមសិក្សា ដែលមានសក្តានុពលដូចជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារសិក្សា អន្តេវាសិកដ្ឋាន មន្ទីរពិសោធន៍ កសិដ្ឋាន មជ្ឈមណ្ឌលឌីជីថល ដើម្បីប្រែក្លាយជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខ និងអាចទទួលបានស្តង់ដាកម្រិតតំបន់ និងអន្តរជាតិ (University Ranking) និងប្រែក្លាយ គ្រឹះស្ថានទាំងនោះ ជាមជ្ឈមណ្ឌលធនធានសម្រាប់ប្រើប្រាស់រួមគ្នា។

**(២) ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន៖** ដោយត្រូវធានាស្វ័យភាព គណនេយ្យភាព ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ប្រព័ន្ធគ្រប់គ្រង ទិន្នន័យឌីជីថល ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធអភិបាលកិច្ច និងការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ ការកសាងផែនការយុទ្ធសាស្ត្រនិងផែនទីបង្ហាញផ្លូវ ការបញ្ជូលអ្នកមានសញ្ញាបត្រថ្នាក់បណ្ឌិតក្នុងក្របខណ្ឌមន្ត្រីរាជការ ការបង្កើតកម្មវិធីថ្នាក់ក្រោយបណ្ឌិត ការសិក្សាលើជំនាញពាក់ព័ន្ធនឹងការងារទាំងរយៈពេលខ្លី និងវែង (reskilling & upskilling) និងការរៀបចំប្រព័ន្ធវាយតម្លៃការបំពេញការងារផ្អែកលើសមិទ្ធកម្ម។

**(៣) ការធ្វើទំនើបកម្មកម្មវិធីសិក្សា និងការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន៖** ដោយត្រូវធ្វើទំនើបកម្ម និងការអភិវឌ្ឍកម្មវិធីសិក្សា ដោយផ្អែកលើលទ្ធផល (Outcome-Based Education Program–OBE) រួមទាំងការផ្តល់សិទ្ធិដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការកែសម្រួល និងការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

ការបញ្ចូលមុខវិជ្ជាថ្មីៗ និង ការបង្កើតកម្មវិធីសិក្សាជំនាញថ្មី ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម ៤.0 ដូចជា៖ បញ្ញាសិប្បនិមិត្រ វិទ្យាសាស្ត្រទិន្នន័យ មេកាត្រូនិក បច្ចេកវិទ្យាព័ត៌មានវិទ្យាសាស្ត្រកុំព្យូទ័រ បច្ចេកវិទ្យាអាហារ វិទ្យាសាស្ត្ររូបធាតុ និងគ្រឿងបង្គុំ វិស្វកម្មអេឡិចត្រូនិក ស្វ័យប្រវត្តិកម្ម មុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System–LMS)។ ការវាយតម្លៃទទួលស្គាល់គុណភាពកម្មវិធីសិក្សា (Program Accreditation) និងការរៀននិងបង្រៀនតាមរយៈប្រព័ន្ធឌីជីថល ការបង្កើតប្រព័ន្ធផ្ទេរក្រេឌីតការសិក្សា (Credit Transfer) ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា និងការផ្សារភ្ជាប់សាកលវិទ្យាល័យជាមួយកម្មវិធីអគារវៃឆ្លាត និងទីក្រុងវៃឆ្លាត ដោយសហការជាមួយក្រុមហ៊ុនក្នុង និងក្រៅប្រទេស។

វិធានការលើកកម្ពស់គុណភាពនៃការរៀននិងបង្រៀន៖ (១)បង្កើនគុណវុឌ្ឍិសាស្ត្រាចារ្យ ដោយផ្ដល់អាហារូបករណ៍ដើម្បីបង្កើនគុណវុឌ្ឍិគ្រូថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ចំនួនសាស្ត្រាចារ្យមានសញ្ញាបត្របណ្ឌិត នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាកើនឡើងពី ៣៤នាក់ ទៅ ៩៥នាក់ និងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញកើនឡើងពី ១៦នាក់ ដល់ ៩៦នាក់ និងឈានដល់ ១០៦នាក់នៅឆ្នាំ ២០២៥ (២) អនុវត្តវិធីសាស្ត្របង្រៀនទំនើប ដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១ តាមរយៈការសិក្សាបែបត្រឡប់ (Blended Learning) ការបង្រៀនតាមបែបសិក្សាគម្រោង (អនុវត្តផ្ទាល់ក្នុងមន្ទីរពិសោធន៍ កសិដ្ឋាន ឬជាក្រុម) ការសិក្សាបែបពិសោធន៍ (Lab based education) ការសិក្សាបែបអនុវត្តផ្ទាល់ Leaning by doing តាមរយៈម៉ូដែល Fab-lab ការបង្រៀនភាសាបរទេស បំណិនសហគ្រិនភាព បំណិនបច្ចេកវិទ្យា និងបំណិនឌីជីថល (៣) ការគាំទ្រដល់និស្សិត ដូចជាការសិក្សាគម្រោង ការស្រាវជ្រាវ ការពិសោធន៍ ការចុះកម្មសិក្សា និងការចល័តនិស្សិតជាមួយសាកលវិទ្យាល័យអន្តរជាតិ ស្ថាប័នដៃគូ និងសហគ្រាសឯកជន និងឧស្សាហកម្ម និងការបង្កើតក្លឹបសិក្សា និងស្វ័យសិក្សា និងការជួយនិស្សិតរៀនយឺត។

**(៤) ការពង្រឹងអន្តរជាតិភាវូបនីយកម្ម៖** បង្កើតកម្មវិធីសិក្សាអន្តរជាតិ (International Academic Programs) រួមមាន កម្មវិធីសិក្សាទ្វេ/ភ្លោះ (Dual Program) និងកម្មវិធីសិក្សារួមគ្នា (Joint-Degree Program) ជាពិសេសសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត តាមរយៈការសហការជាមួយសាកលវិទ្យាល័យដៃគូនៅក្នុងនិងក្រៅប្រទេស និងក្រុមហ៊ុនឧស្សាហកម្ម ការផ្លាស់ប្ដូរគ្រូបង្រៀន អ្នកស្រាវជ្រាវ និងនិស្សិត ការអនុវត្តគម្រោង ស្រាវជ្រាវរួមគ្នា ការអញ្ជើញសាស្ត្រាចារ្យ និងអ្នកជំនាញពីបរទេសមកជួយបង្រៀនមុខវិជ្ជាថ្មីៗ។ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនចំនួន ១១ បាននិងកំពុងបន្តអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូជាមួយសាកលវិទ្យាល័យនៅក្រៅប្រទេសចំនួន ១៧ មកពី ១០ប្រទេស។ កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រថ្មីត្រូវបានបង្កើត និងកែលម្អមានចំនួន ៧៩ ហើយបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សាចំនួន ១៩៩រូប កំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជាមួយសាកលវិទ្យាល័យដៃគូ។

**(៥) ការពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅឧត្តមសិក្សា៖** ការលើកកម្ពស់ការស្រាវជ្រាវ និងបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្ដីស្រាវជ្រាវជាតិនិងអន្តរជាតិ ការពង្រឹងសមត្ថភាព គ្រប់គ្រងការស្រាវជ្រាវ ការផ្ដល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវនិងការបង្កើតប្រាក់ចំណូល ការវាយតម្លៃស្នាដៃស្រាវជ្រាវដើម្បីផ្ដល់ឋានៈសាស្ត្រាចារ្យ ការរៀបចំវេទិកាផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ ការបង្កើតមូលនិធិស្រាវជ្រាវជាតិ ការបង្កើតសង្គមវិទ្យាសាស្ត្រ (Professional Scientific Society) ដើម្បីចែករំលែកបទពិសោធ ការបង្កើតភាពជាដៃគូរវាងសាកលវិទ្យាល័យ

និងសាកលវិទ្យាល័យ (Consortium Universities) សាកលវិទ្យាល័យនិងក្រុមហ៊ុនឧស្សាហកម្មឯកជន (University-Industry Linkage) សាកលវិទ្យាល័យនិងសហគមន៍ (University-Community Partnership) ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សង្គមជាតិ ក្រុមហ៊ុនឧស្សាហកម្ម និងសហគមន៍។ អត្ថបទស្រាវជ្រាវបែបវិទ្យាសាស្ត្រចំនួន៧៧ ត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវអន្តរជាតិ និងអត្ថបទ ២០ទៀតត្រូវបានបោះពុម្ពនៅក្នុង ទស្សនាវដ្ដីស្រាវជ្រាវជាតិ។

**(៦) ការបង្កើនចំនួននិស្សិតចូលរៀន និងបរិយាប័ន្ន៖** ដោយអនុវត្តកម្មវិធីភាពជាដៃគូ ការអប់រំស្វែងតាមគំរូភាពជាដៃគូរវាងមធ្យមសិក្សានិងឧត្តមសិក្សា ការផ្ដល់អាហារូបករណ៍ដល់និស្សិតក្រីក្រនិងមានពិការភាព និងការផ្ដល់ថវិកាគាំទ្រនិស្សិតចូលរៀននៅឧត្តមសិក្សា។

**១០.ការអភិវឌ្ឍឧត្តមសិក្សាក្នុងបរិបទបច្ចេកវិទ្យាឌីជីថល៖** នៅក្នុងយុគសម័យឌីជីថល គោលបំណងសំខាន់នៃការអប់រំឧត្តមសិក្សាគឺ ដើម្បីសម្របខ្លួន និងឆ្លើយតបទៅនឹងទិដ្ឋភាពបច្ចេកវិទ្យាដែលកំពុងវិវត្តយ៉ាងឆាប់រហ័ស។ គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្ដល់ឱ្យនិស្សិតនូវសមត្ថភាពឌីជីថល និងជំនាញត្រិះរិះពិចារណាដែលចាំបាច់សម្រាប់ភាពជោគជ័យក្នុងសតវត្សទី២១។ នៅក្នុងន័យនេះ គ្រឹះស្ថានឧត្តមសិក្សាមានភារកិច្ចបង្កើតការអប់រំ ដែលរួមបញ្ចូលយុទ្ធសាស្ត្រសិក្សាតាមឌីជីថល លើកកម្ពស់ការច្នៃប្រឌិត និងសម្របសម្រួលការតភ្ជាប់ជាសកល ដើម្បីធានាថានិស្សិតត្រូវបានរៀបចំយ៉ាងល្អ សម្រាប់រួមចំណែកក្នុងការអភិវឌ្ឍសង្គមក្នុងយុគសម័យឌីជីថល។ គ្រឹះស្ថានឧត្តមសិក្សាត្រូវពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងពង្រឹងរចនាសម្ព័ន្ធនៃការសិក្សាតាមអនឡាញ បន្តការអភិវឌ្ឍវិជ្ជាជីវៈ និងពង្រឹងប្រព័ន្ធ សុវត្ថិភាពទិន្នន័យឯកជនភាព។

ការអប់រំឌីជីថលនៅកម្រិតឧត្តមសិក្សាបានធានា៖ (១) ភាពសម្បូរបែបនៃធនធានសម្រាប់ការរៀននិងបង្រៀន (២) ភាពងាយស្រួលនៃទំនាក់ទំនង កិច្ចសហការ និងការចូលរួម (៣) ភាពបត់បែននៃកាលវិភាគ និងការរៀនតាមលក្ខណៈបុគ្គល (៤) ការអភិវឌ្ឍការអប់រំឌីជីថល (៥) ការលើកកម្ពស់ជំនាញឌីជីថល (៦) ការបង្កើនការស្រាវជ្រាវ និងការច្នៃប្រឌិត និង (៧) ការគាំទ្រការអប់រំពេញមួយជីវិត។

ដើម្បីគាំទ្រដល់ការអប់រំឌីជីថលនៅកម្រិតឧត្តមសិក្សា ក្រសួងបាននិងកំពុង៖ (១)អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា (២) ការធានាគុណភាព និងស្តង់ដា (៣) ការបត់បែនទៅតាមការផ្លាស់ប្ដូរបច្ចេកវិទ្យា (៤) ការធានាសុវត្ថិភាពទិន្នន័យឯកជនភាព (៥) ការពង្រឹងភាពជាដៃគូជាមួយក្រុមហ៊ុន (៦) ការបន្តការអភិវឌ្ឍវិជ្ជាជីវៈ (៧) ការអភិវឌ្ឍបណ្ដាញសាកលវិទ្យាល័យសាយប័រ (Cyber University Network) ដែលមានគ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន ៦ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនចំនួន ២ ទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្ដាខេត្តចូលរួម ដើម្បីពង្រឹងសមត្ថភាពសាស្ត្រាចារ្យសម្រាប់ការអនុវត្តការបង្រៀន និងរៀនតាមអនឡាញ។

**១១.ការអប់រំបរិយាបន្ននៅកម្ពុជា៖** ជាយុទ្ធសាស្ត្រមួយដើម្បីលើកកម្ពស់គុណភាពអប់រំ សំដៅការផ្ដល់ឱ្យមនុស្សគ្រប់រូបទទួលបានឱកាសស្មើៗគ្នា ដោយមិនគិតពីភេទ អាយុ ពណ៌សម្បុរ ជាតិសាសន៍ ជនជាតិដើមភាគតិច ភាសា សាសនា និន្នាការនយោបាយ ឬពិការភាព ជាពិសេសជនងាយរងគ្រោះ។ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** តែងតែយកចិត្តទុកដាក់ដល់កុមារមានពិការភាព ដោយផ្ដល់កិច្ចគាំទ្រពិសេសតាមគ្រប់រូបភាព។

ចាប់ពីឆ្នាំ ២០១៦ ការផ្ដល់សេវាអប់រំពិសេសត្រូវបានផ្ទេរពីអង្គការគ្រួសារថ្មី មកក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីធានាបាននូវការផ្ដល់សេវាអប់រំ ពិសេសប្រកបដោយគុណភាព ក្រសួងបាន៖

**(១) បង្កើតវិទ្យាស្ថានជាតិអប់រំពិសេស និងនាយកដ្ឋានអប់រំពិសេស៖** ការរៀបចំគោលនយោបាយស្ដីពីការអប់រំកុមារពិការ គោលនយោបាយស្ដីពីការអប់រំបរិយាបន្ន ឯកសារជំនួយ ស្មារតីសម្រាប់គ្រូបង្រៀនវិទ្យាល័យអប់រំពិសេស ឯកសារជំនួយសម្រាប់ការកំណត់អត្តសញ្ញាណកុមារមានពិការភាពក្រោមអាយុ ៥ឆ្នាំ និងសម្របសម្រួលកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។

**(២) ការបន្តវិនិយោគលើវិទ្យាល័យអប់រំពិសេសចំនួន ៦៖** ដើម្បីអនុវត្តកម្មវិធីអប់រំដល់កុមារមានពិការភាពនៅទូទាំងប្រទេស រួមទាំងកុមារខ្សោយសតិបញ្ញានិងអូទីស្សឹម និងការអនុវត្តកម្មវិធីសមាហរណកម្ម ដោយកុមារត្រូវរៀននៅគ្រឹះស្ថានសិក្សារដ្ឋពាក់កណ្ដាលថ្ងៃ និងនៅសាលាអប់រំពិសេសពាក់កណ្ដាលថ្ងៃទៀត។

**(៣) ការផ្ដល់ប្រាក់ឧបត្ថម្ភពិសេស៖** ចំនួន ៨ សែនរៀលលើបៀវត្សគ្រូបង្រៀន ដែលកើន ឡើងជាលំដាប់ ដើម្បីថែរក្សាអ្នកឯកទេសខាងផ្នែកអប់រំពិសេស។

**(៤) ការបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** សហការជាមួយអង្គការគ្រួសារថ្មីក្នុងការធ្វើសវនកម្មគុណភាពប្រចាំឆ្នាំ និងសហការជាមួយដៃគូអន្តរជាតិ ក្នុងការពិនិត្យត្រចៀក និងការគាំទ្របច្ចេកទេស។

ក្រសួងអប់រំ យុវជន និងកីឡាបានផ្ដល់ការអប់រំពហុភាសានៅកម្រិតមត្តេយ្យសិក្សា និង បីឆ្នាំដំបូងនៃបឋមសិក្សាសម្រាប់កុមារជនជាតិភាគតិច នៅក្នុងខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ ដោយសហការជាមួយអង្គការយូនីសេហ្វ និង CARE៖

**(១) ការប្រើប្រាស់គំរូស្ពានចម្លង៖** ពីភាសាជនជាតិភាគតិច (ភាសាព្នង ការ៉ែត គ្រឹង ទំពួន ព្រៅ និងចារ៉ាយ) ដើម្បីឱ្យពួកគេអាចរៀនជាភាសាជាតិទាំងស្រុង នៅថ្នាក់ទី៤។

**(២) ផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា៖** កម្ពុជាជាប្រទេសតែមួយគត់នៅតំបន់អាស៊ីអាគ្នេយ៍ដែលលើកកម្ពស់ការអប់រំពហុភាសា តាមរយៈការកំណត់គោលការណ៍ស្ដីពីការអនុវត្តកម្មវិធីអប់រំពីរភាសា ការរៀបចំឯកសារបណ្ដុះបណ្ដាលគ្រូអប់រំពហុភាសា ឯកសារបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សាអប់រំពហុភាសាជាដើម។

**(៣) ការបញ្ចូលសាលាសហគមន៍ចូលជាគ្រឹះស្ថានសិក្សារដ្ឋ៖** ផ្ដល់ថវិកាដំណើរការសាលារៀន និងបញ្ចូលគ្រូជនជាតិដើមភាគតិចចំនួន ៥០នាក់ ចូលក្នុងក្របខណ្ឌរដ្ឋ ដើម្បីធានាថា កុមារជនជាតិដើមភាគតិចទទួលការអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិត ដើម្បីក្លាយជាមូលធនមនុស្ស។

**១២. មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត៖** ជាផ្នែកមួយដ៏សំខាន់សម្រាប់រួមចំណែកអភិវឌ្ឍធនធានមនុស្សនៅក្នុងសហគមន៍ ឱ្យមានការរីកចម្រើនទាំងផ្នែកបញ្ញាស្មារតី ចំណេះដឹងថ្មី បំណិនថ្មី រួមទាំងការផ្ដល់ជាគំនិតច្នៃប្រឌិត ការបង្កើតថ្មី ការគិតអ្វីដែលងាយ និងមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ ការកាត់បន្ថយភាពក្រីក្រ ការជួយ បង្កើតការងារ ការស្វែងរកការងារជូនអ្នកសិក្សាក្រោយរៀនចប់ជំនាញ។

ដើម្បីជំរុញមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យដំណើរការល្អ និងប្រែក្លាយជាមជ្ឈមណ្ឌល អប់រំពេញមួយជីវិត ទាមទារនូវកត្តាជាច្រើនរួមមាន៖

(១) **ការបំពេញបន្ថែមលើកម្មវិធីសិក្សាសាលារដ្ឋ៖** ស្របតាមតម្រូវការជាក់ស្តែងរបស់ យុវជន និងសិស្ស ដូចជាកម្មវិធីបណ្តុះបណ្តាលភាសាបរទេស បច្ចេកវិទ្យា ព័ត៌មានវិទ្យា ការបណ្តុះបណ្តាលជំនាញ និងការបើកវគ្គខ្លីៗ សម្រាប់យុវជន និងសិស្សចំណេះទូទៅ ព្រមទាំង មានវិធីសាស្ត្រទាក់ទាញសិស្សឱ្យមករៀន ។

(២) **ការផ្សារភ្ជាប់កម្មវិធីបណ្តុះបណ្តាលជាមួយតម្រូវការជាក់ស្តែងក្នុងសហគមន៍៖** ការសិក្សាតម្រូវការទីផ្សារ ការបណ្តុះបណ្តាលជំនាញកសិកម្ម និងការរៀបចំកម្មវិធីប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍ ដូចជាវគ្គខ្លីៗខាងផ្នែកគរុកោសល្យ សិប្បកម្មដែក ការផលិតវីដេអូ ការបណ្តុះបំណិនរកប្រាក់ចំណូលជាដើម។

(៣) **ការចូលរួមនិងការសហការ៖** ការបង្កើតគណៈកម្មការគ្រប់គ្រងដែលសកម្ម និងមានមនសិការខ្ពស់ ដោយមានការចូលរួមពីយុវជនស្ម័គ្រចិត្ត និងការគាំទ្រពីនាយកដ្ឋានអប់រំ ក្រៅប្រព័ន្ធ និងអង្គការដៃគូ ដូចជាអង្គការ DVVI ព្រមទាំងធ្វើការអភិវឌ្ឍសមត្ថភាពគណៈកម្មការគ្រប់គ្រងឱ្យមានសមត្ថភាពពេញលេញទាំងជំនាញទន់ និងជំនាញរឹង។

(៤) **ការធានានិរន្តរភាព៖** តាមរយៈការផ្តល់ថវិការដ្ឋ ការបង្កើតសកម្មភាពរកចំណូល ដើម្បីទ្រទ្រង់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ការកៀរគរធនធានពីប្រភពផ្សេងៗ និងការលើកទឹកចិត្តដល់បុគ្គលិក។

**១៣.ក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា និងការផ្លាស់ប្តូរ ឥរិយាបថជាវិជ្ជមាន៖** គោលបំណងរបស់ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារគឺ ដើម្បីប្រមូលផ្តុំយុវជន និងកុមារគ្រប់រូបនៅក្នុងសាលារៀន ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ សាសនា ភេទ វណ្ណៈ ពិការភាព ឱ្យក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ មានភាពក្លាហាន មានសាមគ្គីភាព ចេះរស់នៅជាមួយគ្នាប្រកបដោយគុណធម៌ សីលធម៌ សុជីវធម៌ និងមានគំនិតស្នេហាជាតិមាតុភូមិ។

ដើម្បីធានាបាននូវការគ្រប់គ្រងសាលារៀន និងការរៀននិងការបង្រៀនប្រកបដោយ គុណភាព និងប្រសិទ្ធភាព ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ ត្រូវចូលរួមលើកកម្ពស់៖

(១) **ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា៖** ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ កម្មវិធីមិត្តអប់រំមិត្ត យុទ្ធនាការលើកកម្ពស់ការយល់ដឹងពីសុខភាពបន្តពូជ និងការប្រយុទ្ធ ប្រឆាំងការប្រើប្រាស់សារធាតុញៀន។

(២) **ការងារស្ម័គ្រចិត្ត៖** ដើម្បីលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារសង្គម ហាត់ការ និងការបណ្តុះបំណិនបច្ចេកទេស។

(៣) **ការបង្កើតក្លឹបសិក្សា៖** ការលើកកម្ពស់ស្វ័យសិក្សា និងការសិក្សារៀនសូត្រក្រៅម៉ោងសិក្សា។

(៤) **ការបណ្តុះបំណិនសតវត្សរ៍ទី២១៖** ការចូលរួមក្នុងការប្រឡងប្រណាំង និងកម្មវិធីយុវជន ដើម្បីបង្កើនចំណេះដឹង បំណិនជីវិត បំណិនឌីជីថល បំណិនត្រិះរិះពិចារណា ការធ្វើការងារជាក្រុម និងបង្កើតទម្លាប់និងឥរិយាបថល្អ ដែលមានភាពចាំបាច់សម្រាប់យុវជននៅក្នុងសង្គមបច្ចុប្បន្ន។

**១៤.ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា៖** កំណែទម្រង់កីឡាចាប់ផ្តើមនៅឆ្នាំ ២០១៥ ពីការកែជួសជុលកែលម្អពហុកីឡដ្ឋានជាតិអូឡាំពិក ដែលពីមុនជាកន្លែងជម្រករបស់ជនអនាថា ឱ្យទៅជាទីកន្លែងប្រកួតកីឡាបាល់ទាត់តាមស្តង់ដារបស់ FIFA។ កំណែទម្រង់កីឡាផ្តោតលើ៖

(១) **ការយកចិត្តទុកដាក់របស់រដ្ឋ៖** ប្រមុខរាជរដ្ឋាភិបាលបានទទួលជួបជារៀងរាល់ឆ្នាំ ជាមួយកីឡាករ កីឡាការិនី ដើម្បីផ្តល់ការលើកទឹកចិត្តក្នុងគ្រប់រូបភាព ទាំងការជួបមុនចេញទៅប្រកួតនៅក្រៅប្រទេស ទាំងការចែករង្វាន់ដល់ជ័យលាភី។

(២) **ការកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡា៖** ឱ្យដល់ស្តង់ដាអន្តរជាតិ។

(៣) **ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ៖** ការបង្កើនប្រាក់រង្វាន់ដល់ជ័យលាភី និងការបង្កើនប្រាក់ឧបត្ថម្ភអាហារប្រចាំខែមួយជាពីរ។

(៤) **ការពង្រឹងសមត្ថភាពរបស់សហព័ន្ធកីឡា៖** ការផ្តល់ថវិកាដំណើរការដល់សហព័ន្ធកីឡាដែលមានស្តង់ដា។

(៥) **ការហាត់ហ្វឹកហ្វឺន និងកិច្ចសហការល្អជាមួយគណៈកម្មការជាតិអូឡាំពិក៖** ក្រសួងអប់រំ យុវជន និងកីឡាទទួលបន្ទុកគ្រប់គ្រងការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស។ កត្តាទាំងអស់នេះបាននាំមកនូវលទ្ធផល គឺកម្ពុជាទទួលបានមេដាយសរុប ២៨២ (មាស ៨១) នៅក្នុងការប្រកួតកីឡាស៊ីហ្គេម ឆ្នាំ ២០២៣។

ការអប់រំកាយ និងកីឡាជាសមាសភាគមួយនៃវិស័យអប់រំ ដែលជាមធ្យោបាយហាត់ពត់រាងកាយ និងបញ្ញាស្មារតីរបស់មនុស្សឱ្យមានការលូតលាស់ល្អ កម្លាំងមាំមួន និងមានសុខភាពល្អ។ ប្រការនេះជួយកសាងធនធានមនុស្សឱ្យក្លាយជាពលរដ្ឋល្អ រួមចំណែកកសាង និងការពារជាតិមាតុភូមិ។ ក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងអនុវត្តកម្មវិធីអប់រំកាយ និងកីឡាក្នុងម៉ោងសិក្សា (២ម៉ោងក្នុងមួយសប្តាហ៍) នៅសាលាចំនួន ២,៧៨៦ ការរៀបចំការប្រកួតកីឡាសិស្សនៅកម្រិតរាជធានី ខេត្ត និងការប្រកួតកីឡាជ្រើសរើសជើងឯកសិស្សបឋមសិក្សា និងមធ្យមសិក្សាទូទាំងប្រទេសប្រចាំឆ្នាំ។

តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្រសួងអប់រំ យុវជន និងកីឡានឹង៖

(១) **កម្មវិធីក្រៅម៉ោងសិក្សា៖** ដាក់បញ្ចូលការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាទៅក្នុងកម្មវិធីកីឡាក្រៅម៉ោងសិក្សា និងការអប់រំសិស្សឱ្យយល់ពីសារៈសំខាន់នៃកីឡា ក្នុងការលើកកម្ពស់សុខភាពនិងជីវភាពរស់នៅ។ ការវិនិយោគ ១ដុល្លារនឹងទទួលផលមកវិញ ៣ដុល្លារ។

(២) **ការរៀបចំកម្មវិធីសិក្សាថ្មី និងការលើកកម្ពស់គុណវុឌ្ឍិគ្រូកីឡា៖** ការរៀបចំកម្មវិធីសិក្សាទំនើប ដោយសហការជាមួយអង្គការ Hearts of Gold និងការបណ្តុះបណ្តាលគ្រូកីឡាតាមរូបមន្តបរិញ្ញាបត្រ ឬ ១២+៤។

(៣) **ការផ្សារភ្ជាប់៖** ការអប់រំកាយជាមួយនឹងកីឡាតាមគ្រឹះស្ថានសិក្សា និងកីឡាកម្រិតខ្ពស់ (ការលេងបាល់គ្រប់ប្រភេទ ការបង្កើតក្លិបកីឡា)។

(៤) **ការរៀបចំការប្រកួត៖** លើកទឹកចិត្តឱ្យសហព័ន្ធកីឡារៀបចំការប្រកួតកីឡា ដើម្បីជ្រើសរើសកីឡាករមានសក្តានុពល ឱ្យចូលក្នុងក្រុមកីឡាករថ្នាល និងកីឡាករជម្រើសជាតិ។

**១៥. ការលើកកម្ពស់សុខភាពសិក្សានៅតាមសាលារៀន៖** គឺជាចំណុចគន្លឹះមួយ ក្នុងចំណោមអាទិភាពទាំងបួនរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈ៖

**(១)ការលើកកម្ពស់សុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ៖** ការរៀបចំបន្ទប់សុខភាព ការផ្ដល់សេវាពិនិត្យសុខភាព និងការផ្ដល់ថ្នាំបង្ការ។ ការរៀបចំ«បន្ទប់សុខភាពសិក្សាគ្រប់ជ្រុងជ្រោយ» មុនគេនៅសាលាបឋមសិក្សាចតុមុខ និងសាលារៀនជាច្រើនទៀតបានយកបទពិសោធនេះ ទៅអនុវត្តនៅសាលារៀនរបស់ខ្លួនជាបន្តបន្ទាប់។ នៅឆ្នាំ២០២២ ក្រសួងទទួលបានពានរង្វាន់ «ទិវាពិភពលោកគ្មានថ្នាំជក់» ពីអង្គការសុខភាពពិភពលោក (WHO)។

**(២) ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ៖** បរិក្ខារលាងសម្អាតដៃ បង្គន់អនាម័យ និងការគ្រប់គ្រងកាកសំណល់។ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានសាងសង់បង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃចំនួន ២,៦៩៣ នៅតាមសាលារៀនអស់ថវិកា ៩លានដុល្លារ និងសាងសង់ដោយសហគមន៍។ គ្រឹះស្ថានសិក្សារដ្ឋ ១០០% មានបង្គន់អនាម័យ។

**(៣) ការលើកកម្ពស់អាហារូបត្ថម្ភ និងគុណភាពចំណីអាហារ៖** កម្មវិធីផ្ដល់អាហាតាមសាលារៀន ការលើកកម្ពស់មីក្រូសារជាតិក្នុងចំណីអាហារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន។

**(៤) ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងមេត្រីភាព៖** អនាម័យ បរិស្ថានស្អាត សួនផ្កា និងទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡា។

**(៥) ការលើកកម្ពស់សន្តិសុខនិងសណ្ដាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា៖** ការរក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់ និងការបំពាក់ឧបករណ៍បង្ការការពារ។

**(៦) ការលើកកម្ពស់ការអប់រំសុខភាព៖** ការអនុវត្តកម្មវិធីសិក្សា ២ម៉ោងក្នុង ១សប្ដាហ៍ ការរៀបចំសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងការបណ្ដុះបណ្ដាលគ្រូមុខវិជ្ជាអប់រំសុខភាព។

**(៧) ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដារ៖** ក្រសួងបានសហការជាមួយក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ព្រមទាំងដៃគូអភិវឌ្ឍផ្សេងទៀត ដោយរៀបចំជា «គោលការណ៍ប្រតិបត្តិស្តង់ដាស្ដីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណោះទូទៅ»នៅឆ្នាំ២០២២។ គោលការណ៍នេះមាន ៩ស្តង់ដា ស្របតាមយុទ្ធសាស្ត្រទាំង៩ នៃគោលនយោបាយជាតិស្ដីពី សុខភាពសិក្សា ដែលរួមមាន ២៦សូចនាករ និង ៥៧ សូចនាកររង។

- **សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- **អង្គសន្និបាតទាំងមូលជាទីមេត្រី**

សមិទ្ធផលអប់រំដែលក្រសួងសម្រេចបានក្នុងឆ្នាំសិក្សាកន្លងមក គឺពិតជាអាស្រ័យដោយការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្ដេចតេជោ** អតីតនាយករដ្ឋមន្ត្រី និង**សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ដែលជានិច្ចកាលតែងយកចិត្តទុកដាក់លើវិស័យអប់រំ និងចាត់ទុកវិស័យអប់រំជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ច និងជាវិស័យអភិវឌ្ឍធនធានមនុស្សសម្រាប់ការអភិវឌ្ឍសង្គមជាតិ។

ជាទីបញ្ចប់ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងក្នុងនាមអង្គសន្និបាតទាំងមូល ខ្ញុំបាទសូមគោរពជូនពរ **សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ លោកគ្រូ អ្នកគ្រូ សូមមានសុខភាពល្អ សិរីសួស្ដី ជ័យមង្គល ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិនាពេលដ៏ខ្លីខាងមុខ និងសូមសមប្រកបដោយពុទ្ធពរ ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំបាទមានកិត្តិយស សូមអនុញ្ញាតគោរពអញ្ជើញ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមេត្តាមានមតិសំណេះសំណាល ណែនាំ និងផ្តល់អនុសាសន៍ដល់អង្គសន្និបាតទាំងមូលសម្រាប់យកទៅអនុវត្ត និងប្រែក្លាយជាទិសដៅភារកិច្ចឆ្នាំសិក្សាថ្មី ២០២៣-២០២៤ និងឆ្នាំសិក្សាខាងមុខឱ្យសម្រេចបានជោគជ័យថែមទៀត។

*សូមគោរពអញ្ជើញ !*

**សុន្ទរកថា**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុង**

**ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា**

**ឆ្នាំសិក្សា ២០២២-២០២៣ និងទិសដៅសម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤**

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤

- ឯកឧត្តម លោកជំទាវ គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី
- សមាជិក សមាជិកាអង្គសន្និបាត ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ ដោយបានចូលរួមក្នុង «**ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០២២-២០២៣ និងលើកទិសដៅការងារឆ្នាំសិក្សា ២០២៣-២០២៤**» បន្ទាប់ពីបានដំណើរការដោយរលូនក្នុងរយៈពេល ៣ថ្ងៃកន្លងមកនេះ និងបានដាក់ចេញនូវវិធានការសម្រាប់បន្តអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា ក្នុងឆ្នាំបន្តបន្ទាប់ទៀត ក្នុងគោលដៅអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល អាណត្តិទី៧នៃរដ្ឋសភា ក៏ដូចជាអនុសាសន៍ទាំង ៤ចំណុច ដែលខ្ញុំបានដាក់ចេញនៅក្នុងអង្គប្រជុំលើកដំបូង នៃគណៈរដ្ឋមន្ត្រីក្នុងការលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតលើការពង្រឹងគុណភាពសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សា រួមមាន៖ ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន, ទី២. ការពិនិត្យកែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាម តម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស, ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា, និងទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ក្នុងការអប់រំស្របតាមពាក្យស្លោកភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីការអប់រំ។

ខ្ញុំសូមកោតសរសើរដល់ថ្នាក់ដឹកនាំ និងអ្នកបច្ចេទេសនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានចាត់ចែង និងរៀបចំការឆ្លើយតបភ្លាមៗ ដោយបានធ្វើការពិនិត្យឡើងវិញលើស្តង់ដាសាលារៀន ដោយបញ្ជ្រាបចំណុចទាំង ៤ ខាងលើ និងដាក់ឱ្យអនុវត្ត «ស្តង់ដាសាលារៀនគំរូ» ចាប់ពីសាលាមត្តេយ្យរហូតដល់សាលាមធ្យមសិក្សា ព្រមទាំងបានរៀបចំយន្តការចុះវាយតម្លៃសាលារៀន យន្តការចុះជួយសាលារៀន និងយន្តការពិនិត្យតាមដាន ជាពិសេសការធ្វើអាទិភាវូបនីយកម្មថវិកា និងប្រមូលផ្តុំធនធានសម្រាប់គាំទ្រដល់ការអនុវត្តសាលារៀនគំរូ ផងដែរ។

ជាការពិត សាលារៀនជាអង្គភាពផ្តល់សេវាសាធារណៈ ដែលស្ថិតនៅជិតប្រជាពលរដ្ឋ សាលារៀនត្រូវតែអនុវត្តនូវតួនាទីប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការបង្រៀន និងរៀន និងផ្តល់នូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដល់សិស្សានុសិស្សគ្រប់រូប ដែលទាមទារឱ្យសាលារៀនត្រូវពង្រឹងអភិបាលកិច្ច ប្រកបដោយភាពធន់ បុរេសកម្ម និងប្រមូលផ្តុំការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសសហគមន៍ និងមាតាបិតា ក្នុងការអភិវឌ្ឍសាលារៀន គ្រប់ជ្រុងជ្រោយស្របតាមស្តង់ដាសាលារៀនគំរូ ។

ខ្ញុំពិតជាគាំទ្រចំពោះការវាយតម្លៃសាលារៀនទាំងបីកម្រិត ដែលក្រសួងបានជ្រើសរើស និងទទួលស្គាល់ជាសាលារៀនគំរូ ទាំង១២០សាលា នៅដំណាក់កាលដំបូងនេះ ក្នុងន័យទទួលស្គាល់នូវសមិទ្ធផលសាលារៀន ទាំងលទ្ធផលសិក្សារបស់សិស្សខ្ពស់ ទាំងកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស និងគ្រួសារក្នុងការអភិវឌ្ឍសាលារៀន ជាសាលារៀនជាប់ចំណាត់ថ្នាក់អង្គភាពសេវាសាធារណៈល្អ សាលារៀនស្អាត នាយកល្អ ។ល។ និងក្នុងរូបភាពផ្សព្វផ្សាយការប្រតិបត្តិដ៏ល្អ ដែលអាចជាគំរូដល់សាលារៀន នៅជុំវិញ និងសាលារៀនដទៃទៀត ឱ្យខិតខំអភិវឌ្ឍសាលារៀនស្របតាមយុទ្ធសាស្ត្រផ្ការីក។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ និងបានបង្កើតលេខាធិការដ្ឋានមួយ ដែលដើរតួជាសេនាធិការរបស់គណៈកម្មាធិការជាតិ ក្នុងគោលបំណងជួយគាំទ្រដល់ការលើកកម្ពស់ការអប់រំ ដែលក្នុងដំណាក់កាលដំបូងផ្តោតលើសាលាបឋមសិក្សាប្រមាណ៥០ និងផ្តល់នូវការគាំទ្រ និងការចុះជួយលើផ្នែកទន់ (soft skill) ដើម្បីឱ្យនាយកសាលា គ្រូបង្រៀន និងសហគមន៍ចូលរួម និងការរៀបចំកម្មវិធីក្រៅម៉ោងសិក្សាយ៉ាងហោច ២ម៉ោងសិក្សាបន្ថែម ដើម្បីឱ្យសិស្សបានមកសាលារៀន និងទទួលបាននូវការបំប៉នមេរៀនបន្ថែមទៅលើការសិក្សាក្នុងម៉ោងផ្លូវការ ការសិក្សាភាសាអង់គ្លេស កុំព្យូទ័រ និងសកម្មភាពផ្សេងៗទៀតដូចជា ការអានជាក្រុម ការអាននៅក្នុងបណ្ណាល័យ ការធ្វើលំហាត់បន្ថែម សកម្មភាពសង្គម ការអប់រំសីលធម៌ និងការលេងកីឡា។ល។ ការរៀបចំសកម្មភាពក្រៅម៉ោងសិក្សានេះ ក៏មានគោលដៅកាត់បន្ថយម៉ោងទំនេរ និងប្រែក្លាយម៉ោងទំនេររបស់កុមារ និងយុវជន ដែលអាចយកទៅប្រព្រឹត្តសកម្មភាពអសកម្មមួយចំនួន ឱ្យក្លាយទៅជាម៉ោងសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនវិញ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

**អង្គសន្និបាតទាំងមូល!**

ស្របពេលដែលព្រះរាជាណាចក្រកម្ពុជារក្សាបាននូវសុខសន្តិភាព និងការអភិវឌ្ឍ ហើយអ្វីដែលជាការកត់សម្គាល់ថែមទៀតនោះ ឆ្នាំសិក្សា ២០២២-២០២៣ ជាឆ្នាំចុងក្រោយ ដែលក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានា ដូចបានលើកឡើងនៅក្នុងរបាយការណ៍សង្ខេបរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ដែលពិតជាបានស្តែងចេញនូវកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហការយ៉ាងស្អិតរមួតរបស់ថ្នាក់ដឹកនាំ, បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់, លោកគ្រូ អ្នកគ្រូ, មាតាបិតា, សហគមន៍ និងអាជ្ញាធរដែនដី ក្នុងការអភិវឌ្ឍវិស័យអប់រំឱ្យមានការរីកចម្រើនទៅមុខ ស្របតាមតួនាទី និងភារកិច្ចរៀងៗខ្លួនជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់។ ជាមួយនេះ ខ្ញុំក៏សូមអរ

គុណ និងវាយតម្លៃខ្ពស់ចំពោះដៃគូអភិវឌ្ឍ, អង្គការជាតិ អន្តរជាតិ, និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួម, សហការ, និងផ្តល់ការឧបត្ថម្ភគាំទ្រទាំងសម្ភារៈ, ថវិកា, និងបច្ចេកទេស។

អង្គសន្និបាតអប់រំនៅពេលនេះ បានដំណើរការដោយរលូន និងទទួលបានសមិទ្ធផល គួរជាទីមោទនៈលើការងារអប់រំ, ការអភិវឌ្ឍយុវជន, និងការអប់រំកាយនិងកីឡា ដោយបានពិនិត្យឡើងវិញនូវសមិទ្ធផលសម្រេចបានក្នុងឆ្នាំសិក្សាកន្លងមក ព្រមទាំងបានដាក់ចេញនូវអាទិភាព និងទិសដៅការងារនាពេលខាងមុខ ឱ្យកាន់តែស៊ីជម្រៅ និងមុតស្រួច ស្របតាមបរិការណ៍ថ្មីៗនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទាំងក្នុងតំបន់ និងពិភពលោក ជាពិសេសក្នុងខណៈដែលកម្ពុជាកំពុងរក្សាបាននូវសុខសន្តិភាពពេញលេញ, ស្ថិរភាពនយោបាយ, និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបានឆ្លើយតបទៅនឹងចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៣០ និង២០៥០។

ខ្ញុំសូមគាំទ្រចំពោះកម្មវិធីកំណែទម្រង់ វិធានការ និងអាទិភាព ដែលអង្គសន្និបាតបានដាក់ចេញដោយឈរលើមូលដ្ឋាននៃសមិទ្ធផលនាពេលបច្ចុប្បន្ន និងកាលានុវត្តភាពថ្មីៗ, និងការកំណត់ទិសដៅកំណែទម្រង់ច្បាស់លាស់ ប្រកបដោយភាពជាក់ស្តែងនិយម ជាមួយនឹងគោលដៅជាក់លាក់, ព្រមទាំងមានរចនាសម្ព័ន្ធដឹកនាំ និងមានយន្តការអនុវត្តច្បាស់លាស់ ដើម្បីកសាងមូលធនមនុស្សដែលមានសក្តានុពលពេញលេញ ទាំងចំណេះដឹង ជំនាញ និងអាកប្បកិរិយាសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់អាទិភាព ក្នុងការជ្រើសរើសគ្រូបង្រៀន ទាំងគ្រូបង្រៀនមានក្របខណ្ឌ និងគ្រូបង្រៀនកិច្ចសន្យាបច្ចេកទេស ដើម្បីបំពេញបន្ថែមនូវតម្រូវការគ្រូបង្រៀននិងប្រកបដោយគុណភាព, ការកៀរគរ និងការផ្តល់ធនធានបន្ថែមទៀតសម្រាប់គាំទ្រដល់ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន, ការអនុវត្តកំណែទម្រង់សាលារៀន, ការអភិវឌ្ឍ និងការលើកកម្ពស់បំណិនសតវត្សរ៍ទី២១ដល់យុវជន, ការអប់រំវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា, ការជំរុញការអប់រំឌីជីថល, កំណែទម្រង់សាលាគរុកោសល្យ, ការលើកកម្ពស់សុខភាពសិក្សា, និងការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា។

ដើម្បីលើកទឹកចិត្ត និងយកចិត្តទុកដាក់លើកិច្ចការដ៏មានសារៈសំខាន់នេះ ខ្ញុំសូមផ្តល់អនុសាសន៍សំខាន់ៗសម្រាប់អនុវត្តបន្តដូចខាងក្រោមនេះ ៖

ទី១) បន្តពង្រឹងអភិបាលកិច្ចសាលារៀន និងអភិវឌ្ឍប្រព័ន្ធអប់រំឱ្យកាន់តែរឹងមាំ, មានភាពបុរេសកម្ម, ទំនើបកម្ម និងឆ្លើយតបទៅនឹងបរិការណ៍ជាតិ និងអន្តរជាតិ ដែលបាននិងកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័ស តាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូ និងការធានាបាននូវការសេវាអប់រំដែលមានប្រសិទ្ធភាព និងគុណភាពប្រកបដោយសមធម៌ បរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ទី២) បន្តពិនិត្យកែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និង៏ឥរិយាបថរបស់អ្នកសិក្សា ដូចជាចាប់ផ្តើមអនុវត្តការសិក្សាពេញមួយថ្ងៃ និងកែលម្អសៀវភៅសិក្សាគោល ដើម្បីឱ្យស្របគ្នាជាមួយបណ្តាប្រទេសជឿនលឿន។

ទី៣) ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្របង្រៀន វិធីសាស្ត្ររៀន និងវិធីសាស្ត្រវាយតម្លៃថ្មី ដែលអាចអនុញ្ញាតឱ្យសិស្សអភិវឌ្ឍបំណិននៃការគិត ប្រកបដោយការត្រិះរិះពិចារណា ដោះស្រាយបញ្ហាដែលទាក់ទងនឹងជីវិតប្រចាំថ្ងៃ និងអនុវត្តចំណេះដឹងវិទ្យាសាស្ត្រក្នុងជីវិតប្រចាំថ្ងៃ។

ទី៤) បន្តកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយត្រូវពង្រឹងគុណវុឌ្ឍិគ្រូបង្រៀនចេញថ្មី និងធ្វើវិក្រឹតការគ្រូបង្រៀន, កែលម្អការបណ្តុះបណ្តាលគ្រូ ដើម្បីបំពេញតាម "ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន" និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ទី៥) បន្តអភិវឌ្ឍការអប់រំឌីជីថល ដោយត្រូវបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត, បំពាក់បន្ទប់ពិសោធន៍ឌីជីថល, ភ្ជាប់បណ្តាញអគ្គិសនី និងអ៊ីនធើណិតនៅតាមគ្រឹះស្ថានសិក្សា, លើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពឌីជីថលដល់គ្រូបង្រៀន, បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងការបង្រៀននិងរៀន, កែលម្អមាតិកាឌីជីថល និងបង្កើតមជ្ឈមណ្ឌលអប់រំឌីជីថល និងផ្សព្វផ្សាយវេទិកាឌីជីថលឱ្យកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ។

ទី៦) បន្តលើកកម្ពស់សុខភាពអនាម័យនៅតាមគ្រឹះស្ថានសិក្សា ត្រៀមវិធានការឆ្លើយតបនិងចូលរួមទប់ស្កាត់ភ្លាមៗ និងបង្កើនការអប់រំអំពីសុវត្ថិភាពសុខភាពសិក្សា, សុវត្ថិភាពចំណីអាហារ, កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព ដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា, បរិស្ថានសាលារៀនបៃតង, សាលារៀនស្អាតគ្មានសំរាម, និងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ ។

ទី៧) ជំរុញភាពជាដៃគូសាធារណៈ និងសហគមន៍ក្នុងការអប់រំ ដោយចាប់ផ្តើមអនុវត្តនៅតាមសាលារៀនគំរូ និងរៀបចំសេចក្តីណែនាំអនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សា ក្នុងគោលដៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួម ដូចជាការបង្កើតមូលនិធិសមធម៌ ដើម្បីប្រើប្រាស់ថវិកាបដិភាគដោយស្ម័គ្រចិត្តពីមាតបិតាសិស្ស សម្រាប់គាំទ្រដល់ការបន្ថែមមុខវិជ្ជាថ្មីៗ, ការបង្កើតទំនាក់ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស, និងការអប់រំមាតាបិតាឱ្យផ្តល់តម្លៃបន្ថែមទៀតដល់ការអប់រំ និងលើកទឹកចិត្តពួកគាត់ឱ្យចូលរួមជាមួយការសិក្សារបស់កូនកាន់តែច្រើន។

ទី៨) បន្តអភិវឌ្ឍកុមារ និងយុវជនឱ្យមានស្មារតីទទួលខុសត្រូវ មានជំនឿលើសមត្ថភាពរបស់ខ្លួន និងប្រកាន់ខ្ជាប់នូវទង្វើវិជ្ជមានក្នុងសង្គម មានសីលធម៌ និងការរស់នៅក្នុងភាពជាពលរដ្ឋល្អ តាមរយៈការបំផុសចលនា «កូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ», កម្មវិធីយុវជនស្ម័គ្រចិត្ត, និងការលើកទឹកចិត្តឱ្យយុវជនចុះជួយដល់មូលដ្ឋាននៅតាមសហគមន៍, ព្រមទាំងបន្តបណ្តុះបណ្តាលជំនាញបច្ចេកទេស និងជំនាញទន់ដល់យុវជន សំដៅឆ្លើយតបបានទៅនឹងឱកាសការងារ និងភាពរឹងមាំនៃកោសិកាសង្គម។

ទី៩) បន្តលើកកម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និងសុខុមាលភាពល្អ, កាយសម្បទាមាំមួន, ឆន្ទៈមោះមុត, អំណត់ព្យាយាម, មានវិន័យ, មានស្មារតីក្រុម, គំនិតច្នៃប្រឌិត, និងមានការតស៊ូស្វិតស្វាញ។ ជាមួយនេះ ពង្រឹងការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា, ពង្រឹងយន្តការដៃលមានស្រាប់រួមទាំងសហព័ន្ធកីឡា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា ការបណ្តុះបណ្តាលធនធានមនុស្ស និងការលើកទឹកចិត្ត ដែលជាកត្តាចម្បងក្នុងការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការត្រៀមខ្លួនរបស់អត្តពលិក, និងការពង្រឹងគុណភាពនៃការប្រកួតគ្រប់កម្រិត។

ទី១០) បន្តការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ, ការកសាងគោលនយោបាយ និងផែនការអប់រំ, និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ និងគ្រូបង្រៀនឱ្យបានពេញលេញ

និងមានភាពរស់រវើកនិងប្រទាក់ក្រឡាគ្នា ដើម្បីជានាភាពស័ក្តិសិទ្ធិភាពនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ ថ្នាក់។

ខ្ញុំមានសុទិដ្ឋិនិយមចំពោះសមិទ្ធផលរបស់អង្គសន្និបាត និងអនុសាសន៍សំខាន់ៗ ដែលខ្ញុំបានលើកឡើងនាពេលនេះ ដែលនឹងក្លាយជាមូលដ្ឋាន និងជាធាតុចូលសម្រាប់យកទៅអនុវត្ត ក្នុងវិស័យអប់រំកម្ពុជានៅឆ្នាំសិក្សាថ្មី និងឆ្នាំសិក្សាបន្តបន្ទាប់។

នៅទីបញ្ចប់ ជាមួយនឹងការប្រកាសបិទ **«សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២២-២០២៣ និងលើកទិសដៅការងារឆ្នាំសិក្សា ២០២៣-២០២៤»** ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ និងអង្គសន្និបាតទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**